៨

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ សីហា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

៨

# កម្ពុជសុរិយា


ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ នៃ ពុទ្ធសាសនបណ្ឌិត្យ


អត្ថបទ　　　ផ្នែកសាសនា　　　ទំព័រ


១— មហាសីល លោក ប៉ូ-ប៉ូ រៀបរៀង . . . . . ៧៨៩

២— ទស្សនវិជ្ជាពុទ្ធសាសនា ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង ៧៩៧


## ផ្នែកអក្សរសាស្ត្រ


៣— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៨១៤

៤— រឿងសាមកុក (ត) ឧកញ៉ាទូ-កន ប្រែរៀបរៀង . . . . ៨១៧

៥— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ សហជីវិន ពេជ-សល់ ប្រែរៀបរៀង ៨២៩

៦— ល្បើកអក សហ. លី-ធាមតេង ស្រាវជ្រាវ . . . . ៨៤៤

៧— ឯកសារ : ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង ឧកញ៉ា ប្រសើរលិខិត ម៉ែន-ទន់ រៀបរៀង. . . . . . ៨៦១


## ផ្នែកកំណាត់-ប្រវត្តិការណ៍


៨— ពិធីបូជាសព ព្រះសុមេធាវង្ស ប្រាជ្ញ-ប៉ុល . . . . ៨៨៥

៩— សុន្ទរកថា ព្រះពុទ្ធវង្ស ហេក-ទាង ថ្លែងក្នុងឱកាសបូជាព្រះសព ព្រះសុមេធាវង្ស ប្រាជ្ញ-ប៉ុល នៅថ្ងៃ២៤ ខែសីហា ឆ្នាំ ១៩៦៩ នៅឈាបនដ្ឋាន វត្តឧណ្ណាលោម ក្រុងភ្នំពេញ . . . . ៨៨៦

១០— ពិធីប្រគេនព្រះរាជអំណោយរបស់សម្ដេចឪ ថ្វាយចំពោះសម្ដេចព្រះពោធិវង្ស . ៨៩៤

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ៛

# ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យដុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា • |

ប. ព

# មហាសីល

លោក ប៉ូ ប៊ូ រៀបរៀង

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសម-ណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ គឺចិញ្ចឹមជីវិតខុស ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ៗ គឺ សាស្ត្រា (ក្បួន) និយាយអំពីអវយវៈខ្លះ ទាយនិមិត្ត គឺហេតុខ្លះ ឧត្បាតគឺធ្លាក់ចុះនៃហេតុធំៗ មានរន្ទះបាញ់ជាដើមខ្លះ ទាយយល់សប្តិខ្លះ ទាយលក្ខណៈខ្លះ ទាយវត្ថុដែលកណ្តុរកាត់(មានសំពត់ជាដើម)ខ្លះ និយាយអំពីការបូជាដោយភ្លើងខ្លះ និយាយអំពីការបូជាដោយវែកខ្លះ និយាយអំពីការបូជាដោយអង្កាមខ្លះ និយាយអំពីការបូជាដោយកុណ្ឌកខ្លះ និយាយអំពីការបូជាដោយអង្ករខ្លះ និយាយអំពីការបូជាដោយ

ទឹកដោះពរខ្លះ និយាយអំពីការបូជាដោយប្រេងខ្លះ និយាយអំពីការបូជាដោយមាត់[១]ខ្លះ និយាយអំពីការបូជាដោយឈាមខ្លះ វិជ្ជាសម្រាប់ទាយនូវអវយវៈខ្លះ វិជ្ជាសម្រាប់ទាយភូមិឋានខ្លះ វិជ្ជាសម្រាប់ទាយទីស្រែចម្ការខ្លះ វិជ្ជាស្គាល់ព្រៃខ្មោចខ្លះ វិជ្ជាចាប់ខ្មោចខ្លះ វិជ្ជាសម្រាប់ការពាររក្សាភូមិផ្ទះខ្លះ វិជ្ជាស្តោះពស់[២]ខ្លះ វិជ្ជារក្សាពិសខ្លះ វិជ្ជាស្តោះខ្ទួយទិចខ្លះ វិជ្ជាស្តោះកណ្តុរខាំខ្លះ វិជ្ជាសម្រាប់ទាយសម្រែកសត្វស្លាបខ្លះ វិជ្ជាសម្រាប់ទាយសម្រែកក្អែកខ្លះ វិជ្ជាសម្រាប់ទាយអាយុខ្លះ វិជ្ជាសម្រាប់ពក់ព័ន្ធនូវសរខ្លះ វិជ្ជាសម្រាប់មើលនូវស្នាមជើងម្រឹគ គឺសត្វជើង ៤ ទាំងអស់ខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកការចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចម្រើនពួកមួយបរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ៗ គឺការទាយលក្ខណៈកែវមណីខ្លះ ទាយលក្ខណៈសំពត់ខ្លះ ទាយលក្ខណៈដំបងឬឈើច្រត់ខ្លះ ទាយលក្ខណៈគ្រឿងសាស្ត្រាខ្លះ ទាយលក្ខណៈដាវ

---

១- អដ្ឋកថា ថា បាយមាំទាំងរួមនព្រះជាក្នុងរើយ បោះចោលក្នុងភ្លើង ឬ សូត្ររបៀបអ្នកបាយបេះ ។ ២- វិជ្ជាមើលសត្វពិសចឹកសំលាប់ ឬហេតុសំ ។

ខ្លះ ទាយលក្ខណៈសេះខ្លះ ទាយលក្ខណៈដំរីខ្លះ ទាយលក្ខណៈអាវុធខ្លះ ទាយលក្ខណៈស្ត្រីខ្លះ ទាយលក្ខណៈបុរសខ្លះ ទាយលក្ខណៈក្មេងប្រុសខ្លះ ទាយលក្ខណៈក្មេងស្រីខ្លះ ទាយលក្ខណៈខ្ញុំប្រុសខ្លះ ទាយលក្ខណៈខ្ញុំស្រីខ្លះ ទាយលក្ខណៈដំរីខ្លះ ទាយលក្ខណៈសេះខ្លះ ទាយលក្ខណៈក្របីខ្លះ ទាយលក្ខណៈគោឧសភខ្លះ ទាយលក្ខណៈគោខ្លះ ទាយលក្ខណៈពពែខ្លះ ទាយលក្ខណៈកែះខ្លះ ទាយលក្ខណៈមាន់ខ្លះ ទាយលក្ខណៈចាបឬក្រួចខ្លះ ទាយលក្ខណៈរូបគំនូរឬគ្រឿងប្រដាប់ធ្វើដោយរូបទន្សងខ្លះ ទាយលក្ខណៈគ្រឿងប្រដាប់ ឬ កំពូលផ្ទះខ្លះ ទាយលក្ខណៈរូបគំនូរ ឬ គ្រឿងប្រដាប់ធ្វើដោយរូបអណ្តើកខ្លះ ទាយលក្ខណៈម្រឹគ គឺសត្វជើង ៤ ទាំងអស់ខ្លះ ។ ភិក្ខុជាអ្នកវៀរចាក មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ។ គឺទាយការលើកទ័ពថា ព្រះរាជាគួរស្តេចចេញទៅ ( ក្នុងថ្ងៃនោះ ) ព្រះរាជាគួរស្តេចត្រឡប់មកវិញ ( ក្នុងថ្ងៃនោះ ) ព្រះរាជាខាងក្នុងនឹងរុករានចូលទៅ ព្រះរាជាខាងក្រៅនឹងថយចេញទៅ ព្រះរាជាខាងក្រៅនឹងរុក

រានចូលមក ព្រះរាជាខាងក្នុងនឹងថយចេញទៅ ព្រះរាជាខាងក្នុងនឹងមានជ័យជម្នះ ព្រះរាជាខាងក្រៅនឹងបរាជ័យ ព្រះរាជាខាងក្រៅនឹងមានជ័យជម្នះ ព្រះរាជាខាងក្នុងនឹងបរាជ័យ ព្រះរាជាអង្គនេះនឹងមានជ័យជម្នះ ព្រះរាជាអង្គនេះនឹងបរាជ័យ ។ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ។ គឺការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានចន្ទគ្រាះ នឹងមានសូរ្យគ្រាះ នឹងមាននក្សត្រគ្រាះ គឺផ្កាយព្រះគ្រោះដើររួមចូលគ្នា ឬដើររំលងព្រះអាទិត្យ ព្រះចន្ទ ឬផ្កាយណាមួយ ព្រះចន្ទព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា ព្រះចន្ទព្រះអាទិត្យនឹងដើរខុសផ្លូវគ្នា ផ្កាយទាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា ផ្កាយទាំងឡាយនឹងដើរខុសផ្លូវគ្នា នឹងមាន ឧក្កាបាត[1] នឹងកើតមានកម្តៅក្នុងទិស នឹងមានការកម្រើកផែនដី នឹងមានផ្គរលាន់ (ឥតមាន

---

១ ក្នុងសារត្ថប្បកាសនាដីកាថា កាលបើអាកាសមានខ្យល់ទង្គិចគ្នាខ្លាំង ក៏កើតអានពន្លឺរស្មីដូចជាពន្លឺប្រទីបធ្លាក់ចុះមកអំពីអាកាស ហៅថាឧក្កាបាត ។

ភ្លៀង ) ព្រះចន្ទព្រះអាទិត្យផ្កាយនឹងរះឡើង ឬលិចទៅវិញនឹងសៅហ្មង ឬផូរផង់ ចន្ទគ្រាះនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ សូរ្យគ្រាះនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ នក្សត្រគ្រាះ នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទនឹងព្រះអាទិត្យដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទនឹងព្រះអាទិត្យដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ឧក្កាបាតនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ការក្តៅក្នុងទិសនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ការកម្រើកផែនដីនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ផ្គរលាន់ (ឥតមានភ្លៀង) នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទព្រះអាទិត្យ នឹងផ្កាយរះឡើង លិចទៅវិញ សៅហ្មងឬផូរផង់នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ភិក្ខុជាអ្នកវៀរចាក មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ។ គឺការទាយថា (ក្នុងឆ្នាំនោះ) នឹងមានភ្លៀងធ្លាក់ស្រួល នឹងមានភ្លៀង

ធ្លាក់មិនស្រួល នឹងមានបាយសម្បូណ៌ នឹងមានបាយក្រ នឹងមានសេចក្ដីក្សេមក្សាន្ត នឹងមានភ័យ នឹងមានរោគ នឹងមិនមានរោគ ការកាប់ដោយដៃទទេ ការកាប់ដោយវិធីខព្វន្ត កាប់បូក(១)កាព្យឃ្លោង គម្ពីរលោកាយតៈ ៗ ភិក្ខុជាអ្នកវៀរចាក មិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរ-ច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជា នោះតើដូចម្ដេចខ្លះ ៗ គឺវិធីរៀបអាវាហមង្គលខ្លះ វិធីរៀបវិវាហមង្គលខ្លះ វិធីធ្វើឲ្យព្រមព្រៀងគ្នា(សេហ៍)ខ្លះ វិធីធ្វើឲ្យព្រាត់ប្រាសគ្នា(បង់ចំណែង) ខ្លះ វិធីប្រមូលទ្រព្យខ្លះ វិធីប្រកបជំនួញខ្លះ វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរីខ្លះ វិធីធ្វើឲ្យស្អប់គ្នាខ្លះ វិធីធ្វើគភ៌ដែលបម្រុងវិនាសមិនឲ្យវិនាសខ្លះ វិធីចងអណ្ដាតឲ្យរឹងដោយមន្តខ្លះ វិធីចងចង្កាឲ្យរឹងខ្លះ វិធីសូត្ររៀនដើម្បីផ្លាស់ប្ដូរដៃខ្លះ វិធីសូត្ររៀនដើម្បីមិនឲ្យឮសំឡេងដោយត្រចៀកខ្លះ ប្រស្នាកញ្ចក់ គឺមន្តខាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ហើយសួរប្រស្នាខ្លះ ប្រស្នាកុមារី

---

១ អដ្ឋកថា ថា ការកាប់នេះ បើស្ទាត់ដល់បុគ្គលណា បុគ្គលនោះ កាលបើឃើញដើមពេលី ក៏អាចនឹងដឹងថា ពេលីនោះមានស្លឹកប៉ុណ្ណោះៗ បាន ។

គឺមន្តបញ្ចូលទេវតាក្នុងសរីរៈ នៃកុមារីហើយសួរប្រស្នាខ្លះ ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈ នៃទាសីហើយសួរប្រស្នាខ្លះ វិធីបម្រើព្រះអាទិត្យខ្លះ វិធីបម្រើមហាព្រហ្មខ្លះ វិធីបញ្ចេញភ្លើងអំពីមាត់ដោយមន្តខ្លះ វិធីហៅសិរីឲ្យស្ថិតក្នុងសរីរៈខ្លះ ។ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើន ពួកមួយបរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជាមានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ។ គឺការបន់ស្រន់ខ្លះ ការលាបំណន់ខ្លះ ធ្វើមន្តសម្រាប់ការពារបិសាចខ្លះ ធ្វើមន្តសម្រាប់ការពារផ្ទះខ្លះ ធ្វើខ្ទើយឲ្យដូចជាបុរសខ្លះ ធ្វើបុរសឲ្យដូចជាខ្ទើយខ្លះ ធ្វើពិធីសង់ផ្ទះលើទីដីដែលមិនធ្លាប់បានធ្វើខ្លះ ធ្វើពលិកម្មនៅលើទីដីដែលសង់ផ្ទះខ្លះ ជម្រះមុខឲ្យស្អាតដោយទឹកឲ្យគេខ្លះ បន្តក់ប្រសិទ្ធិឲ្យគេខ្លះ បូជាភ្លើងឲ្យគេខ្លះ ធ្វើថ្នាំសម្រាប់ឲ្យក្អួតខ្លះ ធ្វើថ្នាំបញ្ចុះខ្លះ ធ្វើថ្នាំកម្ចាត់បង់នូវទោសខាងលើខ្លះ ធ្វើថ្នាំកម្ចាត់បង់នូវទោសខាងក្រោមខ្លះ ធ្វើថ្នាំកម្ចាត់បង់នូវទោសក្នុងក្បាលខ្លះ ស្ងោរប្រេងសម្រាប់បន្តក់ត្រចៀកខ្លះ ធ្វើថ្នាំសម្រាប់ស្អំភ្នែកខ្លះ ធ្វើថ្នាំសម្រាប់ហិតខ្លះ ធ្វើថ្នាំសម្រាប់លាបបង្អាត់ខ្លះ ធ្វើថ្នាំត្រជាក់សម្រាប់ស្រលាបខ្លះ ធ្វើវេជ្ជកម្មក្យះភ្នែកខ្លះ

ធ្វើពេទ្យវះខ្លះ ធ្វើពេទ្យរក្សាក្មេងខ្លះ ដាក់ថ្នាំក្រោយឲ្យជួយកម្លាំងថ្នាំមុនខ្លះ លាងថ្នាំដើមចេញ(១) ខ្លះ ។ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

បពិត្រមហារាជ ភ័យណា ដែលគប្បីកើតឡើង ព្រោះសេចក្តីសង្រួមក្នុងសីល ភិក្ខុនោះឯងបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ។ បពិត្រមហារាជ ប្រៀបដូចជាភ័យណា ដែលគប្បីកើតឡើងអំពីសត្រូវ ក្សត្រិយដែលបានមុទ្ធាភិ-សេក (២) ហើយ កម្ចាត់បង់នូវពួកសត្រូវអស់ហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ដូចម្តេចមិញ, បពិត្រមហារាជ ភ័យណាដែលគប្បីកើតឡើង ព្រោះសេចក្តីសង្រួមក្នុងសីល ភិក្ខុអ្នកបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ដូច្នោះឯង ៗ ភិក្ខុនោះ បើបានប្រកបដោយសីលក្ខន្ធជារបស់ព្រះអរិយៈនេះហើយ រមែងសោយនូវសេចក្តីសុខ ដែលមិនមានទោសក្នុងសន្តានចិត្តនៃខ្លួន ៗ បពិត្រមហារាជ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។

---

១- អដ្ឋកថា ថា កាលបើមានដំបៅ ដាក់ថ្នាំមានថ្នាំផ្សារជាដើមក្នុងដំបៅនោះ កាលបើដំបៅស្រួលសមគួរហើយ ក៏នាំយកថ្នាំនោះចេញ ។

២ ព្រះរាជពិធីដែលគេការអភិសេកស្រោចទឹកលើព្រះសិរៈ ក្សត្រកាលបើឡើងសោយរាជ្យ ។

ចប់ មហាសីល ។

# ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរយ បណ្ឌិតោ ទាំង-ខាត់ រៀបរៀង

---

អ្នកផងទូទៅតែងនិយាយថា ៖ ពុទ្ធសាសនា ជាលទ្ធិសាសនា (Religion); ពាក្យថា Religion នេះ មិនគួរយកទៅប្រើសម្រាប់ហៅ ពុទ្ធសាសនាទេ ព្រោះពុទ្ធសាសនា ជាផ្លូវប្រតិបត្តិមិនពាក់ទងទៅខាងលទ្ធិ ទិដ្ឋិ (Dogme), វាទ (Doctrine) ដូចលទ្ធិសាសនា(Religion) ដទៃ ៗ នោះឡើយ ។ ក្នុងគម្ពីរពុទ្ធសាសនាមានពាក្យចោទឆ្លើយថា ៖" សាសនាមានប៉ុន្មាន ?

ឆ្លើយថាមាន២យ៉ាងគឺ ១-ពុទ្ធសាសនា ២-ពាហិរសាសនា ។ សាសនាទីពីរ គឺពាហិរសាសនា ( Religion ) សំដៅយកលទ្ធិសាសនាទាំងអស់ក្រៅពីពុទ្ធសាសនា ព្រោះសុទ្ធតែជាលទ្ធិ ទិដ្ឋិ ( Dogme ) វាទ ( Doctrine ) ។ល។ ឯពុទ្ធសាសនាជាបដិបទាផ្លូវប្រតិបត្តិជាកម្មនិយម ឬជាវិធីបំបាត់អវិជ្ជា តណ្ហា ឧបាទានកម្ម ។ សេចក្តីពិត អង្គព្រះសម្ពុទ្ធមិនមែនជាអ្នកបង្កើតពុទ្ធសាសនាទេ ព្រះអង្គគ្រាន់តែជាសាស្តា ព្រះអង្គគ្រាន់តែជាអ្នកឃើញធម៌ ហើយប្រកាសធម៌ដែលទ្រង់ត្រាស់ដឹងនោះ ។ ទ្រង់មិនដែលប្រកាសព្រះអង្គថាជាអ្វីដទៃ ក្រៅពីព្រះអង្គជា

មនុស្សឡើយ ពោលគឺទ្រង់ជាមនុស្សសុទ្ធសាធ ។ មេសាសនាដទៃច្រើនតែលើកខ្លួនថាជាទេវតា ជាអាទិទេពនៅឋានសួគ៌ ឬជាអវតារ នៃអាទិទេព កន្លែការបែងភាគទៅជារូបផ្សេង ១ ។ ព្រះអង្គជាមនុស្សហើយទ្រង់មិនដែលប្រកាសថា ព្រះអង្គមានអ្នកណា ឬទេវតាណា មានសក្តានុភាពចូលមកណែនាំព្រះអង្គឲ្យប្រកាសសាសនា ដូចសាសនាទាំងពួងទេ ។ ផលប្រសើរដែលទ្រង់បានសម្រេចអភិសម័យគឺការលុះធម៌ ការត្រាស់ដឹងធម៌ មិនមែនបានដោយឫទ្ធិអំណាចទេវតា ជួយផ្តល់ឲ្យបានសម្រេចទេ គឺទ្រង់បានសម្រេចដោយវីរិយភាពព្រះអង្គជាមនុស្ស ដោយបញ្ញាញាណព្រះអង្គជាមនុស្សពិតប្រាកដ ។ មនុស្សយើង បើគ្រាន់តែបានភាពជាមនុស្សប៉ុណ្ណឹង អាចលុះភាពនៃខ្លួនជា " ពុទ្ធ " បានឥតសង្ស័យឡើយ ។ មនុស្សគ្រប់រូប អាចប្រើសក្តានុភាពខ្លួន ជាមនុស្សឲ្យបានសម្រេចភាពជាព្រះពុទ្ធបាន ចាំបើមានបំណងមាំទីងមានវីរិយភាពធំ ។ ដូច្នេះ យើងអាចពោលបានថា អង្គព្រះសម្ពុទ្ធជាមនុស្សដោយប្រពៃមិនខុសតាសក្តីទេ ព្រោះព្រះអង្គទ្រង់បំពេញបារមីធម៌កន្លែមនុស្សភាព មិនមែនកន្លែទេវភាពឡើយ ហើយទ្រង់បានសម្រេចភាពជាមហាបុរសរតន៍ឆ្នើមបំផុត កន្លែបំណោមមនុស្សជាមេសាសនាធំ ១ កន្លែពិភពលោក ទាល់តែមនុស្សលោកពិលក្នែកមើលព្រះអង្គ ឃើញព្រះអង្គ ហើយសំគាល់ថា ទ្រង់ជាឧត្តមមនុស្ស ( Super humain ) ។

ការបានភាពនៃខ្លួនជាមនុស្សប្រសើរបំផុត (កិច្ចោ មនុស្សបដិលាភោ)។ មនុស្សជាម្ចាស់ខ្លួនឯង ឥតមានទេពតាណា ឬអំណាចអ្វីណាមួយប្រសើរជាងពលនាខ្លួនជាមនុស្សនេះទេ ។ មនុស្សម្នាក់ៗ ជាកោះទីពឹងរបស់ខ្លួន អត្តទីបោ =អ្នកណាជាសរណៈខ្លួនឯង ជាងខ្លួនឯង ? ព្រះសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា "ខ្លួនជាទីពឹងខ្លួន" មនុស្សម្នាក់ៗមិនត្រូវដើរទៅស្វែងរកសរណៈដទៃក្រៅពីខ្លួនទេ ។ កាលទ្រង់គង់ធរមាននៅឡើយ ព្រះសម្ពុទ្ធទ្រង់តែងទេសនាប្រៀនប្រដៅថា៖ ត្រូវកសាងខ្លួនដោយខ្លួនឯង (អត្តសម្មាបណិធិ) ហើយយកអានុភាពខ្លួនឯងទៅរំដោះទុក្ខ (មោក្ខ) ខ្លួនឯង ឲ្យរួចស្រឡះពីចំណងតណ្ហា ដោយវីរិយភាព និងបញ្ញាជារបស់ខ្លួនឯងជាមនុស្ស ។ ទ្រង់ផ្ដាំទុកទីបំផុតថា:(១) ចូលធ្វើប្រយោជន៍ខ្លួនឲ្យសម្រេចដោយក្ដីមិនប្រមាទ (អប្បមាទេន សម្បាទេថ) ឯពាក្យដែលអ្នកផងតែងពោលថា "ព្រះអង្គស្រង់សត្វ" នោះ គ្រាន់តែជាពាក្យពោលដោយន័យថា ព្រះអង្គត្រាស់ដឹងធម៌ ទេសនាបង្អុលប្រាប់ផ្លូវឲ្យសត្វដើរ គឺប្រៀនប្រដៅសត្វលោកឲ្យខំរៀនឲ្យចេះដឹង ហើយឲ្យដើរដោយខ្លួនឯង ព្រមទាំងធ្វើបានលុះមោក្សធម៌ ដោយខ្លួនឯងតែប៉ុណ្ណោះទេ ដោយពិត យើងត្រូវដើរដោយខ្លួនយើងគ្រប់គ្នា នឹងឲ្យព្រះអង្គស្រង់យើងដូចស្រង់មនុស្សលង់ទឹកដូចម្ដេចបាន ? តែមនុស្សលោក

---

១- មហាបរិនិព្វានសូត្រ ។

ចូលចិត្តឲ្យគេស្រង់ខ្លួនទាំងស្រកាក ដូចស្រង់មនុស្សលង់ទឹកកណ្ដាលទន្លេ ដូច្នោះឯង ។

តាមគោលការណ៍ មនុស្សម្នាក់ៗ ត្រូវទទួលខុសត្រូវដោយខ្លួនឯង ។ សេចក្ដីត្រង់នេះ ក្នុងពុទ្ធសាសនា ឃើញមានច្រើនកន្លែងណាស់ ទ្រង់តែងតែប្រទានសេរីភាពដល់សាវកព្រះអង្គ ។ ក្នុងមហាបរិនិព្វានសូត្រ ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរថា(១) : ។

–អានន្ទ ! ភិក្ខុសង្ឃ ត្រូវការអ្វីចំពោះតថាគតទៀត =(កឹ បនា-នន្ទភិក្ខុសង្ឃោ មយិ បច្ចាសីសតិ ) ។

អានន្ទ ធម៌ដែលតថាគតសំដែងប្រាប់ហើយ មិនមានក្នុង មិនមានក្រៅទេ បានសេចក្ដីថា ធម៌វិន័យនេះ មិនមែនជាអន្ដោក្ខតវាទ (Doctrine ésotérique )

មានអ្វីលាក់លៀមទុកក្រោយទៀតទេ =(ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ) ។

" អានន្ទ ! អាចរិយមុដ្ឋិ ក្នុងធម៌តថាគតមិនមានទេ បានសេចក្ដីថា ធម៌វិន័យនេះ មិនមែនបិទនៅក្នុងកណ្ដាប់ដៃអាចារ្យ គឺមិនមែនជាទិដ្ឋិ (Dogme) របស់អាចារ្យ និយាយក្រៅពីអាចារ្យមិនបាននោះទេ នត្ថានន្ទ តថាគតស្ស ធម្មេសុ អាចរិយមុដ្ឋិ ។

---

១- ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ សៀវភៅទី ១៦ ទំព័រ ២៣ ។

សេចក្ដីតទៅ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទៀតថា ៖

អានន្ទ! តថាគត មិនដែលបានគិតថា មិនត្រូវត្រួតត្រាសង្ឃមណ្ឌល ... ឬក៏សង្ឃមណ្ឌលត្រូវនៅក្រោមឱវាទតថាគតដូច្នេះក៏ទេដែរ ឥឡូវនេះ តថាគត គ្រាំគ្រាហើយ ចម្រើនហើយ ចាស់ហើយ កន្លងបច្ឆិមវ័យហើយ មានអាយុ ៨០ ឆ្នាំ ហើយ ។

សេរីភាពក្នុងការគិត ដែលព្រះអង្គទ្រង់ប្រទានដល់សាវកព្រះអង្គនេះ មិនដែលឮថាមានប្រាកដនៅក្នុងប្រវត្តិសាសនា នៃសកលលោកសោះឡើយ ។ សេរីភាពក្នុងការគិតនេះ មានប្រយោជន៍ណាស់ ព្រោះថាអត្តាធិនភាព (Emancipation) នៃមនុស្សលោក ឋិតនៅក្នុងអភិសម័យ (Réalisation) អរិយសច្ចធម៌ មិនមែននៅក្រោមការប្រោសប្រាណនៃព្រះអាទិទេព ឬអំណាចនៃបុគ្គលណាមួយសោះឡើយ ។ សេចក្ដីនេះ បើយើងមើលក្នុងគម្ពីរ ដែលជាពុទ្ធវចនៈ នឹងឃើញមានច្រើនអន្លើណាស់ ។

ក្នុងសម័យមួយ កាលព្រះសម្ពុទ្ធស្ដេចយាងទៅកាន់ចារិកក្នុងក្រុងកេសបុត្ត ក្នុងដែនកោសល មានប្រជាជនកាលាមៈ[1] ច្រើននាក់បានចូលមកក្រាបទូលសួរព្រះអង្គថា :

---

១- មើលកាលាមសូត្រ សេចក្ដីប្រែព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ថោង ពុទ្ធសាសនបណ្ឌិត្យ ។ អង្គុត្តរនិកាយ តិកនិបាត មហាវគ្គ សៀវភៅទី ៤១ ទំព័រ ២១៦ ។

សូមទ្រង់មេត្តាប្រោស ពួកតាបសឬសី ពួកព្រាហ្មណ៍ច្រើននាក់ ដែលបានចូលមកកាន់ក្រុងកេសបុត្តនេះ តែងតែទេសនា អួតសរសើរ លើកតម្កើងវាទៈរបស់ខ្លួនសឹងតែពល់គ្នា ហើយបន្តុះបង្អាប់វាទៈនៃសាស្តាដទៃ ៗ ថាមិនត្រឹមត្រូវ ៗ យើងខ្ញុំព្រះអង្គគ្រប់គ្នាមានសេចក្តីសង្ស័យ មានក្តីឆ្ងល់ថា តើបណ្តាពួកតាបសឬសី ពួកព្រាហ្មណ៍ទាំងនោះពួកណា និយាយត្រូវ ពួកណានិយាយខុស ៗ

កាលនោះព្រះសម្ពុទ្ធទ្រង់ប្រទានធម៌ទេសនា ដោយអនេកបរិយាយ ទ្រង់វិសជ្ជនា ដោះស្រាយប្រស្នានេះ ដោយពិស្តារ ៗ សេចក្តីដោះស្រាយបែបនេះ មានតែក្នុងពុទ្ធសាសនាមួយទេ មិនដែលមានប្រាកដទៅក្នុងប្រវត្តិសាសនាសកលលោកឡើយ ដូចសេចក្តីដែលអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ ដូចតទៅនេះ ៖

« ហៃកាលាមៈ ! អ្នកគួរមានក្តីសង្ស័យមែន អ្នកគួរកើតក្តីឆ្ងល់មែន ចំពោះប្រស្នាសង្ស័យដែលគួរឲ្យសង្ស័យនេះ ឥឡូវ ចូរប្រុងស្តាប់ដោយគោរពចុះ អ្នកទាំងឡាយកុំប្រព្រឹត្តអាការ ១០ យ៉ាងគឺ ៖

១- អនុស្សវា ការប្រកាន់ជឿ ដោយអាងពាក្យដែលឮតៗ គ្នា គឺមិនបានពិនិត្យពិចារណា រកហេតុផលទេ ដោយគ្រាន់តែជឿតាមៗ គ្នា ៗ

២- បរម្បរា ការប្រកាន់ជឿ ដោយអាងធ្វើតៗ គ្នា មិនដឹងដើម

មិនដឹងបុន ដូចជាកាន់ទំនៀមទម្លាប់ជាដើម ។

៣- ឥតិកិរា ការប្រកាន់ជឿ ដោយអាងថាបានឮមក ឬការប្រកាន់ជឿដោយអាងថា បានឮគេនិយាយមកយ៉ាងនេះ ដូចជាការប្រកាន់ជឿរឿងព្រេងជាដើម ។

៤- បិដកសម្បទា ការប្រកាន់ជឿ ដោយអាងថាពាក្យនេះសមនិងគម្ពីរដីកាយើងហើយ គឺអាងក្បួនតម្រាដូចគម្ពីរវេទជាដើម,

៥- តក្កហេតុ ការប្រកាន់ជឿ ដោយអាងហេតុ ឬអនុមាណដោយស្មានយកខ្លួនឯង ឃើញយ៉ាងណា ក៏កាន់យកយ៉ាងនោះ ,

៦- នយហេតុ ការប្រកាន់ជឿ ដោយអាងន័យគ្រវគ្រាន់កាត់តម្រុយផ្ទៀងផ្ទាត់យក សំគាល់យកសេចក្តីណាមួយដែលមានន័យប្រហែលគ្នាមកប្រកបហើយប្រកាន់ជឿតាមគ្នា,

៧- អាការបរិវិតក្កា ការប្រកាន់ជឿ ដោយអាងការត្រិះរិះនូវអាការៈគឺហេតុអ្វីដែលកើតឡើង តែមិនមែនជាការពិត ត្រិះរិះផ្គួងមើលទៅឃើញថា ពេញចិត្តខ្លួនយល់ថា ត្រឹមត្រូវហើយ ក៏ប្រព្រឹត្តកាន់តាមទៅ,

៨- ទិដ្ឋិនិជ្ឈានក្ខន្តិ ការប្រកាន់ជឿ ដោយអាងការចូលចិត្តគឺហេតុអ្វីមួយដែលមិនមែនជាការពិត តែត្រូវនឹងគំនិតដែលខ្លួនធ្លាប់គិតទុកមក ចូលចិត្តថាហេតុនោះល្អហើយ ពិតហើយ ក៏ប្រព្រឹត្តតាមហេតុ

ការណ៍នោះ ។

៩- ភព្វរូបតា ការប្រកាន់ជឿដោយអាងថា អ្នកនេះជាអ្នកចេះដឹង គួរតែយើងជឿកាន់តាម បានសេចក្ដីថា អ្នកណាមួយប្រសប់ប៉ុនប៉ាវខាងសម្ដីមាត់តែងពាក្យអ្នកនិយាយនេះមិនពិតទេ គ្រាន់តែពិរោះស្ដាប់ ហើយប្រកាន់ជឿតាមអ្នកនោះទៅ ។

១០-សមណោ នោ គរុ ការប្រកាន់ជឿដោយអាងថា សមណៈនេះជាគ្រូយើង គួរយើងកាន់យកតាម ពាក្យលោក គឺការប្រកាន់ជឿតាមលទ្ធិគ្រូខ្លួន បើទុកជាលទ្ធិគ្រូខ្លួនខុសក៏ដោយ ក៏ចេះតែប្រកាន់ជឿតាមទាំងអស់ ពទៈអ្នកដទៃដែលមិនមែនជាគ្រូខ្លួន តែត្រឹមត្រូវ មិនប្រកាន់ជឿតាមទេ ។

ឱកាលាមៈ! អ្វីមួយដែលអ្នកបានឃើញខ្លួនឯងថា នេះជាកុសល ជារបស់ប្រសើរ អ្នកចូរប្រព្រឹត្តតាមចុះ ! អ្វីមួយដែលអ្នកបានឃើញខ្លួនឯងថា ជាអកុសលជាធម៌លាមក ខុសគន្លងធម៌ អ្នកគួរលះបង់ចោលទៅ កុំប្រព្រឹត្តតាមឡើយ ។

សាវកព្រះពុទ្ធ វៀរអាការ ១០ យ៉ាងនេះ លោកប្រើសទ្ធា និងបញ្ញាពិចារណារកហេតុផល ទើបជឿកាន់តាម ប្រតិបត្តិតាម ។

ក្នុងគម្ពីរដែលជាពុទ្ធវចនៈ មានសេចក្ដីដាស់តឿន ឲ្យសាវកព្រះអង្គចេះគិតប្រើគំនិតគឺការប្រទានសេរីភាព ក្នុងការគិតមានច្រើនអន្លើណាស់

ដូចព្រះតម្រាស់ចំពោះភិក្ខុទាំងឡាយថា[១] ភិក្ខុទាំងឡាយ សាវក តថាគត ត្រូវពិនិត្យមើលពាក្យតថាគត សាវកតថាគតត្រូវច្បាំងចំពោះសច្ចធម៌តថាគតដែលជាគ្រឿងឲ្យឃើញត្រឹមត្រូវសិន សឹមប្រតិបត្តិតាម ដូចជាយើងនិយាយថា "ឲ្យឃើញសឃើញខ្មៅ" សិន ។

ក្នុងពុទ្ធសាសនា វិចិកិច្ឆា សេចក្ដីសង្ស័យ (Doute, Doubt) នេះជាធម៌មួយ នៅក្នុងនីវរណធម៌[២] (Empêchements, Hindrances) ទាំង ៥ ប្រការ ជាធម៌រាំងខ្ទប់មិនឲ្យយល់អរិយសច្ចធម៌ ឬ មិនឲ្យកើតសេចក្ដីចម្រើនគ្រប់ប្រការ ។ តែ វិចិកិច្ឆានេះ មិនមែនជាអំពើបាបកម្មទេ ព្រោះថាមិនមានទិដ្ឋិដែលត្រូវប្រើជំនឿ សទ្ធា នៅក្នុងពុទ្ធសាសនាឡើយ ។ ក្នុងពុទ្ធសាសនា មិនមានអំពើបាបកម្ម (Péché, sin) ដូចនៅក្នុងលទ្ធិសាសនា (Religion) ដទៃ ១ ទេ ។ ឯមូល (Racine, Root) ឬ ឫសគល់នៃបាបកម្មនោះ គឺអវិជ្ជា (Ignorance) និង

---

១- មជ្ឈិមនិកាយ មូលបណ្ណាសក វិមំសកសូត្រ សៀវភៅទី ២២ ទំព័រ ៣៣៧ ។

២- នីវរណធម៌ (Empêchements, Hindrances) ៥ ប្រការ គឺ :

១- កាមច្ឆន្ទ (La convoitise sensuelle, Sensual Lust) ; ២- ព្យាបាទ (La malveillance, Ill-will) ; ៣- ថីន មិទ្ធ (La torpeur physique et mentale et la langueur, physical and mental torpor and languour) ; ៤- ឧទ្ធច្ច កុក្កុច្ច (L'inquiétude et le tracas, Restlessness and worry); ៥- វិចិកិច្ឆា (La doute, Doubt) ។

មិច្ឆាទិដ្ឋិ (Vues fausses, False views) ។ នេះជាធម៌ដែលគេប្រកែកជជែកមិនបាន បើមានវិចិកិច្ឆា មានការងឿងឆ្ងល់ មានសន្ទិះសង្ស័យហើយសេចក្តីចម្រើនពិតជាមិនអាចកើតឡើងបានទេ ។ មួយទៀត ធម៌នេះក៏គេប្រកែកជជែកមិនបានដែរថា គេមិនត្រូវទុកវិចិកិច្ឆានេះ ឲ្យនៅយូរលង់ទេ បើគេមិនយល់ ឬ បើគេមិនឃើញច្បាស់ ។ បើគេចង់ឲ្យសេចក្តីចម្រើនដើរលឿនទៅមុខ ត្រូវតែបំបាត់វិចិកិច្ឆានេះចោលចង់ឲ្យស្រឡះ តែដើម្បីនឹងបំបាត់វិចិកិច្ឆា ក៏ត្រូវតែគេឃើញច្បាស់សិនដែរ ។

តែសេចក្តីនេះ មិនមែនត្រូវយល់ថា គេមិនត្រូវឲ្យមានក្តីសង្ស័យ ឬ មិនត្រូវឲ្យមានជំនឿនោះទេ បើគ្រាន់តែនិយាយថា “ ខ្ញុំជឿ ” ក៏មិនមែនបានសេចក្តីថា “ យល់ ឬ ឃើញ ” នោះទេ ។ សេចក្តីនេះ ប្រៀបដូចជាសិស្សគណិតសាស្ត្រ ដែលគិតចំណោទគណិតសាស្ត្រ ជួនកាលខ្លះតែងមានចំណុចមួយ ដែលសិស្សនេះមិនដឹងធ្វើដូចម្តេចនឹងឲ្យទៅមុខរួច ឬ ខ្លួនលង់ទ្រនេសនៅក្នុងវិចិកិច្ឆា ឬ ក្នុងការងឿងឆ្ងល់ដែរ ។ ដរាបណាសិស្សនេះ នៅតែមានវិចិកិច្ឆា ដរាបនោះ សិស្សនេះនៅតែធ្វើទៅមុខមិនបានទេ ។ បើសិស្សនេះ ចង់ធ្វើឲ្យទៅមុខរួច លុះត្រាតែសិស្សនេះដោះវិចិកិច្ឆានេះបានសិន ទើបទៅមុខបាន ។ ក្នុងករណីនេះ នាងនេះគ្រូបាយកេចជួយឲ្យសម្រេចបានដែរឬទេ ? បើ

គ្រាន់តែនិយាយថា "ខ្ញុំជឿ" ឬ "ខ្ញុំមិនសង្ស័យទេ" នេះទៀត ក៏មិនអាចដោះស្រាយចំណោទបានពិតប្រាកដទៀត បើទុកជាបង្ខំជឿអ្វីមួយ ហើយព្រមទទួលយកអ្វីមួយនោះ ដោយឥតបានយល់សោះ នេះអាចទៅបានដែរ បានខាងវិស័យការរដ្ឋ តែមិនទុកជាបានការខាងវិស័យធម្មៈ ឬ ខាងវិស័យចំណេះដែលមានហេតុផលពុំបានឡើយ ។

ព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាប្រដៅជានិច្ចថា ត្រូវបំបាត់ វិចិកិច្ឆា ហៅឲ្យប្រឡះបង់ពេលមុនបរិនិព្វាន ព្រះអង្គត្រាស់ហើយត្រាស់ទៀត ឲ្យព្រះសង្ឃសាវកសាកសួរព្រះអង្គ កុំឲ្យទុកវិចិកិច្ឆា នេះ ចំពោះធម្មវិន័យព្រះអង្គ ដើម្បីកុំឲ្យកើតវិប្បដិសារីធម៌ទៅថ្ងៃក្រោយ ហើយមិនអាចកំចាត់វិចិកិច្ឆា នេះបាន ។ តែកាលនោះ ព្រះសង្ឃសាវកតាំងនៅក្នុងតុណ្ហីភាពគ្រប់អង្គ ទើបទ្រង់ត្រាស់ទៀតថា(១) ៖ ។

ភិក្ខុទាំងឡាយ ! បើអ្នកទាំងឡាយ មានគរុគារវធម៌ មិនអាចហ៊ានលើកប្រស្នាឡើងសួរទេ ឲ្យសទ្ធិវិហារិកណាម្នាក់ចូលមកសួរតថាគតចុះ កុំទុកឲ្យមាន វិចិកិច្ឆា នេះ តទៅទៀត ។

សេចក្ដីខាងលើនេះ អ្នកសិក្សាប្រវត្តិសាស្ត្រលទ្ធិសាសនាគោតមស្ងើចក្រៃលែងចំពោះអង្គព្រះសម្ពុទ្ធ ដែលទ្រង់មានព្រះហឫទ័យទូលាយ ទ្រង់មិនមែនព្រះពជទានត្រឹមតែសេរីភាពក្នុងការគិតតែប៉ុណ្ណោះទេ ទ្រង់ប្រកប

---

១- ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ សៀវភៅទី ១៦ ទំព័រ ២១៣ តទៅ ។

ដោយខន្តីធម៌ មេត្តាប្រោសសន្តោសព្រះសង្ឃសាវកទៀតផង ។ សម័យមួយ នៅស្រុកនាលន្ទា និគណ្ឋនាដបុត្ត ដែលយើងបានស្គាល់ថា តិត្ថង្ករ មហាវីរ បានបញ្ជូនសិស្សជំនិតម្នាក់ ជាគហបតី មានទ្រព្យសម្បត្តិស្តុកស្តម្ភ ឈ្មោះឧបាលិ(១) ឲ្យទៅគាល់អង្គព្រះសម្ពុទ្ធ ដើម្បីដេញដោលសួរព្រះអង្គពីទ្រឹស្តីកម្ម ធ្វើព្រះអង្គឲ្យចាញ់យ៉ាងអាម៉ាស់មុខ ។ ទីបំផុត បុច្ឆាវិសជ្ជនា ឧបាលិគហបតីប្រកាសជាឧឡារិកថា កាយទណ្ឌ វចីទណ្ឌ មនោទណ្ឌ ជាប្រវចនៈ និគណ្ឋ នាដបុត្ត មិនប្រសើរស្មើដោយ ពុទ្ធវចនៈ កាយកម្ម វចីកម្ម មនោកម្ម នោះឡើយ ហើយសូមថ្វាយខ្លួនជាឧបាសកចូលសាសន៍ពុទ្ធរតន៍ បានដល់ត្រៃសរណគមន៍ ។ កាលនោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទូន្មានឧបាលិគហបតី ឲ្យពិចារណាទុកមុនឲ្យបានម៉ត់ចត់សិន ព្រោះការពិចារណាម៉ត់ចត់ ទើបសម្រេចចិត្ត ជាការប្រសើរបំផុត តែឧបាលិគហបតី ទទូចសូមថ្វាយខ្លួនជាឧបាសក ទើបទ្រង់ប្រទានដំបូន្មាន សុំឧបាលិគហបតីឲ្យគោរពគ្រូដើមរបស់ខ្លួនដូចដើមដដែល ។

បណ្ដា មេលទ្ធិសាសនាទាំងអស់ក្នុងលោក ព្រះសម្ពុទ្ធជាអគ្គបុគ្គលប្រសើរលើសក្នុងការប្រទានសេរីភាព ប្រទានខន្តីមេត្តាប្រោសប្រ-

១- មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ឧបាលិវាទសូត្រ សៀវភៅទី ២៣ ទំព័រ ៩ [illegible]

ណី ប្រមានការយោគយល់ទៅវិញទៅមក ។ ធម៌ទាំងនេះ ជាប្រពៃណីពុទ្ធសាសនាវៀងរហូតមក ។ ព្រះបាទអសោកមហារាជ ជាឧបាសកដ៏ប្រសើរ បានយកធម៌ជាប្រពៃណីពុទ្ធសាសនា នេះមកប្រតិបត្តិក្នុងរជ្ជកាលព្រះអង្គ មានសេចក្តីប្រាកដនៅក្នុងព្រះរាជប្រកាសព្រះអង្គស្រាប់ដូចសេចក្តីតទៅនេះ (១) ៖

«អ្នកគ្រប់គ្នា មិនគួរលើកតម្កើងសរសើរតែលទ្ធិសាសនារបស់ខ្លួន ហើយប្រទូស្តលទ្ធិសាសនាដទៃទេ ត្រូវគោរពលទ្ធិសាសនាដទៃៗ ឲ្យដូចជាខ្លួនគោរពរបស់ខ្លួនដែរ ។ ការគោរពលទ្ធិសាសនាដទៃៗ ឈ្មោះថា ជួយលើកតម្កើងហើយជួយពង្រីកលទ្ធិសាសនារបស់ខ្លួនផង ហើយធ្វើប្រយោជន៍ចំពោះលទ្ធិសាសនាដទៃផងដែរ បើមិនដូច្នោះទេ ឈ្មោះថាជីករណ្តៅកប់លទ្ធិសាសនារបស់ខ្លួនឲ្យកប់បាត់ទៅ ព្រមទាំងធ្វើលទ្ធិសាសនាដទៃៗ ឲ្យវិនាសទៅផងដែរ ។ អ្នកណាមួយគោរពតែលទ្ធិសាសនារបស់ខ្លួន ហើយប្រទូស្តលទ្ធិសាសនាដទៃ គ្រាន់តែបាន ឈ្មោះថា ធ្វើឲ្យគេឯងបានដឹងថាខ្លួនមានភក្តីភាពចំពោះលទ្ធិសាសនារបស់ខ្លួន ដោយគិតថា «អាត្មាអញបានលើកតម្កើងលទ្ធិសាសនារបស់ខ្លួនហើយ» ។ គំនិតនេះខុសស្រឡះទេ ការប្រព្រឹត្តិនេះ ឈ្មោះថាបំផ្លាញលទ្ធិសាសនារបស់ខ្លួនដោយឥតសង្ស័យឡើយ ។ ដូច្នេះ សាមគ្គី

១- ព្រះរាជប្រកាស ព្រះបាទអសោកមហារាជ លេខ ១២ ។

ជាគុណធម៌ប្រសើរណាស់ សូមឲ្យអ្នកគ្រប់គ្នាស្ដាប់ ហើយសូមមេត្តាស្ដាប់ព្រះនៃលទ្ធិសាសនាដទៃផង„ ។

ការសន្ដោសដោយសមានចិត្តនេះ ជាគុណធម៌ប្រសើរណាស់ ប្រសិនបើយកធម៌នេះមកអនុវត្តសម្រាប់ជាប្រយោជន៍ទូទៅ មិនមែនបានផលចំពោះតែលទ្ធិសាសនាទេ សូម្បីទុកជាច្បាប់សម្រាប់ប្រទេសជាតិនយោបាយ សង្គមកិច្ច ឬសេដ្ឋកិច្ច ក៏នឹងតែតែបានផលប្រសើរណាស់ទៅទៀត ។

ខន្តីធម៌និងមេត្តាប្រោសប្រាណនេះ ជាឧត្តមគតិប្រសើរខ្ពង់ខ្ពស់ណាស់ ទុកជាវប្បធម៌និងអរិយធម៌នៃពុទ្ធសាសនា ចាប់ដើមតាំងពីពុទ្ធសាសនាកើតឡើង ។ ការបៀតបៀន (ហិង្សា = La violence) ទោះជាបែបណាក៏ដោយ ឬទោះជាប្រើលេសមកបន្ទំក៏ដោយ ក៏សុទ្ធតែផ្ទុយនិងពុទ្ធវចនៈទាំងអស់ ។ ដោយពុទ្ធសាសនាមានលក្ខណៈ ប្រាកដដូច្នេះហើយ បានជាពិភពលោកមិនបានឃើញមានសង្គ្រាមការកាប់សម្លាប់គ្នាទុកជាឧទាហរណ៍ មានការស្រក់ឈាមមួយដំណក់ដោយការប្រកាសពុទ្ធសាសនា ឬផ្សាយពុទ្ធសាសនានេះឡើយ នៅក្នុងប្រវត្តិសាស្ត្រពុទ្ធសាសនាដ៏វែងប្រមាណជា ២៥០០ ឆ្នាំ ដែលកន្លងទៅនេះ ។ សព្វថ្ងៃនេះ ពុទ្ធសាសនាផ្សាយទូទៅពេញទ្វីបអាស៊ី ហើយត្រូវជ្រាបរហូតទៅដល់ទ្វីបអឺរ៉ុបនិងអាមេរិកទៀត មានអ្នកចូលកាន់សាសនាពុទ្ធរតន៍ប្រមាណ

ជាប្រាំរយលាននាក់ ។

មានប្រស្នាមួយទៀតកើតឡើងហើយ ។ គេតែងចោទសួរថា ពុទ្ធសាសនាជាលទ្ធិសាសនា (Religion) ឬជាទស្សនវិជ្ជា (Philosophie ? មានអ្នកខ្លះ ឆ្លើយដែរ ឆ្លើយដោយអាការ ដូចអ្នកទស្សនវិទូ គេឆ្លើយថា ពុទ្ធសាសនាមិនមែនជាលទ្ធិសាសនា (Religion) ទេ ទំនងជាទស្សនវិជ្ជា (Philosophie) ក៏មិនមែនទៀត ពុទ្ធសាសនាគឺ មិនមែនជាអ្វីទាំងអស់ ឬ ទំនងជាជាអ្វីដូចអ្នកគិតនោះក៏មិនមែនដែរ ពុទ្ធសាសនា គឺពុទ្ធសាសនា ។ សំនួរនេះ ជាការដាក់ស្លាកឬដាក់ឈ្មោះហៅឲ្យពុទ្ធសាសនា មិនជាការអ្វីធំឬចាស់ខុសទេ ហៅថាដូចម្ដេចក៏បាន ពុទ្ធសាសនាមិនយកចិត្តទុកដាក់ចំពោះស្លាកឬឈ្មោះ ដែលគេដាក់ឲ្យខ្លួននោះទេ ។ ស្លាកឬឈ្មោះ គ្រាន់តែជានាមបញ្ញត្តិ ស្លាកឬឈ្មោះដែលគេសន្មតថា „ពុទ្ធសាសនានេះ ក៏មិនមានការសំខាន់អ្វីពេកណាស់ដែរ ។ នាមដែលគេដាក់ឲ្យនេះ មិនមែនជាការសារវន្តទេ ។

មានអ្វីក្នុងឈ្មោះ ព្រះហើយពីកេះ ?
ដូចផ្កាកុលាប បើគេហៅអ្វី
កុលាបពិសី ក្រអូបដដែល ។

សច្ចធម៌មិនមានឈ្មោះទេ គឺមិនមែនជាឈ្មោះ "ពុទ្ធ គ្រិស្ត ហិណ្ឌូ មុស្លីម ឡៅត្ស៊ី ខុងត្ស៊ី ឈិនតូ „ ទេ ។ សច្ចធម៌មិនមែនជាឯកជនភាព

(Monopole) របស់ជនណាតែម្នាក់ទេ ។ ស្លាក ឬ យីហោថា និកាយនេះ និកាយនោះ ជានីវរណធម៌ ករាំងបិទមិនឲ្យយល់សច្ចធម៌បាន ហើយបង្កើតជាឧបក្កិលេសដល់សន្តានចិត្តមនុស្ស ធ្វើចិត្តឲ្យសៅហ្មងទៀត ។

សេចក្តីពិតធម៌នេះមិនមែនផ្តល់សេចក្តីនាសឲ្យតែខាងលទ្ធិសាសនា ឬខាងបញ្ញាតែប៉ុណ្ណោះទេ ធ្វើឲ្យចូលហូតទៅដល់ការទាក់ទងរវាងមនុស្ស និងមនុស្សទៀតផង ឧបមាថា យើងជួបមនុស្សម្នាក់យើងមិនមែនគ្រាន់តែទុកគេជាជាមនុស្សប៉ុណ្ណឹងទេ យើងថែមទាំងទៅដាក់ស្លាក ឬ យីហោឲ្យគាត់ទៀតថាគេ ជាអង់គ្លេស ជាបារាំង ជាអល្លឺម៉ង់ ជាអាមេរិកកាំង ឬជាជីហ្វ ម្ល៉ោះហើយចិត្តយើងក៏ជាប់នៅក្នុងស្លាក ឬ យីហោនោះឯង ។ ជួនកាលមនុស្សដែលយើងស្គាល់នោះ មិនមែនជាជាតិដែលយើងដាក់ស្លាក ឬ យីហោឲ្យនោះផង ។.

មនុស្សលោកចូលចិត្តដាក់ស្លាក ឬ យីហោណាស់ ដាក់រហូតទៅដល់គុណធម៌ដ៏ប្រសើររបស់មនុស្សលោកទៀត ។ នេះជាសន្តានចិត្តនៃមនុស្សសាមញ្ញទូទៅក្នុងពិភពលោក ។ ដូច្នេះហើយ បានជាយើងឃើញមានស្លាកឬយីហោ នៃការឲ្យទាន (Charité) គេថា នេះទានពុទ្ធ ទានគ្រិស្ត ទានហិណ្ឌូ ហើយមើលងាយទាននៃជនទាំងនោះថាជាទានមិនមានអានិសង្ស ។ សេចក្តីពិត ទានគឺទាន ប្រាកដជាទានៗ ទាន មិនមែនជាពុទ្ធ ជាគ្រិស្ត ជាហិណ្ឌូ ឬជាមូស្លីម ទេ ។ ព្រហ្ម-

ហារធម៌នៃមាតាបិតា មិនមែនជាពុទ្ធ មិនមែនជាគ្រិស្ត មិនមែនជាហិណ្ឌូ ឬជារបស់អ្នកណាទេ គឺជារបស់មាតាបិតា ។ គុណធម៌ ឬទោសធម៌ដែលកើតក្នុងសន្តានចិត្តមនុស្ស ដូចសិនេហធម៌ សប្បុរសធម៌ ករុណា ខន្តី វិរិយៈ មិត្តភាព រាគៈ ទោសៈ មោហៈ មានៈ-ធម៌ទាំងអស់នេះ មិនមែនជាស្លាក ឬ ជាយីហោនៃនិកាយទេ មិនមែនជាធម៌នៃលទ្ធិសាសនាណាមួយចំពោះទេ ។ បុណ្យ បាប ដែលកើតឡើង កុសលចិត្តនិងអកុសលចិត្ត មិនមែនកើតចំរើនឡើង ឬអន់ថយទៅវិញ ដោយសារតែយើងជួបមនុស្សដែលកាន់លទ្ធិសាសនានោះទេ ។

អ្នកស្វែងរកសច្ចធម៌ មិនមានប្រយោជន៍អ្វីនឹងដឹងថា សច្ចធម៌នេះកើតមកពីណាទេ ។ ការរកកំណើត ឬ ការចំរើនឡើងនៃឧត្តមគតិនេះ ជាភារៈនៃអ្នកប្រវត្តិសាស្ត្រដោយឡែក ។ ដើម្បីលុះសច្ចធម៌ មិនបាច់នឹងដឹងថា ពុទ្ធវចនៈនេះ ជាធម៌អង្គព្រះសម្ពុទ្ធ ឬរបស់លោកអង្គណាក៏បាន ។ កិច្ចការដែលជាសារវន្តនោះ គឺការឃើញធម៌ពិត ហើយបានលុះធម៌នោះដោយប្រពៃ សេចក្តីនេះ មានឧទាហរណ៍ពិតប្រាកដនៅគម្ពីរមជ្ឈិមនិកាយ(១)ដូចសេចក្តីតទៅនេះ ៖ ។ (នៅមានត)

១- មជ្ឈិមនិកាយ ឧបរិបណ្ណាសក ធាតុវិភង្គសូត្រ សៀវភៅទី ២៨ ទំព័រ ១៥០ ។

## ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ទាំង-ខាត់ រៀបរៀង*

អភិវិបញ្ច ធាតុ ពេញចិត្តក្រៃលែង ។

អភិវិសជ្ជ ធាតុ បោះបង់ចោល ។

អភិវិហា ធាតុ ចេញចាក ។

អភិវិក្ស (ឦក្ស) ធាតុ ក្រឡេកមើល. មៀងមើល ។

អភិវីជ ធាតុ វះពោះ ។

អភិវ្ឫ ធាតុ បិទផ្លូវ ៗ-វ្ឫត គុ. ដែលព័ទ្ធជុំវិញ ។

អភិវ្ឫ ធាតុ ជ្រើសរើស ។– វ្ឫត គុ. ដែលជ្រើសរើស ។

អភិវ្ឫត៌ ធាតុ ចូលទៅជិត, កិរិយាចូលភាយ, កិរិយាចាប់ផ្តើម។

អភិវ្ឫទ្ធិ ស្ត្រី. អភិព្រឹទ្ធិ កិរិយារីក, កិរិយាចំរើន ។

អភិវ្ឫធ៌ ធាតុ ចំរើន, លូតលាស់, រីក; កបន្ទាយ ។

អភិវ្ឫឞ៌ ធាតុ ភ្លៀង, ជន់លិច ។– វ្ឫត គុ. ដែលជោរជន់,

ដែលឲ្យភ្លៀង ។

អភិវេដ្ឋ ធាតុ គ្រប, បិទបាំង ។

អភិវុឌ្ឍិ ស្ត្រី. អភិវុឌ្ឍិ កិរិយាកើតឡើង, កិរិយាធ្វើឲ្យប្រាកដ ធ្វើជាគុកម្ម ។

អភិវ្យញ្ជ ធាតុ លេចឡើង ។—ញ្ជិ គុ. ដែលលេចឡើង, ដែលច្បាស់ ។

អភិវ្យញ្ជក គុ. ដែលធ្វើឲ្យប្រាកដឡើង ។

អភិវ្យញ្ជន នបុំ. អភិវ្យញ្ជន៍, កិរិយាបើកបង្ហាញ ។

អភិវ្យធ ធាតុ ធ្វើឲ្យរបួស, បាញ់ត្រូវ ។

អភិវ្យាហារ បុំ. អភិវ្យាហារ កិរិយាថ្លាថ្លែង, សម្ដី ។

អភិវ្យាហ្រ ធាតុ និយាយ, ថ្លែង ។ – ហ្រត នបុំ. រឿងដែលសំដែងហើយ ។

អភិវ្យុទស៍ ធាតុ បោះបង់បោលទាំងអស់ ។

អភិវ្រជ៍ ធាតុ ដើរត្រង់, ដើរតម្រង់ ។

អភិគម្យៀ ធាតុ សរសើរ ។ ឆ្លូល ។

អភិគម្យន នបុំ. កិរិយាដើរ, កិរិយាតិះដៀល ។

អភិគម្យិន៍ គុ. ដែលបោទទោស ។

អភិគក៑ ធ.គុ បង្រៀន ។

អភិគង្ក៑ ធ.គុ សង្ស័យ ។

អភិគង្គា ស្ត្រី. អភិសង្កា, កិរិយាសង្ស័យ ។ - សង្កិត គុ.
ដែលសង្ស័យ ។

អភិគត្រុ ក្រ.វិ. ដោយសត្រូវចំពោះបច្ចាមិត្រ ។

អភិគប៑ ធ.គុ ប្រទេច ។ -គប្ត គុ. ដែលប្រទេច ដែលប្រវញ្ច។

អភិគុប្តិត គុ. ដែលកត់សម្គាល់, ដែលតែងតាំ ។

អភិគម៑ ធ.គុ ឈប់, ស្ទះទុក ។

អភិគស្ត គុ. ដែលចោទទោស ដែលតិះដៀល ដែលដេរ ។

អភិគាន្ត- បុំ. ភារៈនៃកិរិយាធ្វើដោយក្បេមក្សាន្ត ។

អភិគាបិ បុំ. កិរិយាធ្វើធ្មប់ កិរិយាដាក់ស្នេហ៍ ។

អភិគាស៑ ធ.គុ គ្រប់គ្រង ។

អភិគុប៑ ធ.គុ កាន់ទុក្ខ សោយសោក ។

អភិគោភិត គុ. ដែលលំអ ដែលគុបតែង ។

អភិគោប បុ. កិរិយាហាល កិរិយាធ្វើឲ្យស្ងួត ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វៀ-កា ង

ប្រែ-រៀបរៀង

(៩)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកភាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

បេងហោកឆ្លើយថា ដែលលោកទឹងឲ្យយើងព្រមចំណុះចុះចាញ់នោះ មិនត្រូវសោះ ពីព្រោះយើងមិនមែនចាញ់ដោយថ្វីដៃរបស់លោកទេ គឺអៀវហាងគៀនសំឡាញ់របស់យើងធ្វើកលឧបាយឲ្យយើងទុកចិត្ត ហើយគិតចាប់យើងយកឲ្យលោក, បើលោកទឹងសម្លាប់យើង ក៏តាមចិត្តទៅចុះ ឯយើងមិនចំណុះចុះចូលជាដាច់ខាត ។ ខុនបេងថា គ្រានេះអ្នកឯងតែដោះខ្លួនពីយើងមកនៅក្នុងមឿងស្បៀងពិបាក ប្រាថ្នានឹងបញ្ឆោតយើងនិងពួកម៉ាក ឲ្យអន្តរាយជីវិតដោយទឹកអាក្រក់មានពិស កណ្ដាលផ្លូវ តែបាក់ថា ទេវតាលោកមកជួយគម្រង់បម្រុងការយើង ឲ្យចូលមកបានដល់ទីនេះ ហើយ ម្ដេចឡើយអ្នកឯង នៅតែកាន់ទិដ្ឋិមានះ មិនព្រមចំណុះចុះចាញ់យើងដល់ណាទៀត ។

បេងហោកថា បើយើងនៅក្នុងស្រុកនិមថៃ មានទីស្ថានកំពែងបន្ទាយជាមាំមួន ហើយលោកចាប់យើងបាននៅទីនោះ យើងក៏គួរចំណុះលោកតកូនចៅផៅសន្តាន, នេះយើងមិនមែននៅក្នុងទីនោះ ចំពោះមកនៅទីដថៃ បានជាមានសេចក្ដីក្ដាយថ្ងស់ ឲ្យលោកបញ្ឆោតចាប់បានដូច្នេះ, យើងមិនអស់ចិត្តនឹងចាញ់សោះ ។

ខុងបេងឮដូច្នោះក៏គិតថា បេងហោកនៅមានមានះនៅឡើយ, គិតហើយក៏ថា បើដូច្នោះ យើងនឹងលែងអ្នកឯងទៅម្ដងទៀត, អ្នកឯងត្រូវទៀតរកទីជយភូមិឲ្យមួនមាំ ហើយត្រូវចំបម្រុងសេនាទាហាន ឲ្យព្រមព្រៀងទុកចុះ, យើងនឹងលើកទ័ពទៅតស៊ូនឹងអ្នកឯង ។ ក៏នឹងបានឃើញថ្វីដៃយើងជាប្រាកដ, បើយើងចាប់អ្នកឯងបានម្ដងទៀត ហើយនៅតែនិយាយដូច្នេះ យើងនឹងសម្លាប់ឲ្យអស់ទាំងដូរគោត្រ, ថាហើយបង្គាប់ឲ្យស្រាយចំណងបេងហោកចេញ, បេងហោកក៏លាខុងបេងចេញទៅ, ខុងបេងក៏ឲ្យទាហានស្រាយចំណងបេងហ៊ុវ និងតោស៊ូតៃអង់ចេញទៅ រួចក៏តាំងអៀវហានជាទីមន្ត្រីធំ ហើយឲ្យបំណាច់រង្វាន់ដល់ស្រីទាំង ១០ នាក់ និងទាហានទាំងពួងតាមសមគួរ, អៀវហាន ក៏លាខុងបេងទៅកាន់ទីឋានវិញ, ឯបេងហោក បេងហ៊ុវ និងតោស៊ូតៃអង់ ក៏ស្រុតនាំគ្នាទៅទាំងយប់ទាំងថ្ងៃ ដល់ស្រុកសាំកាំង, ក្រៅស្រុកនោះ មានស្ទឹងធំទាំង ៣ ជ្រុង ក្រៅពីនោះទៀត ខាងទិសឯជើងជាទីរាបទូលាយប្រមាណ ៤០០ ហ៊ិន

(១៦គីឡូម៉ែត្រ) មានផ្លែឈើផ្សេងៗជាច្រើនណាស់, ខាងទិសឯលិច ២០០ សិន (៨គីឡូម៉ែត្រ) ជាវាលស្រែអំបិល, ខាងទិសឯត្បូង ជិតក្បែរស្រុក ៣០០សិន (១២គីឡូម៉ែត្រ) ដល់ស្រុកលង់តតង់ហើយ ទើបដល់ទៅស្រុកក្រុងមានកំពែងជុំវិញ, ក្នុងស្រុកនោះ មានកំពុំ ១ ឈ្មោះង៉ិនវ៉ៃ, លើកំពូលភ្នំនោះមានប្រាសាទឈ្មោះកង់តៀន មានបន្ទាយជាទីលំនៅទៅម៉ឺនអង់, ក្បែរប្រាសាទនោះមានសាលាទេព្រ័ក្សជាសម្រាប់ផែនដីជាទីសក្តិសិទ្ធិ, ពួកអ្នកស្រុកឆ្ងាយជិតទាំងពួងរមែងជឿកប់អានកាន់ តែងកំណាន់ឡើងទៅតាំងគ្រឿងសែនថ្វាយ ទៅកែគុយ នៅលើសាលា ១ ឆ្នាំ៤ដង, អ្នកដែលសម្រាប់ប្រតិបត្តិទទួលគ្រឿងសែននោះឈ្មោះ ប៉ក គុយ, ហើយអ្នកស្រុកទាំងពួង ត្រូវជូនទៅចាប់មនុស្សពីដែនស្រុកសែឈួន យកមកសែនគ្រប់ឆ្នាំមិនដែលដាច់, បើរកមិនបាន ក៏បណ្តាលឲ្យឈឺថ្កាត់ជាពោគវិបត្តិផ្សេងៗ ។

ប្រការ ១ ក្នុងស្រុកង៉ិនវ៉ៃនោះ មិនមានរបៀបច្បាប់សម្រាប់ស្រុក នឹងទំនុកបម្រុងតាមទំនៀមទម្លាប់ ដូចជាច្បាប់ស្រុកឯទៀតនោះទេ, បើនរណាហើយធ្វើឲ្យទៅហួយស្រុកនោះតាស់អធ្យាស្រ័យ ដោយប្រការអ្វីនីមួយ ក៏ឲ្យយកខ្លួនទៅសម្លាប់ចេញ, ប្រសិនបើមនុស្សនោះមិញជាស្រីបរទេសនៅក្នុងស្រុកនោះ នឹងធ្វើល្មើសក្រៅពាក្យមាតាបិតាឬស្វាមី ក៏មិនបានឲ្យមានទោស, មួយវិញទៀត បើមានភ្ញៀវធ្លាក់មកមិនបរិបូណ៌ ខ្វះ

ខាតដោយស្រូវអង្ករស្បៀងអាហារ ពួកអ្នកស្រុកពល់គ្នា ក៏យកសាច់សត្វមានជីវ សេះ ជាដើមបរិភោគចិញ្ចឹមជីវិត ។

ឯប៉េងហោកនោះ លុះទៅដល់ស្រុកនិទវែរហើយ ក៏រេះតែបញ្ចុះបញ្ចូលពលទាហាន បានប្រមាណ ១.០០០ នាយ, ប៉េងហោកក៏និយាយនឹងទាហានទាំងពួងថា យើងធ្វើសឹកមកនឹងខុនបេង ក៏បាញ់ប្រៀបគេច្រើនគ្រា បានសេចក្តីវេទនា គួរឲ្យអាប់យសណាស់ អស់អ្នកពល់គ្នាដែលមានប្រាជ្ញាស្មារតី ចូរមានសេចក្តីឈឺចិត្តគិតជួយយើងឲ្យកែខ្លួនបានឡើងវិញ ធ្វើម្តេចមិញនឹងបានមានជ័យជម្នះខុនបេងឲ្យបាន, តួហៃហូ ជាប្អូនប្រពន្ធប៉េងហោកឆ្លើយថា បើខុនបេងលើកទ័ពតាមមក ខ្ញុំបាទនឹងសុំយកអាសាសងសឹកឲ្យបាន, ប៉េងហោកថា អ្នកឯងមានប្រាជ្ញានឹងគិតធ្វើម្តេច ។

តួហៃហូឆ្លើយថា បុកឡុកតែអង ចៅហ្វាយស្រុកប៉ុតហ៊ុបតង នៅខាងទិសឯលិចស្រុកយើងនេះ មានសេចក្តីចេះដឹងជ្រៅជ្រាស បើឡើងជិះលើដំរី ហើយរាយមន្តគាថា ហៅឲ្យកើតខ្យល់ព្យុះសង្ឃរា ហៅដុំថ្មសិលា ឲ្យខ្ទាតអណ្តែតទៅត្រូវខាំងសត្រូវ ឬហៅសត្វអាសិរពិសការចផ្សេងៗ មកប្រើក៏បានតាមប្រាថ្នា ហើយមានព្រាយមាយាជាបិសាចអាចចេះសម្តែងរិទ្ធិប្រមាណ ៣០.០០០ តាមជិតដោយឲ្យប្រើប្រាស់ មិនចេះដាច់, សូមឲ្យលោកតែងសំបុត្រ ១ ច្បាប់ នឹងចាត់គ្រឿងប្រដាប់ ជា

បណ្ណាការឲ្យមានតម្លៃ ខ្ញុំបាទនឹងនាំទៅគំនាប់ ប្រស្រ័យដល់ពុកឡុក-តៃអង សុំអង្វរឲ្យលើកទ័ពមកជួយលោកជាបងឲ្យបាន, ការដែលយើងគិតទាំងប៉ុន្មាន ក៏នឹងសម្រេច ។

បេងហោកបានឮហើយ ក៏ត្រេកអរណាស់ ក្រោកឡើងរហ័សទៅសរសេរសំបុត្រតាមគំនិតដែលគិតឃើញគ្រប់ប្រការ ហើយចាត់ទូវរបស់ជាគ្រឿងបណ្ណាការប្រគល់ឲ្យគួហៃ ។ ក៏គំនាប់នាំរបស់ទ្រព្យនិងសំបុត្រចេញទៅ, ឯបេងហោកនោះកូវ ក៏ចាត់ប្រើតោស៊ូតៃអង ឲ្យនាំពួកទាហានមួយកងទៅឈរក្បែស្រុកសាំកាំង ។

ខុងបេងក៏លើកកងទ័ពតាមបេងហោកទៅដល់ស្រុកសាំកាំង ហើយឲ្យជូឡុងនិងអ៊ុយអៀន នាំទាហានលើកទៅព័យស្រុក ខាងទិសឯជើង, នោះតោស៊ូតៃអង ក៏ឲ្យទាហានដែលចំណានស្ទាត់ (បាញ់ស្នា) ឡើងរក្សាសើនបន្ទាយ ជាមាំមួនណាស់, ទាហានទាំងនោះ ក៏ត្រៀមស្នាសម្រាប់ដៃលាបថ្នាំពិស បើបាញ់ត្រូវអ្នកឯណា ក៏រលួយបែកទាល់ស្លាប់, លុះជូឡុងលើកទាហានចូលទៅជិត, ទាហានលើកំពែង ក៏យកស្នាបាញ់ចម្រុះត្រូវទាហានជូឡុងរបួសពិការស្លាប់ជាច្រើន, ជូឡុងនិងអ៊ុយអៀន ក៏ថយត្រឡប់ទៅរកខុងបេង ។ ឃើញទាហានត្រូវ (ព្រួញ) របួសពិការជាសាហ័ស ក៏យកថ្នាំទៅផ្សះលាបឲ្យពិស (ព្រួញ) នោះ ក៏សះជាបាត់

ហើយក៏ឡើងរទេះបរសំដៅទៅមើល ឃើញក្បួនមិនបានមានរបៀបរៀបរយ, ខុងបេងក៏ថយទ័ពត្រឡប់ចេញទៅតាំងបន្ទាយជាមាំមួន ចម្ងាយពីទីក្រុង ៦០ សិន (២,៤០០ ម៉ែត្រ), ទាហានក្នុងស្រុក សាំកាំង ឃើញខុងបេង ថយទ័ពត្រឡប់ចេញ ទៅតាំងបន្ទាយពីចម្ងាយ ក៏មានសេចក្ដីមើលងាយ ប្រមាទធ្វេសសម្គាល់ថា ខុងបេងចាញ់ថ្វីដៃខ្លួន មិនហានតស៊ូ ។

លុះខុងបេងថយចេញទៅតាំងនៅទីនោះអស់រវាង ៧ ថ្ងៃ ក៏កើតព្យុះខ្យល់បក់បោកមកក្នុងបន្ទាយ, ខុងបេងក៏និយាយបង្គាប់ទាហានទាំងពួងថា យើងនឹងត្រូវការយកខោអាវឲ្យបានក្នុងម្នាក់ ១ ប្រដាប់គ្រប់គ្នា ក្នុងវេលាថ្ងៃនេះ បើនរណាមិនបាន យើងនឹងកាត់ក្បាលអ្នកនោះចេញ, អស់ពួកទាហាននោះមិញ ឮដូច្នោះ ក៏ទឹកសន្ទះសង្ស័យណាស់ តែខ្លាចអាជ្ញាខុង-បេងជាម្ចាស់ ក៏នាំគ្នាទៅរកខោអាវបានម្នាក់១ ប្រដាប់ចូលទៅជូនខុងបេង, លុះដល់ពេលយាម ១ ខុងបេងក៏ឲ្យទាហានយកគ្រឿងសម្លៀកនោះរុំបត់ម្នាក់ ១ ដុំ លើកចូលទៅតម្រង់ទឹងកំពែងស្រុក ទាល់តែខ្ពស់ឡើងស្មើនឹងសន្ធឹកសីមា ហើយនិយាយនឹងទាហានទាំងនោះថា បើនរណាចូលទៅក្នុងស្រុកបានមុនគេ យើងនឹងឲ្យបំណាច់រង្វាន់ឲ្យពេញចិត្ត; អស់ពួកទា-ហាន បានឮខុងបេងដាក់កម្រិតដូច្នោះ ក៏ស្ទុះដណ្ដើមគ្នាចូលទៅបានជាច្រើន ហើយសញ្ញាគ្នាដេញកាប់សម្លាប់ខ្មាំងជាជ្រួលច្របល់, គោស៊ីតែអង

មិនទាន់ដឹងកលការច្បាស់ជាសត្រូវចូលទៅពីជើងពីត្បូង ក៏ឡើងសេះនាំទាហានចេញពីបន្ទាយ, ទាហានខុនបេងឃើញ ក៏ពារម្ខាយដេញសង្ខុញតាមហើយយកលំពែងចាក់ត្រូវតោស៊ូតែអង់ធ្លាក់ពីលើសេះស្លាប់, កងទ័ពក៏បែកធ្លាយខ្ចាត់ខ្ចាយគ្នា ខូចស្រុកក្នុងគ្រានោះ ខ្លះក៏រត់ទម្រុះទៅរកបេង-ហោក ប្រហែលពាក់កណ្ដាល, ខុនបេងមានជ័យជម្នះ ក៏លើកទ័ពទាំងអម្បាលនោះចូលទៅតាំងនៅក្នុងស្រុកសាំកាំង ហើយក៏ចាត់ការឲ្យត្រួតរាំងរក្សា ហើយគិតនឹងលើកទៅស្រុកដទៃទៀត ។

ឯបេងហោកដឹងថា ខុនបេងវាយបានស្រុកសាំកាំងហើយ ក៏មានសេចក្ដីព្រួយខ្លាំងណាស់ ខណៈនោះមានទាហានចូលទៅប្រាប់ថា ខុន-បេងលើកទាហានធ្វើពីត្រើយម្ខាងចូលមកដែនខាងនេះហើយ, បេងហោកក៏ស្លុតព្រលឹងរឹងរស់ពាន់ខ្លួន, គ្រានោះនាង ចុកយ៉ុង ជាភរិយាបេងហោកលបអែបស្ដាប់ពីក្នុងផាក ក្រឡេកឃើញប្ដីភ័យយ៉ាងលំបាកដូច្នោះ ក៏ស្ទុះចេញមកហើយអស់សំណើចថា ខ្លួនអ្នកជាប្រុសឈ្មោះថាជាជាតិទាហានមានថ្វីដៃ គួរអៀមអស់សេចក្ដីគិតនឹងការសឹកប៉ុណ្ណេះ, អ្នកកុំបីព្រួយជាទុក្ខឡើយ, ឯខ្ញុំឯងហើយជាកូនស្រី នឹងសុំចេញទៅយកអាសាអ្នកជាស្វាមីធ្វើសឹកតថ្វីដៃនឹងខុនបេងឲ្យបាន, បេងហោកបានឮភរិយាថាដូច្នោះ ក៏នឹកឡើងបានថា នាងចុកយ៉ុង ដែលជាមនុស្សមានវិជ្ជាការប្រើអាវុធ-សាស្ត្របានដូចចិត្ត, បើសត្រូវដេញជិតចូលមក ក៏ពុះអាវុធនោះឡើង

ទៅលើអាកាសវេហាស៍ ដោយអំណាចនៃវិជ្ជានោះក៏បណ្ដាលឲ្យអាវុធធ្លាក់ចុះ រុះពាយទៅត្រូវលើសត្រូវទាំងឡាយឲ្យវិនាសអន្តរាយបាន ឃើញល្មមទឹងតស៊ូច្បាំងយកជ័យជម្នះខុងបេងហ្មាន, បេងហោកគិតហើយ ក៏ឲ្យមានសេចក្ដីត្រេកអរពន់ប្រមាណណាស់ គំនាប់ទទួលគួរសមទឹងកិរិយា ហើយម្នីម្នាចេញទៅ ជ្រើសរើសបានទាហានឯក ១០០ នាក់ ទឹងទាហានរង ៥០.០០០ ប្រគល់ឲ្យនាងចុកយ៉ុងជាភរិយា, នាងក៏គំនាប់លាស្វាមីលើកយោធានិករចេញចាកស្រុកទៅ, ខណៈនោះ, ទទួលទៀវងឺទឹងម៉ាតង ជាទាហានខុងបេង លើកមកដល់ទទួលតទល់គ្នា ។

នាងចុកយ៉ុងឃើញកងទ័ពដូច្នោះ ក៏តែងខ្លួនកាន់អាវុធវិសេសសៀតចង្កប់ពីក្រោយខ្នង ៤ អាវុធ ហើយឡើងជិះសេះកាន់លំពែងវែង ៣ ព្យាម ពាំក្បួនអាវុធចូលប្រយុទ្ធគ្នាទឹងទៀវងឺបាន ៩ ក្បួន នាងចុកយ៉ុងធ្វើជាហាញ់ញាក់សេះរត់, ទៀវងឺមិនបានដឹងកលឧបាយ ក៏បំផាយសេះដេញតាមនាងចុកយ៉ុង, នាងចុកយ៉ុង ក៏ក្រទាក់ដកយកអាវុធវិសេសបោះឡើងទៅលើអាកាស, អាវុធនោះក៏ធ្លាក់ចុះមកត្រូវទៀវងឺធ្លាក់ពីលើសេះ, ទាហានទាំងអស់ ក៏ស្ទុះស្រូបចូលទៅចាប់ខ្លួនទៀវងឺចងបាន, ម៉ាតងឃើញដូច្នោះ ក៏បំបោលសេះចូលទៅដណ្ដើមទៀវងឺ គ្រាឡេកឃើញនាងចុកយ៉ុងបញ្ឈរសេះកាន់លំពែងនៅពីមុខ ក៏ខឹកខឹងណាស់ បំផាយសេះចូលទៅច្បាំងទឹងនាងចុកយ៉ុង នៅមិនទាន់ហាញ់ឈ្នះគ្នា, នាងចុកយ៉ុង ធ្វើកលយក

ខ្សែព្រ័ត្រពោះទៅរុំជើងសេះដួលចុះ, ម៉ាតង៉ក៏របូតធ្លាក់ពីលើសេះ, នាងចុកយ៉ុង ក៏ឲ្យទាហានស្ទុះទៅចាប់ចងខ្លួនម៉ាតង៉បាន ហើយឲ្យនាំខ្លួនទៀវង៉ី និងម៉ាតង៉ចូលទៅក្នុងស្រុក ។

បេងហោកឃើញដូច្នោះ ក៏មានអំណរណាស់ ទើបតែងតុលៀងអាហារឲ្យនាងចុកយ៉ុងបរិភោគផឹកស៊ុក, នាងចុកយ៉ុង ក៏បង្គាប់ទាហានឲ្យយកទៀវង៉ី និងម៉ាតង៉ទៅសម្លាប់, បេងហោកឆ្លើយឡើងថា យើងបានធ្វើការនឹងខុងបេង ៗ ចាប់បានយើង ៥ ដង ហើយនៅទុកជីវិតយើងលែងមកវិញមិនបានធ្វើអន្តរាយ, វេលានេះ បើយើងនឹងសម្លាប់ទៀវង៉ី-ម៉ាតង៉ចេញ ឃើញមិនគួរសោះ, មនុស្សទាំងពួង ក៏នឹងគរហានិន្ទាបាន, គួរតែយើងបង្អង់ខានកុំសម្លាប់សិនចុះ បើយើងចាប់បានខុងបេងទាំងរស់ វេលាណាសឹមសម្លាប់ឲ្យព្រមគ្នាតែម្តង, នាងចុកយ៉ុងយល់ឃើញត្រូវផង ទើបឲ្យទាហានយកខ្លួនទៀវង៉ី-ម៉ាតង៉ទៅឃុំទុក ។

ឯទាហានទៀវង៉ីដែលបែកខ្ចាត់ទៅនោះ នាំរឿងហេតុទៅជម្រាបខុងបេងគ្រប់ប្រការ, ខុងបេងក៏ឲ្យហៅម៉ាតាយមកបង្គាប់ថា ត្រូវឲ្យអ្នកឯងនាំទាហានទៅចាំនៅផ្លូវតូច បើឃើញនាងចុកយ៉ុងដេញដូឡុងនិងអ៊ុយអៀនមក ឲ្យយកខ្សែព្រ័ត្រទាក់ជើងសេះចាប់យកខ្លួននាងចុកយ៉ុងឲ្យបាន, ម៉ាតាយទទួលប្រសាសន៍ហើយ ក៏ចេញទៅចាត់ការ នាំទាហានទៅបង្កប់តាមទីកន្លែង, ហើយខុងបេងក៏បង្គាប់ដូឡុងនិងអ៊ុយអៀនឲ្យនាំទាហានទៅច្បាំង

តដៃនឹងនាងចុកយ៉ុង ហើយឲ្យធ្វើជាចាញ់ បញ្ឆាតឲ្យដេញទៅតាមផ្លូវ
ដែលម៉ាតាយបង្កប់នៅនោះ, ជូឡុងនិងអ៊ុយអៀន ក៏ទទួលបង្គាប់ខុង-
បេង ហើយលើកទាហានចេញទៅ ។

លុះដល់ពេលព្រឹក មានពួកល្បាតទៅប្រាប់បេងហេកថា ជូឡុង
លើកទាហានចូលមកច្រើនណាស់, នាងចុកយ៉ុងបានឮច្បាស់ក៏ឡើងសេះ
លើកទាហានចេញទៅច្បាំងនឹងជូឡុងបាន ៩ ក្បួង, ជូឡុងញាក់សេះវេះ
ត្រឡប់ទៅក្រោយ បណ្ដោយឲ្យដេញជាកលបញ្ឆោត, នាងចុកយ៉ុងខ្លាច
ក្រែងខុងបេងនឹងប្រើកលឧបាយ ក៏ថយទាហាន ទឹងត្រឡប់ចូលទៅក្នុង
ស្រុកវិញ, អ៊ុយអៀនឃើញដូច្នោះ ក៏បង្រួះទាហានទន្ទ្រានដេញតាមទៅ,
នាងចុកយ៉ុងក៏គន្ទ្រាក់សេះប្រែមកតដៃនឹងអ៊ុយអៀនវិញ. អ៊ុយអៀនធ្វើជា
ចាញ់ទាញសេះរត់, នាងចុកយ៉ុងក៏បញ្ឈប់គងទ័ពតាំងភ្ជាប់នៅក្រៅស្រុក
១ យប់, លុះពេលព្រឹកឡើងជូឡុងក៏នាំទាហានចូលទៅបបួលច្បាំងទៀត,
នាងចុកយ៉ុង ក៏បំបោលសេះចេញមកតដៃនឹងជូឡុងបាន ៤ ក្បួង, ជូឡុង
ញាក់សេះរត់, នាងចុកយ៉ុងក៏មិនបានលើកតាម ត្រឡប់សេះទឹងចូលទៅ
ក្នុងស្រុក, អ៊ុយអៀនឃើញដូច្នេះ ក៏បំផាយសេះតាមទៅ ហើយស្រែកជេរ
នាងចុកយ៉ុងជាពាក្យទ្រគោះអសុរសផ្សេង ៗ, នាងចុកយ៉ុងឮហើយក៏ខឹង
ណាស់ ត្រឡប់វិលមកច្បាំងនឹងអ៊ុយអៀន ៗ បំផាយសេះរត់ទៅ ហើយ

បេះតែស្រែកជេរបញ្ចោរបណ្តើរ, នាងចុកយ៉ុងក៏បំផាយសេះតាមទៅដោយកម្លាំងទោសោ លុះទៅដល់ផ្លូវតូចក្បែរជើងភ្នំ ដែលម៉ាតាយបង្កប់ទាហាននៅនោះ, ម៉ាតាយក៏ឲ្យទាហានស្ទុះស្រវចេញមក យកខ្សែព្រួរទាក់ជើងសេះដួលចុះ, នាងចុកយ៉ុងក៏ក្លាត់ធ្លាក់ពីលើសេះ, ម៉ាតាយនិងទាហានក៏ស្ទុះពានទៅចាប់ខ្លួននាងចុកយ៉ុងបាន ហើយបងនាំទៅជូនខុងបេង, ប៉ុន្តែក៏ដេញកាប់សម្លាប់កងទ័ពនាងចុកយ៉ុងស្លាប់ជាច្រើនណាស់ ខ្លះក៏រត់ត្រឡប់ចូលទៅក្នុងស្រុកបាន ។

ខុងបេង ឃើញម៉ាតាយចាប់បានខ្លួននាងចុកយ៉ុងនាំទៅជូន ក៏មានអំណរណាស់ ឲ្យទាហានស្រាយចំណងចេញ ហើយអញ្ជើញនាងចុកយ៉ុងឲ្យឡើងតុផឹកស្រា ហើយខុងបេងប្រើបម្រើឲ្យចូលទៅប្រាប់បេងហេកថាឲ្យបង្វិលខ្លួនទៀវធីនិងម៉ាតងមកឲ្យវិញចុះ ទើបនឹងបើកខ្លួននាងចុកយ៉ុងឲ្យរួចទៅ, ឯងណោះបេងហេកបានឮដូច្នោះ ក៏ដោះលែងខ្លួនទៀវធី និងម៉ាតងវិលទៅដល់បន្ទាយខុងបេង ទើបខុងបេងបើកលែងខ្លួននាងចុកយ៉ុងទៅ, បេងហេកឃើញភរិយាចូលមកក៏មានអំណរណាស់ ទទួលទាហានចូលមកប្រាប់ថាបុកឡូកលើកទ័ពមកដល់, បេងហេកក៏មានអំណរណាស់ចេញទៅទទួលដល់ក្រៅស្រុក ឃើញបុកឡូកតែអង្គ ពាក់អាវចានមាសប្រដាប់ត្បូងពេជ្រសៀតគ្រប់ដំថ្លៃ ២ ជិះដំរីសម្បុរលឿងចញ្ជូរកណ្ដាល

រណារង្គ មានទាហានដែលជាទ្រមាក់សម្រាប់ជិះសត្វកាច ១ ពួក, បេង-ហោក ក៏ចូលទៅគំនាប់សាសព្វសេចក្តីឲ្យបុកឡុកតៃអង់ស្តាប់គ្រប់ប្រការៗ

បុកឡុកតៃអង់ថា អ្នកកុំវិតក្កទៀយ ខុងបេងធ្វើការមក ហើយឲ្យអ្នកបានសេចក្តីអាប់យសនោះ យើងនឹងទទួលជួយជាធុរៈសងសឹក, បេង-ហោកបានស្តាប់ ក៏ចាប់ចិត្តរឹតតែសោមនស្សត្រេកអរ អញ្ជើញបុកឡុក-តៃអង់ចូលទៅក្នុងស្រុក ហើយតែងតុលៀងអាហារស្រាបាយ ពួកពលទាំងឡាយ ក៏ឲ្យចរិ~~កាគផង~~ច្រើនណាស់, លុះវេលាព្រឹក បុកឡុកតៃអង់ក៏លើកកងទ័ពចេញអំពីស្រុក តម្រង់ទៅបន្ទាយខុងបេង, ខុងបេងឃើញដូច្នោះ ក៏ចាត់ឲ្យជូឡុងនិងអ៊ុយអៀន លើកពលចេញតខាងក្រៅបន្ទាយ, លុះឃើញបុកឡុកតៃអង់លើកមកដល់ ជូឡុងនិងអ៊ុយអៀន ក៏បំផាយសេះចេញទៅបំពារមុខទ័ព ឃើញទង់ជ័យក្បួនទ័ពរៀបរយ តែឃើញពួកពលទាំងឡាយមិនមានពាក់អាវក្រោះសោះ, កិរិយានិងមុខមាត់ពលទាំងអស់ ក៏ខុសនឹងចរិតមនុស្សធម្មតា ហើយក៏មិនគោះគងទូងកែវជាទីរបៀបសោះ គ្រាន់តែវាយឃ្មោះហៅពលជាសម្គាល់, ឯខ្លួនបុកឡុកតៃអង់តែងតួជាក្សត្រ ជិះដំរីលឿង សៀតគ្រឿងអាវុធដាវផ្ទៃរ មានទាហានកាន់ទង់ជ័យរំកាយក្បែរមុខដំរីម្នាក់ ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក ក៉ាប៊ិត្រ្ហណាត តាម្ភ័រ

ប្រែសម្រួលដោយអ្នកស្រី ទេជ-សល់

## វគ្គទី ២៥

ព្រៃល្បាស់ដែលដុះជាជួរនៅលើមាត់ច្រាំង ប្រៀបបានទឹងខ្សែបូខៀវមួយយ៉ាងវែង ដែលក្រវាត់ព័ទ្ធលើសារពណ៌លឿងទុំ នៃទេសភាពកាលអស្ដង្គត ។ មើលទៅលើអាកាស ហ្វូងទាព្រៃខ្មៅជាសហើរត្រឡប់មកកាន់បឹងដែលជាទីជម្រករបស់ខ្លួនវិញ ក្រោយពីបានទៅរកគ្រាប់ផលាបរិភោគនៅទីវាលឆ្ងាយអស់បីវេលាពេញមួយថ្ងៃ ។ រាត្រីកាលក៏កាន់តែសន្សឹមចុះគ្របព្រះធរណី ហ្វូងក្អែកដែលស្រែកលាន់ទ្រហឹងក៏នាំគ្នាចូលទ្រនំស្ងាត់មាត់បន្តិចម្ដង ៗ ទាទាំងឡាយដែលត្រេចតាមដងទន្លេក៏ចូលរកចំណតបន្តបន្ទាប់គ្នាអស់ នៅសល់តែកប៉ាល់អភ័ព្វធំជ្រងឹងដែលគៀងជាប់តាំងពីថ្ងៃនោះឯង ដែលចាំត្រេចឡើងច្រាស់ខ្សែទឹកតែម្នាក់ឯង ។

ក៉ាមេស្ហ៊ូសកៅអីសំពត់មួយទៅអង្គុយលើក្បាលកប៉ាល់ បណ្ដែតអារម្មណ៍ក្រោមពន្លឺព្រះចន្ទដែលទើបនឹងរះឡើង ។ មួយរាត្រីកាល ហាក់ដូចជាផាត់ច្រានពន្លឺព្រះអាទិត្យចេញអស់រលីង ឯផ្ទៃព្រះធរណីនៅក្រោមពន្លឺព្រះចន្ទក៏ត្រចះត្រចង់ដែរ ក៏ហាក់ដូចជាគ្មានទេ ទៅជាស្ងៀមស្ងាប់

សក្បុះ ៗ ក៏មេស្នេហ៍ដែលមានអាត្មានពោរពេញទៅដោយអនុស្សាវរីយ៍មិន
អាចបំភ្លេចបានគ្រប់យ៉ាង នៃនាងហិមណាលិទីស្រីបណ្ដូលចិត្តកំពោល
ឈ្មោះនាងរម្យ ៗ តែម្នាក់ឯង ៗ គ្រាន់តែនឹកដូចប្រេះក្លាម អ្នកស្រមៃឃើញ
គូស្នេហារបស់អ្នក អណ្ដែតតាមផ្សែងអាប់មកនៅចំពោះមុខអ្នកភ្លាម អ្នក
ស្រមៃឃើញនាងមានទឹកមុខព្រួយស្រពោន អ្នកនឹកអាណិតព្រួចហើយ
អង្គុយសម្រក់ទឹកភ្នែកតែម្នាក់ឯង អ្នកនឹកឃើញកាលដែលធ្លាប់បាននៅ
ប្រាស្រ័យលេងជាមួយគ្នាយ៉ាងស្និទ្ធស្នាលអស់រយៈវេលា ២ ឆ្នាំមកហើយ
នឹកឃើញពេលដែលបានស្គាល់នាង ហើយអ្នកមិនបាននឹកស្មានថា ការ
ដែលបានស្គាល់នាងនោះ ធ្វើឲ្យអនាគតអ្នកធ្លាក់ដល់ថ្នាក់នេះសោះ ៗ
ដោយចន្ទ្រាគេបាននាំអ្នកទៅលេងផ្ទះគេ កាលនោះអ្នកនៅក្មេងហើយ
អៀនច្រើននៅឡើយ លុះឃើញនាងហិមណាលិទី ចូលមកបរិភោគ
ទឹកតែនៅតុជាមួយអ្នក អ្នកអៀនស្ទើរតែធ្វើអ្វីមិនកើត ៗ ក្រោយ
មកអ្នកក៏គ្រាន់តែស៊ាំបន្តិចម្ដង ៗ ឯពាក្យកាព្យឃ្លោងនៅក្នុងសៀវភៅ
ទាំងប៉ុន្មាន ក៏ក្លាយទៅជាមានរូបរាងលើសមនុស្សនារីជាទីស្នេហានោះ
ទាំងស្រុង ៗ អ្នកសប្បាយចិត្តក្រៃលែងនឹងការដែលបានតើបពះប្រទះ
ទីពឹងស្នេហា ច្បាស់ក្រឡែតអណ្ដែតមកទន្ទិចអ្នកបាក់ដូចជាដប់ ៗ
ទាល់តែមកដល់ទីនិប៉ុណ្ណេះ ទើបអ្នកដឹងខ្លួនច្បាស់ថា « អ្នកទើបតែនឹង
[illegible] លុះនាងកាមាលាចូល

មកជាបញ្ហាមួយស្រាយមិនរួចក្នុងឆាកជីវិតរបស់អ្នក ទើបអ្នកយល់ច្បាស់ថា សេចក្ដីស្នេហារបស់អ្នកចំពោះនាងហិមណាលិនី គឺត្រូវសន្ធឹកមហាព្យុះសង្គ្រាមគួបត្រឡប់ក្នុងពេលនេះតែម្ដង ។

ទឹកឃើញសេចក្ដីកង្វល់ស្មុគស្មាញរាយមិនថែកសេចក្ដី យ៉ាងនេះ អ្នកយកដៃទ្រក្បាលហាក់ដូចជាក្បាលនោះធ្ងន់សែនធ្ងន់ "ឱ! ជីវិតអាត្មាអញតទៅអនាគត ជីវិតឋិតនៅក្នុងសំណាញ់ ដែលអាត្មាអញគេដូរចេញមិនរួច តើអញត្រូវចំប្រើងចំរះឲ្យរួចយ៉ាងពេញទំហឹងប្ដូយ៉ាងណា ?" អ្នកងើបក្បាលឡើងភ្លាមហាក់ដូចជាសម្រេចចិត្តថា "ត្រូវតែធ្វើ" ស្រាប់តែឃើញនាងកាមាលាឈរព្រួតលើខ្នងកៅអីមួយនៅបង្អើយក្បែរអ្នក កាយវិការកាមេស្វាទាញអារម្មណ៍នាងរិប នាងសួរ ?

– បងសម្រាន្តអីអំបាញ់មិញ ? ខ្ញុំមកធ្វើឲ្យបងភ្ញាក់អស់ ជាហើយនាងបង្វិលខ្លួនទឹងត្រឡប់ចូលទៅបន្ទប់វិញ

– ខ្ញុំឥតគេងទេ (កាមេស្វាឆ្លើយ) កាមាលាទាញកៅអីនោះមកអង្គុយជិតខ្ញុំមក ខ្ញុំនិយាយរឿងមួយឲ្យស្ដាប់ ។

ពុកាមេស្វាជាដូច្នេះនាងអរណាស់ កំរុញកៅអីទាល់តែទៅប៉ះនឹងកៅអីកាមេស្វាហើយអង្គុយរង់ចាំស្ដាប់រឿង ។ កាមេស្វាគិតខឹងនិយាយរឿងពិតប្រាប់នាងហើយម្ដងនេះទុកយូរមិនកើតទេ ប៉ុន្តែត្រូវរៀបសេចក្ដីឲ្យស្រួលសិន ។

កាមេស្ហតើមនិយាយ :

– កាលនោះមានក្រុមកដពុទ្ធ . . .

– ពីកាលណាបង ប៉ុន្មានឆ្នាំកន្លងទៅហើយ ?

– តាំងពីកាមាណាឯងមិនទាន់កើតម៉្លេះ

– បងកើតហើយប្រហែល និយាយតទៅលោកគាពុកមាត់ស្រួរ ៗ

– ពួកកដពុទ្ធនោះ មានទំនៀមប្លែកណាស់ គឺថា បើបុរសណារៀបការប្រពន្ធ បុរសនោះមិនត្រូវទៅទទួលប្រពន្ធខ្លួនឯងទេ គេត្រូវផ្ញើតែផាវទៅបានហើយ កូនស្រីត្រូវរៀបចំអាពាហ៍ពិពាហ៍ជាមួយនឹងផាវនោះសិនទៅ រួចទើបគេនាំយកនាងនោះមករៀបការជំជុំមែនទែននៅឯផ្ទះខាងប្រុស ៗ

– ចុះទំនៀមអ្វីក៏ប្លែកខុសគេម៉្លេះបង ?

– មែនហើយ រឿងហ្នឹងក៏ដូចជារឿងខ្ញុំខ្វះដែរ ពួកកដពុទ្ធនោះគេយល់ថា ប្រុសទៅផ្ទះខាងស្រីជាការថោកទាប ។ ឯស្តេចដែលត្រូវរៀបអាពាហ៍ពិពាហ៍នោះ គឺជាពួកកដពុទ្ធនោះឯង ។ ថ្ងៃមួយ ស្តេច . . .

– ស្តេចនោះសោយរាជ្យនៅនគរណាទៅបង ?

– នៅម៉ាឌុក ថ្ងៃមួយស្តេច . . .

– ស្តេចនោះឈ្មោះអីបង ? ( កាមាណាចេះតែសួរបញ្ជាក់ )

នាងកាមាណាស្មានថាជារឿងពិត ក៏ចេះតែសួរដេញដោលឲ្យអស់

សេចក្តី ក៏មេស្ហទឹកស្តាយ នឹងមិនបានរកទឹកទុកជាមុន អ្នកទប់មួយសន្ទុះ ទើបចាប់និទានតទៅទៀត ។

— ស្តេចនោះមានព្រះនាមថា „ រញ្ជិតសិង្ហ ”

“ ថ្ងៃមួយលោកបានទទួលដំណឹងអំពីអ្នកដើរច្រៀងម្នាក់ថា មានស្តេចមួយព្រះអង្គសាសន៍ជាមួយនឹងព្រះអង្គដែរ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គប្រកបដោយរូបឆោមដ៏ល្អឥតខ្ចោះ ។

— ស្តេចដែលមានកូនស្រីនោះ គង់នៅនគរណាបង ?

— យើងថានៅនគរកុងដេវេក៉ាមទៅចុះ

— យី ម្តេចក៏បងចេះតែថាដូច្នេះ បើគីចឹងរឿងនេះមិនមែនជារឿងពិតទេឬ ?

— ប្រហែលជាមិនពិតមែនហើយ រួចនាងចង់ដឹងព្រះនាមស្តេចនោះទៀតឬ ? ព្រះអង្គទ្រង់ព្រះនាមថាអមរសិង្ហ ។

ចុះព្រះរាជបុត្រី ?

— មែនហើយ ព្រះនាងឈ្មោះចន្ទ្រា ។

— បងភ្លេចអ្វីក៏ភ្លេចម្ល៉េះទេ ភ្លេចទាំងឈ្មោះខ្ញុំផងទៅហើយទេដឹង ។

— ខ្ញុំនិយាយតទៅទៀត លុះដល់ស្តេចក្រុងអ៊ុធនោះ ទ្រង់ព្រះសណ្តាប់ អ្នកចម្រៀងនោះហើយ . . .

.. ១ នស្តេចក្រុងអ៊ុធពីណាមកទៀត ក្រែងថាស្តេចនៅម៉ាឌុកឬបង?

– ថាគេសោយរាជ្យនគរពីរ (រាមេស្ហបេះតែថែម) នៅពេលរាមេស្ហនិទានរឿង នាងរាមាណាបេះតែចាប់កំហុស តែអ្នកបេះតែដោះរួច ឯរឿងដែលរាមេស្ហប្រឌិតក្នុងពេលនោះ មានដូចខាងក្រោម... ។

– រញ្ចិតសិង្ហ ស្តេចក្រុងម៉ាឌូក៏ទ្រង់ប្រើមហាមាត្យធំម្នាក់ឲ្យទៅក្រុងដេវេរ៉ាមនគរ ដើម្បីសុំចងស្ពានមេត្រីនឹងព្រះអង្គ ។ ព្រះចៅក្រុងកុងដេវេរ៉ាម ទ្រង់សព្វព្រះរាជហឫទ័យ តាមសេចក្តីស្នើនោះ ។

ព្រះចៅរញ្ចិតសិង្ហ ទ្រង់ប្រើព្រះអនុជពៅរបស់ព្រះអង្គព្រះនាមឥន្ទ្រជិតសិង្ហ ឲ្យនាំពលរេហ៍ទៅឯនគរព្រះចៅអមរសឹង្ហ ដល់ហើយក៏នាំគ្នាទៅបោះព្រះពន្លានៅក្នុងព្រះរាជឧទ្យាន ។ នៅឱកាសនោះនៅក្រុងកុងដេវេរ៉ាម គេមានធ្វើបុណ្យមួយយ៉ាងឧឡារិក កំដរអាពាហ៍ពិពាហ៍ព្រះរាជបុត្រីនៃព្រះរាជា ។

ព្រះរាជហោរាបានរាយលេខរកឫក្សពារពេលល្អ ដើម្បីនឹងរៀបអាពាហ៍ពិពាហ៍ព្រះអង្គម្ចាស់ក្សត្រី រកទៅត្រូវបានពេលានៅយប់ថ្ងៃ ១៦ កើត វេលាម៉ោង ២ ភ្លឺ ៖ ផ្ទះនានាក្នុងទីក្រុងនោះសុទ្ធតែប្រដាប់ដោយភ្លើង ទង់ក្រដាសពណ៌ចងខ្វាត់ខ្វែងដែលជានិមិត្តរូបនៃសេចក្តីអបអរសាទររបស់ប្រជារាស្ត្រនឹងពិធីមង្គលការព្រះនាងចន្ទ្រា ។

ប៉ុន្តែដល់ថ្ងៃកំណត់ការហើយ ព្រះនាងមិនទាន់ស្គាល់មុខមាត់ព្រះស្វាមីព្រះនាងនៅឡើយទេ កាលព្រះនាងទើបនឹងទ្រង់ប្រសូត្រចេញមក

ភ្លាម តាបសបរមានន្ទ្រាស្វាមិ បានទំនាយថ្វាយព្រះបិតាព្រះនាងថា « តាកប្រចាំជីវិតរបស់ព្រះនាង មិនថ្វាយប្រផ្នូលល្អដល់ព្រះនាងសោះ ដូច្នេះកាលណាត្រូវរៀបចំព្រះនាងឲ្យមានស្វាមី សូមព្រះអង្គប្រយ័ត្ន កុំប្រាប់ឈ្មោះស្វាមីឲ្យព្រះនាងទ្រង់ជ្រាបជាមុនឲ្យសោះ » ។

លុះដល់ថ្ងៃកំណត់ហើយ ក៏ពបអាពាហ៍ពិពាហ៍ព្រះនាងជាមួយតែនឹងព្រះខ័នរបស់ស្វាមីតាមទំនាយទៅ ឥន្ទ្រាជិតសិង្ហក៏នាំបណ្ដាការរបស់ស្វាមីព្រះនាង ទៅថ្វាយព្រះនាងតាមទំនៀមហើយក៏សច្ចាថានឹងគោរពកិរិយារបស់ព្រះរៀមលុះអស់កិច្ច ។ ព្រះលក្សណ៍ទ្រង់គោរពព្រះរាមជាច្បងយ៉ាងណាមិញ ឥន្ទ្រាជិតសិង្ហ ក៏គោរពបងរបស់គេយ៉ាងនោះដែរ ហេតុនោះហើយទើបនៅពេលរៀបមង្គលការ ដែលព្រះរាជធីតាត្រូវបើកព្រះភក្ត្របង្ហាញព្រះអនុជថ្ងៃនោះ ឥន្ទ្រាជិតមិនហ៊ានងើបមុខមើលព្រះនាងទេ ទៅជាឈ្មោកសំឡឹងព្រះបាទព្រះនាង ដែលបន្ទំលក្ខណ៍ក្រហមរលោងឯណោះទៅវិញ ។

ថ្ងៃបន្ទាប់មក ឥន្ទ្រាជិតទៅស្ដេចព្រះនាងឲ្យគង់ក្នុងបុស្បុកល្អវិចិត្រ រួចក៏នាំរេហ៍ពលដង្ហែព្រះនាងទៅព្រះនគរខ្លួន ។ មុនពេលក្បួនដែលដង្ហែចេញទៅព្រះចៅក្រុងកុងដេវេក៏ ទ្រង់នឹកឃើញទំនាយតាបស ទ្រង់ព្រួយព្រះរាជហ្ឫទ័យក្រៃពេក ក៏លើកព្រះហស្តស្ដាំទៅដាក់លើព្រះកេសាបុត្រីជានិមិត្តរូបនៃព្រះពរដ៏ប្រសើរបំផុត ព្រះអគ្គមហេសីទ្រង់មានព្រះទ័យក្ដួល

ណាស់ លាព្រះរាជធីតាបណ្ដើរ បង្ហូរទឹកព្រះនេត្របណ្ដើរ ។ នៅទីអាកមនានាព្រះសង្ឃ នាំគ្នាស្វាធ្យាយធម៌ជយន្តោដើម្បីចម្លងព្រះនាងឲ្យចាកផុតអំពីគ្រោះកាចដែលគេទាយទុកនោះ ។

ក្រុងកុងដេវើរម៉ែនៅឆ្ងាយអំពីក្រុងម៉ាឌូរ៉ាណាស់ គេត្រូវចំណាយពេលមួយខែទើបទៅដល់ ។ ក្រោយពីបានធ្វើដំណើរអស់ ១ ថ្ងៃហើយ លុះពេលល្ងាច ពួករាជពុត្រទាំងនោះនាំគ្នាបោះជំរុំសម្រាកនៅក្បែរមាត់ទន្លេវេតស្ហា ពលរេហ៍ទាំងប៉ុន្មានរៀបចំនឹងចូលសម្រាកស្រាប់តែក្រឡេកទៅក្នុងព្រៃឃើញភ្លើងចន្លុះសន្ធោដេរដាសដើរតម្រង់មក ឥន្ទ្រាជិតប្រើទាហានម្នាក់ឲ្យទៅមើលបម្រើត្រឡប់មកវិញទូលព្រះអង្គថា „ភ្លើងដែលយើងមើលទៅឃើញនោះ គឺពួករាជពុត្រដូចយើងហ្នឹង ១ ក្រុមគេត្រឡប់មកពីរៀបអាពាហ៍ពិពាហ៍ដូចយើងដែរ គ្នាខ្លាចជួបគ្រោះកាចតាមផ្លូវ ទើបចូលមកសុំជ្រកកោននឹងយើង ឲ្យបានជាគ្នាក្នុងការធ្វើដំណើរតាមផ្លូវឆ្ងាយនេះ តែគេមិនមានដំណើរស្របតាមយើងរហូតទេ” ។

ទ្រង់ព្រះសណ្ដាប់ហើយ ព្រះអង្គម្ចាស់ក៏ត្រាស់ថា “ចូរឯងឲ្យគេមកចូលជាមួយនឹងយើងផងចុះ បើមានអាសន្នយ៉ាងណា យើងនឹងជួយការពារឲ្យ កុំឲ្យគេព្រួយ នេះជាកិច្ចដែលយើងពេញចិត្តនឹងទទួលជាទីបំផុត„

ជនទាំងពីរពួកក៏មករួមបញ្ចូលគ្នា ដើម្បីបន្តដំណើរទៅទៀត ។

យប់ស្អែកឡើង គឺត្រូវលើថ្ងៃខងាច់ ក្នុងដំណើរមើលទៅមុខ

ឃើញផ្លូវក្នំមួយវែងអន្លាយ ឆកទៅក្រោយវិញ ព្រៃឈើដ៏ក្រាស់ គេក៏នាំគ្នាសម្រាកនៅទីនោះទៀត ។ មិនយូរប៉ុន្មានពួកទ័ពសេះដែលបាននឿយហត់ក្នុងការធ្វើដំណើរ ក៏លង់លក់ស្កាត់ស្ងប់ ហាក់ត្រូវសណ្ដំនៃសូរទឹកធ្លាក់ចុះទៅជ្រោះ ។

ខណៈនោះ ការជ្រួលច្របល់មួយយ៉ាងសម្បើម បានផ្ទុះឡើងមួយរំពេច ធ្វើឲ្យពួកពលភ្ញាក់ក្រញេងក្រញាងក្នុងជំរំពួកម៉ាឌូរ៉ា សេះទាំងប៉ុន្មានដែលគេបានចងពីល្ងាច ស្រាប់តែផ្អើលដាច់ រត់ប្រសេកប្រសាច ជំរំខ្លះឆេះ អណ្ដាតភ្លើងឡើងក្រហមរន្ទាលអស់ទាំងមេឃ ។

ឃើញសភាពដូច្នោះភ្លាមពួកអ្នកដំណើរយល់ភ្លាមថា គ្មានអ្វីក្រៅអំពីការវាយប្រហាររបស់ពួកចោរកម្មឡើយ ការវាយតស៊ូយ៉ាងសាហាវក៏ចាប់ធ្វើឡើងគ្មានបង្អង់ ក្នុងពេលប្រយុទ្ធពួកច្របូកច្របល់នោះ មិនដឹងណាជាចោរ ណាជាពួកគ្នាឯង ម៉្លោះហើយពួកចោរក៏បានឱកាសវាយលុកយកជោគជ័យ ហើយប្លន់យកទ្រព្យសម្បត្តិ រត់កៀសខ្លួនចូលគុំអស់ ។

ផុតអំពីការជ្រួលច្របល់នោះទៅ ព្រះអង្គម្ចាស់ក្សត្រីចន្ទ្រាក៏បាត់ទៅដែរ ដោយព្រះនាងភ័យពេករត់តាមគេទៅ ស្មានជាគ្នាឯង ។

ឯពួកអ្នករត់ទាំងនោះ គឺជាក្រុមដែលបានចូលមកសុំធ្វើដំណើរជាមួយកាលពីថ្ងៃមុន ហើយស្ដេចស្រីរបស់គេនោះ ចោរវាចាប់បានយកបាត់ទៅ ប៉ុន្តែគេស្មានថាព្រះនាងចន្ទ្រានេះហើយដែលស្ដេចបានប្រគល់មក

ឲ្យគេជូននោះ ក៏ខំតែស្រូតនាំព្រះនាងទៅ ដើម្បីឲ្យបានដល់ស្រុកឆាប់ ក្រែងមានភ័យអន្តរាយមកដល់ថ្មីទៀត ។

ស្រុករបស់ក្រុមនោះជាស្រុកតូចមួយ ស្ថិតនៅលើមាត់ព្រែកជីក ។ លុះបានពេលល្អហើយ គេក៏រៀបចំនាំព្រះនាងទៅថ្វាយបង្គំព្រះអង្គម្ចាស់ជេតសិង្ហជាស្វាមីរបស់ក្សត្រីដែលពួកចោរចាប់ទៅនោះ ។

គ្រួសាររបស់ព្រះអង្គម្ចាស់ជេតសិង្ហ ចេញមកទទួលព្រះនាងចន្ទ្រា ហើយលាន់មាត់សរសើរអំពីសម្ផស្សព្រះនាងគ្រប់ ៗ គ្នា ។ ព្រះវរមាតាព្រះអង្គទ្រង់ចេញមកទទួលព្រះសុណិសា នាំទៅប្រគល់ឲ្យព្រះរាជបុត្រ ពិធីផ្សេងៗក៏ចាប់ធ្វើជាបន្តបន្ទាប់គ្នាតាមទំនៀមទៅ ។

ព្រះអង្គម្ចាស់ជេតសិង្ហ សព្វព្រះរាជហឫទ័យនឹងព្រះជាយាពន់ពេកណាស់ ដោយរូបឆោមលោមពណ៌ព្រះនាងល្អផង ដោយព្រះនាងចន្ទ្រាចេះបំពេញករណីយកិច្ចជាភរិយាគ្រប់បែបយ៉ាងចំពោះព្រះអង្គផង ហើយទ្រង់ស្រឡាញ់ព្រះស្វាមីស្មើជីវិតផង មិនបានប៉ុន្មានថ្ងៃផង នៅពេលដែលព្រះអង្គម្ចាស់ជេតសិង្ហ ទ្រង់ប្រាស្រ័យក្រសាលជាមួយនឹងព្រះនាង ក៏ទ្រង់ជ្រាបថាជាយាព្រះអង្គនេះ គឺជាព្រះនាងចន្ទ្រាទេ មិនមែនជាក្សត្រីដែលព្រះអង្គបានទៅដណ្តឹងនោះទេ !

# វគ្គទី ២៦

មកដល់ត្រង់នេះ នាងកាមាលាសួរក៉ាមេស្ហា ៖

-បើអីចឹងធ្វើម្ដេចទៅបង? (នាងបានស្ដាប់រឿងនោះដោយយកចិត្តទុកដាក់ណាស់មែន បានជាឆ្ងល់)។

ក៉ាមេស្ហាឆ្លើយ ,

-ខ្ញុំមិនដឹងថាយ៉ាងម៉េចទៅទៀតទេ

តើកាមាលាឯងយល់ថារឿងនោះត្រូវចប់ដូចម្ដេចទើបសម ?

-ទេ ទេ ! បងត្រូវនិយាយឲ្យចប់ទៅ មកសួរខ្ញុំម្ដេច អីចឹងទៅវិញ ? ។

-មែនណាកាមាលា ខ្សែទី ១ ចប់តែត្រឹមហ្នឹងហើយខ្ញុំមិនដឹងថារឿងនោះយ៉ាងណាទៅទៀតទេក្នុងខ្សែទី ២ ។

-បងឯងនេះចំតែម្ដងហើយ និយាយអីមិនឲ្យចប់ទេ

-ត្រូវចឹងនឹងអ្នកនិពន្ធឯនោះទើបត្រូវ . . .បងដឹងអី បើគេមិនបន្ត

ប៉ុន្តែខ្ញុំចង់ឲ្យនាងប្រាប់ខ្ញុំថា តើជេតស្ហិងត្រូវធ្វើដូចម្ដេច ? បើដឹងថាព្រះនាងចន្ទ្រាមិនមែនជាព្រះជាយារបស់ព្រះអង្គដូច្នោះ ។

នាងកាមាលាគោលខ្សែភ្នែកឆ្ងាយទៅលើផ្ទៃទន្លេ សញ្ជឹងគិតមួយសន្ទុះទើបឆ្លើយមួយៗ ថា ៖

-ខ្ញុំមិនដឹងទេហ្នឹង តែមិនដឹងថាត្រូវធ្វើម្ដេចទេ ។

ក៏មេស្ហសម្ងំចាំស្ដាប់ចម្លើយនាងមួយសន្ទុះ ទើបចាប់និយាយត
ទៅទៀត ។

– បងជាដេតសិង្ហត្រូវតែនិយាយការពិតប្រាប់ព្រះនាងចន្ទ្រាណា ?

–បងនិយាយអី អីចឹង ? ចុះបើនិយាយទៅ តើអ្នកទាំងពីរទៅជា
យ៉ាងណាទៅ ពីបាកចិត្តស្ដាប់ហើយបង !

–មែនហើយ ឥឡូវយើងឧបមាថា ...

–ឧបមាថាអីបង ?

– ថាខ្ញុំជាដេតសិង្ហ កាមាលាឯងជាព្រះនាងចន្ទ្រា ...

–បងកុំនិយាយលេងអីចឹង ខ្ញុំមិនចូលចិត្តទេ

–ទេខ្ញុំគ្រាន់តែចង់ដឹងថា តើករណីយកិច្ចរបស់ខ្ញុំត្រូវធ្វើដូចម្ដេច
ប៉ុណ្ណោះទេតើ ។

ប៉ុន្តែនាងកាមាលាមិនឆ្លើយ បែរជាក្រោកដើរចេញកន្លែង ទុកក៏
មេស្ហឲ្យនៅអង្គុយគិតតែឯង ។ នាងដើរចូលទៅក្នុងបន្ទប់សីនៃជាន់
អ៊ុយមេស្ហដែលអង្គុយក្លួចខ្លួននៅមាត់ទ្វារ ។

–អ៊ុយមេស្ហដែលខ្លាចលងទេ ? (នាងសួរក្មេង )

– បាទដែលម្ដងដែរម៉ែ

- រាលងធ្វើម្ដេចខ្លះទៅ និយាយប្រាប់ម៉ែមើល ? (នាងកាមាលា
ទាញជើងម៉ា ៗ មកអង្គុយក្បែរក្មេង) ។

ក៏មេស្ហមិនហៅនាងត្រឡប់មកវិញទេ ព្រោះដឹងថានាងខឹងមែន ៗ ទៅលើផ្ទៃមេឃ ចំណិតព្រះចន្ទតូចមួយសន្សឹមចុះទៅក្នុងគុម្ពោតឫស្សី ពួកសារិកនាំគ្នាចុះ សេចៗ ទៅរកចាយបរិភោគនិងរកកន្លែងសម្រាកពួកអ្នកដំណើរនាំគ្នាចុះទៅរកម្ហូបអាហារសម្រាប់ពេលល្ងាចបន្តៗ គ្នា នៅឯលើគោកឯនោះ គេឃើញពន្លឺភ្លេត ៗ តាមចន្លោះស្លឹកឈើខ្ទៅស្ទុង យូរៗ កញ្ចាល់អង្គើមង ដោយកម្លាំងទឹកហូរប៉ះខ្ទាំងទៅលើខ្សែយុក្ខា ៗ

ក៏មេស្ហនៅអង្គុយសញ្ជឹងគិតម្នាក់ឯង ក្រោមផ្ទៃមេឃដ៏ល្វឹងល្វើយ ព្រោះបញ្ហារបស់អ្នកនោះស្មុគស្មាញ ពាំឲ្យអ្នកខ្វល់គំនិតអស្ចារ្យ គឺថាត្រូវចោលកាមាណាឬហិមណាលីទ ? បុះបើទុកទាំងពីរនាក់នៅជាមួយគ្នាទៅវិញ តើរាំយ៉ាងណា ប៉ុន្តែទោះជាអ្នកគិតឃើញថា បញ្ហានេះពិបាកយ៉ាងណា ក៏គេនៅតែយល់ច្បាស់នូវករណីយកិច្ចរបស់គេដែរ គឺថា នាងហិមណាលិទ នឹងអាចផ្លាស់ចិត្តទៅបាន នាងអាចបំភ្លេចរឿងចាស់ ហើយទទួលគូដណ្ដឹងថ្មីទៀតបាន ឯរូបគេនេះ មិនមែនជាពិសេសអ្វីជាងអ្នកដទៃទេ ចំពោះរូបនាងកាមាណាវិញ តែអ្នកលែងនាងចោលទៅ វិស័យដូចជាទូកនៅកណ្ដាលមេទន្លេ ព្រោះនាងគ្មានអ្នកណាជាទីពឹងសោះ ៗ ទោះជាយល់ឃើញច្បាស់យ៉ាងនេះហើយក៏ដោយ ពុទ្ធោអើយ ! ចិត្តបុរសដែលគិតតែបំរើចិត្តខ្លួនមួយប៉ុណ្ណោះ មានទៅសុខចិត្តឲ្យនាងហិមណាលិទបំភ្លេចរូបខ្លួន ដើម្បីទៅរកសុភមង្គលក្នុងរង្វង់ដៃបុរសដទៃក្រៅឯណា

កើតអំពីដៃខ្លួន? គ្រាន់តែទឹកដល់នេះភ្លាម សេចក្ដីស្នេហារបស់អ្នកចំពោះ
នាងរឹងរឹតតែខ្លាចផ្សាខ្លាំងឡើង ។

ក៉ាមេស្ហូយកដៃទាំងពីរទ្រក្បាល គេត្រូវសួរចេចកល្អក្រលួចល្មើយៗ ពីចម្ងាយ បណ្ដាលឲ្យហ្វូងក្ដែស្រុកផ្អើលព្រួសលាន់ទ្រហឹង ក៉ាមេស្ហូងើបក្បាលឡើង ឃើញនាងកាមាលាឈរនៅជិតអ្នក អ្នកស្ទុះងើបឡើងហើយ និយាយថា :

–មិនទាន់គេងទេកាមាលា ថ្ងៃនេះហើយ ?

- ចា៎ ខ្ញុំទៅគេងឥឡូវហើយបង ខ្ញុំលើកពូកខ្ញុំមកដាក់ជិតបងហើយ បងក៏ត្រូវចូលសម្រាន្តដែរ យប់យូរណាស់ហើយណា៎ ។

តាមពិតគឺនាងកាមាលាខ្លាច មិនហ៊ានចូលគេងតែឯង ក្រោយអំពីបានស្ដាប់ក៊ុយមេស្ហូនិយាយរឿងខ្មោចលង ប៉ុន្តែនាងមិនហ៊ានសារភាពប្រាប់ក៉ាមេស្ហូ ក៏ដើរធ្មើយតិច ៗ ចូលទៅក្នុងបន្ទប់ ក៉ាមេស្ហូឃើញដូច្នោះទើកអាណិតក៏ស្រែកប្រាប់នាងថា ៖

–កុំខ្លាចអី កាមាលា បន្ទប់ខ្ញុំនៅជាប់នឹងបន្ទប់កាមាលាឯងទេ តើខ្ញុំមិនបិទទ្វារធ្ងន់បន្ទប់នោះទេ ។

– អ្នកណាថាខ្ញុំខ្លាច ? បង ! (នាងឆ្លើយទាំងបំពាន)

ត្បិតដូច្នោះ ក៉ាមេស្ហូគិតក្នុងចិត្ត «បើយ៉ាងហ្នឹងតើឲ្យអ្នកបោលនាងម្ដេចទៅ ល្ហើយ ! ខ្ញុំលែងកកើតទៀតហើយ ឈប់គិតដល់នាងហ៊ុបណាលីនី

តែប៉ុណ្ណោះជាការស្រេច ប៉ុន្តែ គិតទៅគិតមក អ្នកនៅតែយល់ថា ការអៀនខ្មាស និងសេចក្តីវេទនារបស់អ្នកនៅតែធំ ហើយគ្មានព្រំដែន វិស័យដូចជាផ្ទៃមេឃនិងពេលវេលាដូច្នោះដែរ ។ ឯសេចក្តីស្នេហារបស់អ្នកក៏ប្រៀបបាននឹងពន្លឺនៃតារា ដែលដេញផ្ទួកៗនៅលើក្បាលអ្នក ហើយមិនអាចរលត់បានយ៉ាងនោះដែរ អ្នករំពឹងគិតទៀតថា តើទឹកទន្លេនៅតែហូរច្រោះខ្សាច់ដូចឥឡូវនេះ ប៉ុន្មានទិវាទៅទៀត ? ឱ ! ពុទ្ធោអើយ លុះណាតែសរីរៈរាងកាយរបស់ខ្ញុំហុយជាផេះ រលាយសាច់មួយទៅនឹងផងព្រះធរណី ទើបគេឃើញសេចក្តីស្ងប់ជាអវសាននៃជីវិតខ្ញុំឃើញ ។

(នៅមានត)

# ល្បើកអក

(ចម្លងពីសាស្ត្រាស្លឹករឹត)

## ពាក្យ ៧

បានជួបបានជួនបានឃើញប្តី ឃើញស្រីហើយស្រស់មិនឲ្យហ្មង
ឃើញស្រីទំពិតជិតខាងបង ស្រស់ឆោមមិនហានដើរទៅជិត ៗ
និយាយស្រីព្រានតែពីក្រៅ ទឹងហៅក្រែងបងអាក់អន់ចិត្ត
បងសោកធ្វើតើយហាក់មិនស្បិត ទុ អាសូរចិត្តអាណិតស្រី ៗ

## ពាក្យ ៩

អាណិតស្រស់មិនគួរសោះបើមកប្រាស
អាណិតមាសមិនគួរសោះបើឃ្លាតថ្លៃ
អាណិតស្ងួនមិនគួរសោះបើមកកក្យ័យ
អាណិតថ្លៃមិនគួរបើបង់ចោលបង ៗ
មិនគួរបើបងមកប្រែបែរបែកចិត្ត
មិនគួរបើឲ្យបងគិតក្បត់ទងវង់
មិនគួរបើបងចោលប្អូនស្ងួនត្រមង់
មិនគួរសោះឲ្យបងបង់ប្អូនកំព្រា ៗ
នៅកំព្រឹងរឹងកំព្រោនរនកំព្រាយ
ព្រោះចិត្តឆ្លោយបេបណ្ដាយធ្លាក់ទៅយតណ្ហា

ពោលទូននាងនិច្ចនិត្យនៅអង្គឯកា
ឈឺឱកផ្សាឱរ៉ើមិនកូន ។
អកខ្ញុំតាំងតែអំពីពាន់ព្រលប់
លង់លុះយប់គំរប់យាមពីរបីបួន
ស្រែកយំណាស់បម្រះទីងពុំដឹងខ្លួន
ព្រាសព្រាណសូន្យស្មន្ធប់លន់បាត់ស្មារតី ។
ព្រះពាយផាយផាត់ខ្ញាត់មកពាល់ដល់កាយ
រំហើយផាត់រំហើរផាយសាយសព្វព្រៃ
សន្សើមសោតចុះជ្រុះធ្លាក់មកដល់ថ្ពី
ភ្ញាក់ស្មារតីស្រែកយំខ្ញុំទំនួញថា ។
ឱប្អូនស្ងួនទួលកំសត់មាសបងអើយ
ឱះម្ដងឡើយខ្លួនបាត់ទៅបានឯណា
អកយំខ្ញុំទំនួញល្វើយកងអធ្យា
កណ្ដាលយប់សន្ធិយាជ្រៅស្ងាត់ ។
កណ្ដាលយប់ញាត្រទៀបទៅផាស់ទំ
គ្រួសក្ដូយំបន្លឺស្នូរស្រងាត់
អកសង្រើនតែនឹងព្រៃកាលីយក្ដាត់
អែកសត្វសាយសោកសែនសំខេយ្យ ។

អកទំនួញទួញយាសយំទុរគមគិត
ខ្មោចពោកបល្អិតធ្អិតធ្អន់ណែនតក្តន់ឧក
អណោចគិតអាណិតកូនវែងខ្មោចផ្សា
ឈឺកាយាផ្សាការយៃតម្នាក់ឯង ៗ
អកខ្ញួញទៀតបង្អៀតចិត្តអាណិតខ្លួន
ជាទុកមួនប្រមួនថប់គ្រប់កន្ទែង
គ្រប់កន្ទៀតប្រចៀតសព្វគ្រប់ទីល្បែង
គ្រប់ចឹងខ្វែងកន្ទែងជ្រោះអូរឈូងឆក ៗ

( ពាក្យ ៧ )

គ្រប់ចឹងត្រពាំងទាំងព្រៃភ្នំ គ្រប់អូរតូចធំគ្រប់ជ្រោះប្រែក
គ្រប់ណើគ្រប់ព្រៃគិតលែលក ខំស្វែងហើររកបាប់មច្ឆា ៗ
អកសោកខ្សៀបរាប់ទីកន្ទែង ទ្រហោក្តែង ៗ ក្នុងអត្តា
តាំងពីព្រលប់យប់សន្ធ្យា លុះព្រះសុរិយារៀបនឹងរះ ៗ
អកខ្នៀងរកមើលកូនប្រពន្ធ សព្វគ្រប់ដំបន់ទិសទីផ្ដាស
ពុំឃើញប្រពន្ធនឹងកូនមាស អកប្រាសហើរចុះទៅដល់ដី ៗ
អកឈោករកកូនក្រោមមណ្ឌល ក្សៀរាយល់ប្រពន្ធកូនទាំងបី
ស្លាប់គរតម្រួតគ្នានៅដី អកខ្ទីខ្ទបខ្មោចកូនសោកា ៗ
ទុកែវព្រាត់ពីទាំងបីអាស ម្ដេចឡើយមកប្រាសស្លាប់អសារ

ឬមួយក្រែងអកអត់អាហារ　　ព្រោះកម្មវេរពីព្រេងនាយ ។
ឲ្យបានយើងប្រែបែរព្រាត់ប្រាស　　ទិពសុខាយខាត់ប្រាសព្រាត់ព្រាយ
អកឪពុកបាទៅឯនាយ　　ចោលកូននៅឆាយរងវេទនា ។
កូនអើយនេះហើយហេតុតែកម្ម　　ពីព្រេងនាយនាំឲ្យឪបា
ឲ្យស្រើបឲ្យស្រាលដោយតណ្ហា　　ចោលកូនសង្កាទាំងពីរនៃ ។
ពុំគួរបាកើតមកឥតក័ព្វ　　មកស្លាប់នៅនាកណ្ដាលព្រៃ
កូនអើយឪនឹកឡើងស្រមៃ　　ហាក់ថ្លៃនៅរូបរស់នៅឡើយ ។
អកខ្ពញឪបខ្មោចកូនប្រពន្ធ　　រងថែមទុក្ខធ្ងន់ពុំមានស្បើយ
បម្រះនេះនៀលសោកល្វើយ ៗ　　ឪបកើយខ្មោចកូនសន្ធប់លង់ ។
ដូចះគប្រេគទាំងបីបួន　　សន្ធប់សុងសួន្យពុំលើកអង្គ
តាំងពីព្រហាមលុះថ្ងៃត្រង់　　អកពុំភ្ញាក់ភ្ញាក់ដឹងស្មារតី ។
ភ្នំយោផាយផាត់ក្លិនគន្ធា　　ចូលផ្សព្វកាយាអកបក្ស
បានភ្ញាក់ដឹងខ្លួនហើយយំខ្មី　　ឪបស្រីអកខ្ពញទំនួញគ្រប់ ។
ស្រណោះអកយំពេលថ្ងៃត្រង់　　រន្ធត់អស់អង្គខ្ពញស្ញាប់
ឪកែវិណាសមាសទឹកដប់　　. . . . . . . (១) ។
ពីដួចបងកព្វនឹងប្អូនស្រី　　ចូរប្អូនប្រណីណានាងអើយ
ពីកាលស្រីទៅតាមថ្ងៃតើយ　　ស្រីអើយបងសូមសុំសប្ដា ។

---

១-ត្រង់នេះ ក្នុងសាស្ត្រាដើមបាត់មួយឃ្លាដូច្នេះ ឯច្បាប់ខ្លះដែលបោះពុម្ពហើយមិនមាន សេចក្ដីវែងមកដល់នេះទេ ។

ខឹងត្បិតបងអកមានប្រពន្ធ ពោលទួនពោលនាងនៅឯកា
នាងផ្សងឥន្ទព្រហ្មសុំសច្ចា ប្រាថ្នាមិនឲ្យជួបនឹងបង ។
បងបានជាឆ្ងាយនឹងប្អូនស្រី សេចក្តីបងអ្នកឃើញជាឆ្គង
ថ្ងៃនេះបងសូមសច្ចាផង សូមចងជាតិមុខជាសង្សារ ។
ទើបអកឱនអង្គហើយក្រញូក្រាប កាន់ស្លាបបង្គំគ្រប់ទិសា
អកផ្សងឥន្ទព្រហ្មទូវទេវតា សូមសុំសច្ចាបានដូចការ ។
ក្នុងជាតិនេះខ្ញុំមកព្រាត់ប្រាស ទ័ាសប្រពន្ធកូនពីរប្រាណ
ជាន់នេះជាតិនាយកុំឲ្យមាន សូមចងជាស្ពានទឹងកូនថ្ងៃ ។
សូមឲ្យមូលមកកុំឲ្យខាន ឲ្យបានដូចខ្ញុំប្រាថ្នាទេ
សូមជាសង្សារនឹងប្អូនស្រី នូវកូនមាសថ្ងៃទាំងពីរពង្ស ។
អកផ្សងសច្ចារួចស្រេចឡុះ ទទះស្លាបហើរឡើងពុំលង់
ទំលើចុងឈើធ្វើឡូនឡង់ ខំផ្ចង់ស្មារតីតម្រង់កាយ ។
ហើយអកស្រែកផ្តាំទឹកថ្លៃ ទ្រហោក្តួងៗសព្ទសោយ
យំពេលថ្ងៃត្រង់លន្លោចឆ្ងាយ ហើយអកឱនកាយស្រយាកជ្រប់ ។
ថាឱទីឋានព្រៃនេះហើយ ឋានអើយយើងធ្លាប់ពីរវែងឈប់
ធ្លាប់កាច់ស្លឹកឈើធ្វើជាម្ជប់ ជាស្រមប់ឲ្យស្រីរក្សាកូន ។
ឥឡូវគ្មាននៅទីកន្លែង រលីងខ្លួនធេងបាត់សោះសូន្យ
ឋានអើយកម្មព្រេងៈយើងទាំងប្អូន មកជួនជួបទីឋានខ្ញុំអើយ ។

បានអើយថ្ងៃនេះខ្ញុំសូមលា　　ខ្ញុំនឹងមរណាឥឡូវហើយ
ស្តាប់កូនប្រពន្ធខ្ញុំអស់ហើយ　　បានអើយនេះខ្ញុំលាបានទៅ ៗ
អកផ្តាំទីបានជានកន្ទេង　　ស្ទុះស្ទែងហើរហិចគេចសំដៅ
ហើរឡើងតម្រង់អាកាសស្ងៅ　　សំកាំងស្ទាចទៅកាំងឈប់ឈរ ៗ
អកទួញថាឱអាកាសអើយ　　និយាយផ្តាំហើយហើរចេញចរ
លីលាហើរទៅលើអម្ពរ　　ររក់ស្រែកយំនិយាយថា ៗ
ខ្ញុំប្រាសប្រពន្ធនិងកូនថ្ងៃ　　អាកាសអើយថ្ងៃនេះខ្ញុំលា
ខ្ញុំនឹងរងគ្រាំវេទនា　　ខ្ញុំសូមមរណាឥឡូវហើយ ៗ
អកនឹកតែប្អូនកូនតូចគ្រង　　ស្ងួនអើយខ្លួនបងមិនមានស្បើយ
កម្មកួចមកផ្តាច់ក្នុងខ្លួនហើយ　　ប្អូនអើយបងរឹងក្តៅខ្លោចផ្សា ៗ
អកស្រែកច្រេះហោយំក្តែងៗ　　សូរសព្ទល្ងើយល្ងើងក្នុងអព្ភា
ដូចមនុស្សវង្វេងស្រែកហៅគ្នា　　មុខគួរអនិច្ចាអកបក្សី ៗ
ក្សិណអកសម្រេចឱបអង្គកាយ　　ពុំមាននឹកស្តាយខ្លួនឡើយនៃ
នឹងឲ្យមរណាតាមប្អូនស្រី　　អកធ្លាក់ដល់ដីលុះបង់ផាត់ ៗ
និយាយចាចែងថ្លែងស្រដី　　ពីសត្វបក្សីជាអកសត្វ
លើកលយតាមដោយន័យបរមត្ថ　　រឿងនៃពាក្យសត្យសច្ចានោ ៗ
　　ថ្លែងពីអកញីមេម៉ាយវិញ　　កាលឈ្មោលចរចេញហើរហួសទៅ
ក្នុងចិត្តតែកក្កុកក្កួលក្តៅ　　ទុកម្នាមម្ដៅមិះចេញស្តី ៗ

អ្នកទឹករលឹកសាប់សង្វារ គិតថាឲ្យប្រុសសំឡាញ់ថ្មី
ទើបកត្យប្រុសត្វទឹងប្អូនស្រី កម្មអ្វីឲ្យប្រុសអ្នកប្រាសទៅ ៗ
អកុសលផ្តល់ប្អូនអ្វីម្ល៉េះទេ អស់គេមើលដូចជាប្អូនពៅ
ប្តីមុនឥតក័ត្វស្លាប់ចោលទៅ មិញនៅពោលខ្ញុំនសូឲ្យកំព្រា ៗ
ត្រាំនៅមេម៉ាយកាយកើតទុក្ខ វិតក្កពល់ពេលកាល់វេលា
ចំណាំយប់ព្រឹកមិនទឹកនា ឲ្យជាទីរទេសធ្វេសស្មារតី ៗ
ទាល់បានរួមប៉ានទឹងអ្នកប្រុស រក្សរសស្នេហ៍ជាស្វាមី
ប្អូនផ្ទង់ចិត្តចាប់ចាំជាប្តី ជាម្ចាស់ប្អូនស្រីដល់អស់ជន្ម ៗ
មិនដឹងកម្មអ្វីឲ្យប្រុសប្រែ ប្រុសប្រាសប្អូនស្នេហាយូរលង់លន់
ប្អូននៅម្នាក់ឯងតែងទុក្ខធុន់ ទូរទន់ឥតល្ហែតែសព្វថ្ងៃ ៗ
អកអើយអ្នកអកអ្នកឲ្យប្អូន និត្យនៅស្ងាត់ស្ងួនឲ្យពន់ពេកក្រៃ
រង់រងទន្ទឹងៈមើលផ្លូវថ្ងៃ ស្រមៃស្រមាក់ហាក់ថ្ងៃមក ៗ
សន្ទឹកផ្គរលាន់រន្ទាន់ធ្ងើយ រំភើយព្រះពាយផាយពពក
ទឹកបឹងល្ហើយល្ហឹងរង់រលក រលាបលោតជ្រែកចូលភមរង ៗ
ពពកសាត់ជ្រែកព្រៃពីក្សា ប្អូនស្មានជេដ្ឋាធូរក្នុងទ្រូង
អរពេកខំស្រែកហៅរលួង ឃោនឃោងប្រុងហើរទទួលថ្ងៃ ៗ
យល់ពិតមិនមែនជាមិត្តមក ជ្រប់ជ្រកផ្អកផ្អឹសទន្ទឹះក្រៃ
ក្រៀមក្រំជាទុក្ខតែកល់ថ្ងៃ ស្ទើរក្ស័យជីវិតគិតតែអ្នក ៗ

កាលប្រុសប្រាប់ប្អូនថាទៅឆាប់ ប្រញាប់វិលមករកគូស្នេហ៍
ថាបើសុខសាន្តគ្មានធុរៈ ប្រុសអ្នកវិលមករកប្អូនស្រី ។
ឥឡូវទៅបាត់បីថ្ងៃហើយ ប្រុសអើយក្រែងអ្នកមានក្រក្រី
ធុរៈទាក់ទិននឹងការអ្វី ប្អូនស្រីថប់ណាស់អ្នកថ្លៃអើយ ។
ស្រណោះទ្រទំទំពីរនាក់ រមែងក្បែរនៃបនិត្យជិតបង្អើយ
ឱធុំអ្នកជាក់ពុំមានស្បើយ ប្រុសអើយប្រុសធ្លាប់សព្វវេលា ។
ឥឡូវប្រុសទៅតែឯងអាទិ៍ សង្វាតហោះហើរលើវេហាស៍
ត្រូវថ្ងៃក្តៅក្រៃក្រៀមអង្គា ត្រូវភ្លៀងរងារំងាប់ចិត្ត ។
ឱធ្លាប់ប្រុសព្វនៅនឹងប្អូន ក្តៅខ្លួនបក់ស្វាបកាងជាផ្ចិត
រងាប្អូនកទៅផ្តេកផ្តិត ឱបរិតរួមកាយសប្បាយក្រៃ ។
អកញ្ញាវីវេកសង្វេគទឹក សន្ទឹកហាក់ហៀបទៀបនឹងក្ស័យ
ចំណីត្រីសាច់សឹងច្រើនក្រៃ អត់មិនអាស្រ័យដល់តិចឡើយ ។
អង្គុយតែយំទំសំកុក ដាក់មុខស្រពោនពេកពុំស្បើយ
ស្គមស្គាំងមុខមាត់មិនរីកឡើយ ល្ងង់ល្ងើយកម្លាំងកាំងស្មារតី ។
លុះភ្លឺយំថាឱអកអូ៎ អកទៅបាត់យូរហោលប្អូនស្រី
អ្នកមិនស្រណោះសោះអ្នកប្តី ឬមានក្រក្រីនៅឋាននាយ ។
ប្អូនរ៉ះប្អូនរង់ទុក្ខទ្វេញ ទ្រូងតឹងចង្អៀតស្ទើរនឹងធ្លាយ
បែកថ្លើមប្រមាត់ខ្ទាត់រុះពាយ គ្មានអ្នកបេះទាយឲ្យដឹងដាន ។

ប្អូនគិតតែវែងតែងអាឡោះ ស្រណោះពាក្យមត់ទឹងវិលថ្កាន
អ្នកផ្តាំប្អូនចាំនៅក្នុងប្រាណ ឥឡូវគ្រប់បានបីថ្ងៃហើយ ៗ
ខ្ញុំក្រែងអ្នកទៅដោយផ្លូវព្រៃ កើតហេតុភេទភ័យពុំដឹងឡើយ
ជាប់ដង់អន្ទាក់គេដឹងអើយ ប្រុសអើយប្អូនថប់គ្រប់ប្រការ ៗ
ថប់មួយព្រួយចិត្តត្រមនុស្សផង វាចងសន្ទូចយកមច្ឆា
ក្រែងអ្នកប្រុសប្រាណឃ្លានអាហារ ដោយសារហោះហើរហាលថ្ងៃក្តៅ ៗ
អ្នកប្តីឃើញត្រីជាប់សន្ទូច ស្ទុះប្រុចតម្រង់ត្រង់ស្ទុងស្ទៅ
ដល់បិចក្រចកតាប់ក្រពៅ សំដៅខុសត្រីត្រូវជើងជាប់ ៗ
ទឹងផ្ទៃសន្ទូចនៃនេសាទ សន្ធាតស្ទុះទៅសំពងជាប់
ប្រុសអើយប្អូនគិតតែរឹងថប់ ភ័យញ័រចំប្រប់ប្រាណប្អូនស្រី ៗ
ស្អែកហើយប្រុសអើយប្អូនទឹងទៅ តាមអ្នកប្រុសពៅជាស្វាមី
ឲ្យបានដឹងជានពីអ្នកប្តី ហេតុអ្វីក៏បានជាបាត់ម្ល៉េះ ៗ
អកញើជាទុក្ខសំកុកគិត កង់ចិត្តថៃថាត្រោម្តងនេះ
តាមប្តីឲ្យល្អាចខ្លោចជួបផេះ ជួបគ្នាសឹមនាំវិលមកបាន ៗ
បើប្អូនសោះសូន្យមិនជួបជិត មិនជួបជួនទឹងមិត្រប្តីបុកណា
ស៊ូស្លាប់អន្តរាយមិនស្តាយប្រាណ ទឹងរស់រូបខានមិនបានឡើយ ៗ
ទឹងរស់ថ្វីព្រោះប្តីមួយតើ អាប់គេអស្រូវអស្តីតតគ្រើយ
ចង់តែស្លាប់ឥឡូវឲ្យហើយ ប្រុសអើយក្រែងអ្នករស់រួចមក ៗ

ដល់ប៉ាន់ពុំបានយល់ប្អូនស្រី | អ្នកប្តីព្រួយចិត្តគិតហើររក
ដោយព្រៃត្អូចធំចំជ្រៀតជ្រក | ពន្លកយាប់យ៉ាកលំបាកកាយ ៗ
អ្នកយំយូរពេកស្រែកគ្មានឈប់ | តាំងពីព្រលប់លុះសូរ្យាឆាយ
រះរុងរឿងភ្លឺពន្លឺធ្លាយ | ព្រះពាយផាត់ផាយពពកមីរ ៗ
ត្រសុំត្រសែតអណ្តែតជ្រះ | ស្រឡះមេឃមើលមានរស្មី
គ្រានោះមេអកសត្វបក្សី | ហៀបហើរតាមប្តីផ្តាំទ្រទំ ៗ
ថានុះដើមស្រឡប់អ្នកនៅ | ខ្ញុំលាអ្នកទៅទិវូរគម
តាមរកអ្នកប្តីឯព្រៃភ្នំ | បើខ្ញុំទៅដល់យល់ស្វាមីហើយ(១) ៗ
ខ្ញុំគិតរកអ្នកជាទ្រទំ | តែងទំនិត្យនៅជាប្រក្រតី
បើខាងពុំបានជួបនឹងប្តី | លោកថ្លៃទ្រទំខ្ញុំលាស្លាប់ ៗ
ទ្រទំនៅក្រោយឲ្យសុខសាន្ត | កុំឲ្យមានមនុស្សណាមកកាប់
សូមឲ្យអ្នកលាប់ស្រស់ចំណាប់ | បើខ្ញុំស្លាប់ឲ្យរស់តែទ្រទំ
នុះនុចនឹងប្អូននឹងនិត្យនៅ | មិនគាប់បើទៅទីរគម
ស្រណោះកោះ ត្រីយល្ងើ[?] ធារធំ | ល្អូកទកជ្រោយជ្រុំជ្រើនអនេក ៗ
អកហើរដើរដោ[illegible]នគាល័យ | រំពៃមើលបឹងរំសាស្នេហ

---

១ - ត្រង់នេះជាត់ផ្លូវទៅឃ្លាឃ្លាយ តែយើងខំរិះរកនៅតែ ។ ឬខ្ចួយជាថា «បើខ្ញុំ [illegible] [illegible] ?

ទឹកផល់សង្ក្រាហាយំយែក ទឹកភ្នែកហូរស្រក់ហក់ហូរខ្ចាយ ៗ

ឈើជ្រុះដុះច្រើនដោយឈូងឆក មេអកមើលយល់ខ្លប់ក្នុងកាយ

ផ្អែតផ្អិតបិត្តទឹកមិនរសាយ ទឹកស្ដាយកន្ទ្វងតែងអាស្រ័យ ៗ

ខ្ញុំញាថានុណាអ្នកថ្លៃអើយ ទីត្រង់នេះហើយដែលអ្នកថ្លៃ

អ្នកហើរនាំប្អូនមកពល់ថ្លៃ ពិសម័យម្ចូលមិត្តស្និទ្ធស្នេហា -

នុកោះបន្ទោះកណ្ដាលបឹង ត្រង់ហ្នឹងអ្នកប្រុសតាប់មច្ឆា

បានមកឲ្យខ្ញុំបរិភោគា រៀមអើយឥឡូវទៅណាបាត់ ៗ

មិនមករកត្រីឲ្យខ្ញុំប្អូន ប្ដូនទៅក្នុងព្រៃស្ងប់ស្ងាត់

ហៅហើយមិនឆ្លើយប្អូនមួយម៉ាត់ ប្ដកាត់ចិត្តចោលសោះទៅហើយ ៗ

បើអ្នកសម្ងំទំត្រង់ណា មេត្តាឆ្លើយប្អូនកុំយូរឡើយ

អ្នកនៅព្រៃណាអ្នកប្ដីអើយ ប្រុសអើយអាណិតចិត្តប្អូនស្រី ៗ

ប្អូនអស់កម្លាំងកាំងកាយា អាហារប្អូនអត់ទេណាប្ដី

ប្អូនផ្អែតតែទុក្ខពល់ពត្រី ស្វាមីមិនមកយកប្អូនពី ៗ

ឱប្ដីសម្លាញ់ពញចិត្តប្អូន បាត់សូន្យតើអ្នកទៅឯណា

ទៅស្រុកស្រែ[illegible]ប្ដូបំការ ប្អូនមហាចំបែងតែងថប់ព្រៃ ៗ

ប្អូន[illegible] ស្រៀកជ្រកនាមកមរព្រៃ

ប្រាសប្អូនពេកទឹកអាល័យ　　អ្នកថ្លៃត្បិតធ្លាប់ប្រសព្វគ្នា ៗ
អ្នកយំបណ្ដើរហើរតិចទៅ　　ឃើញស្មោញទំនៅដើមទន្ទា
តាំងពីរកៀកកិតជិតគ្ប់　　អកកាងៀងឆាបទន្ទាបទំ ៗ
ប្អូនស្រណោះទឹកប្ដីស្ដីមិនរួច　　ក្រលួចកន្ទុំអង្គុចង់តែយំ
ប្រឹងហាថាបងអាណិតខ្ញុំ　　បងកុំលាក់លៀមនឹងប្អូនឡើយ ៗ
ក្រែងបងបានឃើញប្ដីខ្ញុំប្អូន　　គាត់មកបាត់សូន្យយូរណាស់ហើយ
មិនដឹងទៅណាអ្នកថ្លៃអើយ　　ស្មោញឆ្លើយថាប្អូនបងមិនដែល ៗ
ឃើញអកឯណាមករកត្រី　　លាក់ថ្ងូបងនៅនេះយូរក្រែល
បើមើលមិនជាក់ហាក់ប្រហែល　　ក្រែងទៅក្រវែលបឹងឯនាយ ៗ
អកស្ដាប់ស្មោញប្រាប់ប្រាកដស្មោះ ទុក្ខមនោទោមនស្សទឹកពាយមាយ
ក្ដៅថ្លើមបេះដូងទ្រូងស្ទើរធ្លាយ　　និយាយលាស្មោញប្រួញប្រឹងហើរ ៗ
ស្ទុះស្ទើតអើតកទទះស្លាប　　ស្រែកយំដកបរៀងបណ្ដើរ
បណ្ដាយព្រៃព្រឹក្សាសរសើរ　　ថាអើត្រង់ណេះអ្នកថ្លៃអើយ ៗ
ប្រសិនប្រុសប្រាណបានមូលមិត្ត　　ប្អូនគិតនាំអ្នកមកលេងហើយ
ព្រៃនេះល្អម្ល៉េះអ្នកថ្លៃអើយ　　ម្ដេចឡើយអ្នកប្រុសប្រាសមិននៅ ៗ
ព្រៃប្រែមាត់បឹងសឹងស្រួលស្រាង រំលោងរំលិចទឹកជ្រាលជ្រៅ
ជាកម្មប្រុសឲ្យមកប្រាសទៅ　　ប្អូនពៅពុំយល់អំពល់ទឹក ៗ
ស្មោញហើរបានតិចលេចឃើញក្អែក　　ទំមទំយំស្រែកសូរសន្ធឹក

ខ្ទះម្ជុលហែលហាក់កក់រើក    អកទឹកស្មូរក្អែកស្រែកទៅថា ៗ
អ្នកបងក្អែកទឹកធំនៅនេះ    ច្រើនម៉្លេះអ្នកមកពីទីណា
ប្រយោជន៍យកត្រីទៅពិសា    មេត្តាប្រោសប្រាប់ខ្ញុំដោយពិត ៗ
ក្អែកទឹកឮហើយឆ្លើយប្រាប់ទៅ    ព្រោះជ្រោះនេះឯងតែងនៅនិត្យ
ទីនេះសុខសាន្តគ្មានភ័យកិត    ចុះមិត្តឯងមកពីឋានណា
កំព្រាម្នាក់ឯងឥតគូគ្រង    ទំនងជាមិត្តមកមានការ
រវល់កលកិច្ចដូចម្ដេចម្ដា    ប្រាប់ក៏ទាសបងកុំហោនឡើយ ៗ
អកស្ដាប់ប្រាប់ក្អែកទៅតាមពិត    ថាមិត្តសំឡាញ់ម្នាស់ប្អូនអើយ
ប្អូនមានទុក្ខធំឥតស្បើយ    បងអើយកាលណានឹងបាត់ទុក្ខ ៗ
លាក់ថ្មីប្ដីប្រាសពីទ្រូងប្អូន    ស្ងាត់សូន្យទ្រនំនឹងសំបុក
ចោលប្អូនម្នាក់ឯងតែងតែក្ដុក    ប្រដុកប្រដំយំគិតគាត់ ៗ
ខ្ញុំត្រាំចាំមើលផ្លូវប្ដី    លាក់ថ្ងៃអាហារខ្ញុំក៏អត់
តែទឹកមិនទឹកស្រែកប្រាកដ    ឲ្យស្ងួចកំហាំងមិនមានទក ៗ
អ្នកបងនៅនេះជាប្រក្រតី    ក្រែងឃើញស្វាមីខ្ញុំហើរមក
ក្អែកស្ដាប់ប្រាប់ទៅដោយសាទរ    យើងរកស៊ីសព្វគ្រប់វេលា ៗ
ប្រទះខ្ទះដៃវៃតែគេមាន    គួរគួរមេបានមិត្តមូលគ្នា
ទឹងទំមកទំមិនឃ្លាតឃ្លា    យល់ជាពុំមែនជាគូប្អូន ៗ
ក្រែះតែហើរទៅត្រើយឯជើង    នោះយើងមិនដែលទៅសោះសូន្យ

បើបោះអ្នកថ្លៃម៉ែខានណូន ក្រែងជូនប្រទះនឹងគេឯង ៗ
អកស្លាប់ក្រឡាប់ណាក្អែកទឹក ហើរហោចរពុកនឹកយំក្តែង
ប្រឹងស្រែកទឹកក្អែកហូរហែង ចំបែងកុងចិត្តឥតស្រាកស្រាន្ត ៗ
ហើរកោតគម្រង់ត្រង់ត្រើយបឹង ក្អែកគយគន់ប្រឹងមើលដែនដាន
ដោយដែនដីឈើព្រឹក្សាសាន្ត ព្រឹក្សាសោតមានមិនឃើញប្តី ៗ
ឃើញខ្ទមចំខែងទំដើមកង ទំដើមរៃរតាំងទើបបក្ស
អកសត្វហើរកោតទៅដល់ខ្ទី ស្រដីសួរថាអ្នកបងខ្ទង ៗ
អ្នកបានឃើញប្តីខ្ញុំផងឬ គាត់ហើរហោលខ្ញុំមកតែឯង
ប្រាំពីរថ្ងៃហើយបងអើយក្រែង មកត្រង់កន្ទុងនៃអ្នកបង ៗ
បើបានឃើញជាក់កុំលាក់ឡើយ បងអើយអាណិតប្រាប់ប្អូនផង
ខ្ទងស្តាប់ឆ្លើយប្រាប់ទៅរងស្នង ថាបងមិនឃើញទេអ្នកថ្លៃ ៗ
បើបងឃើញជាក់នឹងលាក់ថ្វី ប្រាប់ស្រីតាមត្រង់កុំសង្ស័យ
សង្សារប្អូនប្រាសប្រាំពីរថ្ងៃ មើចថ្ងៃក៏បានជាព្រាត់គ្នា ៗ
អកស្តាប់ប្រាប់ខ្ទងថាបងអើយ មិនខបងស្តីឡើយរឿងប្អូនក្ង
កើតជាតិនេះមិញពេញវេទនា មេមាយពីគ្រានឹងនេះហើយ ៗ
ប្តីមុនចំណាប់ស្លាប់ទៅហោល ខ្ញុំនៅតែលគោលឯងឥតត្រើយ
កំព្រាផាំពុំមានស្បើយ ល្វេងល្វើយគំនិតគិតផេងផោង ៗ
រងទុក្ខរឿងកល់កាលមានប្តី ប្អូនស្រីបានហើរហោនចូលហ្វូង

បានស្បើយក្នុងចិត្តឥតឆេងឆោង  បានប្តីដំបូងដំបន់ចិត្ត ៗ
បានគ្រាន់ស្រន់ស្រាលស្រយាលទុក្ខ  រកមុខរកមាត់ប្រាកដពិត
សប្បាយក្នុងប្រាណគ្មានភ័យគិត  ព្រោះត្បិតបានប្តីជាត្រីមុខ ៗ
ឥឡូវនេះត្រូវគាត់លាប្អូន  ថាទៅសួរគ្រូនឯស្រែស្រុក
បើជាស្មោះស្មាទមិនមានទុក្ខ  ថាមុខជាមករកប្អូនឆាប់ ៗ
ឥឡូវទៅបាត់យូរថ្ងៃហើយ  បងអើយប្អូនភ័យស្ទើរនឹងស្លាប់
ខំហើរដើរមករកប្រញាប់  ប្អូនប្រាប់ចងអស់ប៉ុណ្ណោះហើយ ៗ
ខ្លែងស្លាប់អកប្រាប់សព្វសេចក្តី  ខ្លែងស្តីថាឱមាសបងអើយ
ជាកម្មអ៊ីប្អូនមិនមានស្បើយ  ស្រីអើយធ្វើម្តេចឥឡូវនេះ ៗ
តើកម្មពីព្រេងតែងតាមផ្តល់  អកប្អូនកុំឆ្ងល់វល់វិលវេះ
ប្រៀបដូចដំរីក្របីសេះ  មិនឆ្លុះហៅរួចពីគេប្រើ ៗ
ចូរប្អូនកំសាន្តកុំសោយសោក  កុំសែនអាមោកមិនប្រសើរ
នាំនឿយអាត្មាណាប្រឹងហើរ  បើម៉្លេះតើកាលណានឹងបានឆាប់ ៗ
មកស្រីយកត្រីទៅកោក្កា  មេវ៉ាកុំអត់កុំឲ្យស្លាប់
ស៊ីទៅប្អូនពៅបើប្រញាប់  តែស្តាប់ពាក្យបងកុំសង្កា ៗ
វិស័យៈហោះហើរប្រើកម្លាំង  មានហើយចង់ខ្លាំងដូចម្តេចម្តា
ចង់ឆាប់ប្រញាប់ដូចចិន្តា  ប្រសិនណាបើបានដូចនឹងប្តី ៗ
ស្បើយទុកជាសុខក្នុងកាយា  ញីញក់យ៉ាងណាអ្នកអូនស្រី

កម្លាំងមានស្រាប់ចំណាប់ថ្មី ចំណុចប្ដីចំណីប្អូនមិនសូន្យសោះ ។
មិនសូន្យទេមាសមេនាងជឿចុះ ស្រីប្រុសជួបប្រាណស្ពានស្ន័គ្រស្មោះ
បើចាស់ក្រឡាស់ដូចកម្លោះ ប្រគោះប្រកិតជិតមិនឃ្លាត ។
ធម្មតាយើងសត្វបំបាត់កម្ម មិនដឹងលិចចាំយប់អធ្រាត្រ
មិនបេះវេះពួនដោយស្បាតញាត មិនគិតមារយាទខាងតែបាន ។
មេអកស្ដាប់ខ្លែងកំប្លែងប្រាប់ ក្រឡាប់លាហើរលេលើឋាន
ទឹកពីពាក្យខ្លែងតែងរំខាន គិតដល់ប្ដីប្រាណប្រាសទៅឆ្ងាយ ។
ប្រឹងហើរហើយយំខំស្រែករក ឱប្រុសពន្លករូបឆោមឆាយ
អ្នកល្អលើសអកទៅដ៏ឆ្ងាយ ប្អូនស្ដាយគំនិតគិតឲ្យខុស ។
ប្រសិនបើប្អូនមកទឹងអ្នក សមបានរួមរក្សរូបឆ្នើមប្រុស
គ្មានទុក្ខជាសុខមិនមានមោះ ចាំងនេះជាគ្រោះផងប្អូនឯង ។
ឥឡូវទឹងទៅទីបានណា គនិច្ចាប្រុសត្រេចជាប់សង្វេង
ប្អូនតាមរកសព្វគ្រប់កន្លែង បំបែងចិត្តពេកស្ទើរបែកថ្លើម ។
អកហើរទៅលិចគេចទៅជើង ហើរឡើងទៅកើតគេចទៅត្បូង
ដល់ស្ទឹងវែងល្វឹងជ្រៅស្រឡូង ឈើច្រើនច្រុះជ្រោងជ្រំជ្រៀតគ្នា ។
ប្រកិតជាប់ជិតជួរមាត់ស្ទឹង អកវិងអាណិតខ្លួនកំព្រា
ព្រួយប្រាណសង្វេគឯកអត្តា រករកគូគ្រេហោយ ។
ពានប្រុសស្ងួនផងវិរ៉ុត ប្អូនពិតកើតទុក្ខប៉ុនក៏

អ្នកតាកហៅលប្អូនស្ងួនជ្រងំ ទូរគម្នាក់ឯងចំបែងក្រៃ ៗ

អ្នកទៅទីណាអ្នកថ្លៃអើយ ប្រុសអើយប្អូនមករកយូរថ្ងៃ

ប្រសិនបានកញ្ញប្រុសញ្ញថ្លៃ យើងនៅអាស្រ័យព្រៃនេះស្ងាត់ ។

អ្នកអើយដើមស្រុលពពូលថ្ក ដើមក្រៈដើមគ្រើលក្រុបពោធិសាត់

កំងភ្នុំស្រុកព្រះកំបាត់ ដើមផាត់ប្រមូលផ្កោលផ្ទួរផ្កាប់ ៗ

(នៅមានត)

ឯកសារ

# ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង

ដោយ


នាកញ៉ាប្រសើរលិខិត ម៉ែន-ឆន់

ធ្វើការនៅទីចាត់ការគរុកោសល្យ ភ្នំពេញ


---

## ៨- ប្រវត្តិ វត្តកោះកាពិ (សុវណ្ណបពិត)

> អ្នកផ្ដល់ពត៌មានគឺលោក ទៀវ-ចាន់ អាយុ ៤៥ ឆ្នាំ ជាស្មៀនសាលាសង្កាត់ កោះកាពិ ។ លោក ទៀវ-ចាន់ បានពត៌មាននេះ ពីលោក តា ង៉ែត នៅកោះកាពិ ដែលគាត់បានអនិច្ចកម្មយូរឆ្នាំហើយ ។ ក្រៅអំពីនេះ ដោយការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃ ២១-២-៦៨ ។

*វត្តកោះកាពិ មានការទាក់ទងនឹងព្រះបដិមាករ ១ អង្គ ដែលអ្នកស្រុកនិយមហៅថា ព្រះពុទ្ធអណ្ដែត ។ ដូច្នេះ ការនិយាយអំពីវត្តកោះកាពិ ត្រូវតែមានរឿងព្រះអណ្ដែតផងដែរ ដូចមានតទៅនេះ ។*

*ជាយូរឆ្នាំកន្លងមកហើយ ពុំដឹងជាសតវត្សរ៍ប៉ុន្មាន មានព្រះពុទ្ធរូបបែបប្រក់នាគ ២ ព្រះអង្គសាងអំពីថ្មកំ ទំហំខ្នងប្រវែង ០ម៦០ កំពស់ប្រវែង ០ម៩០ [illegible] បានអណ្ដែតតាមក្បូនឫស្សីមកពីប្រទេស[illegible] ។ អ្នកស្រុកនៅភូមិ*

ជ្រោយគយ (ឡាំជាំ) បាននាំគ្នានិមន្តព្រះពុទ្ធរូបនេះ មកទុកនៅភូមិរបស់ខ្លួន ដោយកសាងជាសាឡុំ ១ តម្កល់ព្រះពុទ្ធរូបសម្រាប់ជាទីសក្ការៈបូជា និងធ្វើបុណ្យទានតាមគន្លងព្រះពុទ្ធសាសនា ។

ចាប់តាំងពីពេលនោះមក បេះតែមានឧបទ្ទវហេតុ ធ្វើឲ្យអ្នកស្រុកកើតជម្ងឺ និងមានគ្រោះថ្នាក់ផ្សេងៗ ទើបអ្នកទាំងអស់គ្នាសន្និដ្ឋានថា ប្រហែលជាព្រះពុទ្ធរូបនេះឯងដែលជាអ្នកឲ្យទុក្ខទោស ហើយក៏នាំគ្នាដង្ហែយកទៅតម្កល់ទុកនៅកោះប៉ោ ។

បន្ទាប់អំពីនេះ អ្នកភូមិនៅជ្រោយគយ បានរុះរើលំនៅមកនៅកោះកាពិ ដោយរុះទាំងសាឡុំមកផង ហើយក៏កសាងជាវត្ត ១ នៅត្រង់ចង្កេះភ្នំកោះកាពិខាងទិសអគ្នេយ៍ បានដាក់នាមថា វត្តប្រជុំជន ដែលមានលោកគ្រូព្រះនាម និត ជាចៅអធិការ ។ វត្តប្រជុំជននេះ មានសភាពរុងរឿង ហើយមានលោកគ្រូចៅអធិការបន្តបន្ទាប់គ្នាដូចតទៅ គឺលោកគ្រូ និត លោកគ្រូយ៉ុង លោកគ្រូ ឡេក លោកគ្រូបើម និងលោកគ្រូជីត ។

បំណោរក្រោយមក ពុំដឹងជាក្នុងឆ្នាំណា ក្នុងពេលលោកគ្រូព្រះនាម ពៀម-វៀន ជាចៅអធិការនិងជាព្រះអនុគណ បានរុះរើព្រះវិហារពីចង្កេះភ្នំនេះ ទៅកសាងនៅលើកំពូលភ្នំវិញ នៅត្រង់កន្លែងសព្វថ្ងៃនេះ ទុកតែកុដិឲ្យស្ថិតនៅចង្កេះភ្នំដដែល ។

បន្ទាប់អំពីការរុះរើព្រះវិហារមក កសាងលើកំពូលភ្នំនេះបានប្រហែល ៩ ឬ ១០ ឆ្នាំ ទើបអ្នកស្រុកនៅកោះប៉ោ បាននាំគ្នាដង្ហែព្រះអណ្ដែតនោះមកប្រគល់ឲ្យអ្នកស្រុកកោះកាពិវិញ ព្រោះគេយល់ឃើញថា តាំងពីព្រះពុទ្ធរូបនេះទៅគង់នៅស្រុកគេវេលាណា អ្នកស្រុកពុំបានសេចក្ដីសុខសោះ ។ អ្នកស្រុកកោះកាពិក៏ទទួលយកព្រះពុទ្ធរូបនេះមកតម្កល់ទុកនៅព្រះវិហារ ។

លោកគ្រូ ជៀប-វៀន សុគតនៅថ្ងៃទី ៩ កុម្ភៈ ១៩៥០ ក្នុងព្រះជន្មាយុ ៥៦ ហើយត្រូវលោកគ្រូព្រះនាម ឥន្ទ-សំក៉ាន ឡើងជាចៅអធិការ ។ លោកគ្រូ ឥន្ទ-សំក៉ាន បានសុំកែនាមវត្តពីវត្តប្រជុំជនមកជាវត្តសុវណ្ណបព៌តវិញ ។ ក្រៅអំពីនេះលោកបានសាងព្រះចេតិយ ១ នៅខាងត្បូងព្រះវិហារសម្រាប់បញ្ចុះព្រះអដ្ឋិធាតុលោកគ្រូ ជៀម-វៀន គឺកសាងក្នុងឆ្នាំ ១៩៦០ ព.ស. ២៥០៤ ។ លោកគ្រូ ឥន្ទ-សំក៉ាន បានប្រព្រឹត្តទាស់ខុសខាងផ្លូវនយោបាយ ថេរសភាបានផ្សឹកអំពីភិក្ខុភាវ ហើយរាជការចាប់ខ្លួនឃុំឃាំងក្នុងឆ្នាំ ១៩៦៤ ។

បន្ទាប់មក បានលោកគ្រូព្រះនាម ចៀវ-ទួន ជាចៅអធិការ ប៉ុន្តែមិនយូរប៉ុន្មានលោកគ្រូអង្គនេះក៏លាចាកសិក្ខាបទក្នុង គ.ស. ១៩៦៧ ទើបបានលោកគ្រូព្រះនាម ហេង-ឡួន ជន្ម ២៣ ធ្វើជាចៅអធិការ ក្នុងបច្ចុប្បន្ននេះ ។

នៅក្នុងឆ្នាំ ១៩៦៥ ក៏ជាមានទិមន្តព្រះគ្រូ ព្រះនាម ក៉ែរស៊ា ពីបាត់ដំបងមកធ្វើជាព្រះអនុគណស្រុកកោះកុង ហើយឲ្យមកគង់នៅ វត្តសុវណ្ណបពិតនេះ ។

នៅឆ្នាំ ១៩៦៦ មានកិច្ច ១ អន្ដកើតពេកវិកលចរិត បានទៅប្រាទព្រះពុទ្ធរូបអណ្តែតទឹកនោះដួលធ្លាក់ពីលើបល្ល័ង្ក បណ្តាលឲ្យបាក់ព្រះសុរង ហើយរលងពីនោះបាន ២-៣ ខែព្រះគ្រូអនុគណព្រះនាម ក៉ែរស៊ា បានផ្ចួតផ្តើមដង្ហែព្រះអណ្តែតនោះតម្កល់នៅវត្តជោតញ្ញាណ ក្រុងខេមរភូមិន្ទ (ដងទង់) ។

សមិទ្ធិនៅវត្តសុវណ្ណបពិតមានដូចតទៅ :

–នៅលើកំពូលភ្នំ មានព្រះវិហារ សាងអំពីឥដ្ឋប្រក់ក្បឿង ១ និងចេតិយ ១ ។

នៅចង្កេះភ្នំ មានកុដិ ២ សាលាបុណ្យ១, កុដិបាយ ១ ដែលសុទ្ធតែសង់អំពីឈើប្រក់ក្បឿង ។

–ចុងផ្លូវទៅខាងកើត មានបន្ទប់រៀនសង់អំពីឈើ ប្រក់ស្លឹក ដែលជាសាខា នៃសាលាបឋមសិក្សាបំពេញវិជ្ជាកោះកាពិ ។

ព្រះសង្ឃក្នុងវត្តសព្វថ្ងៃគឺ :

| | | |
|---|---|---|
| ព្រះគ្រូអនុគណ | ១ | អង្គ |
| លោកគ្រូចៅអធិការ | ១ | – |

ភិក្ខុបរិស័ទ ២ អង្គ

មានបុគ្គលម្នាក់ទៀតដែលគួរតែលើកយកមកនិយាយផងដែរ គឺត្រង់កន្លែងគុហាដែលព្រះសង្ឃគង់សព្វថ្ងៃនេះ បានជីកដីលាក់ចង្កេះភ្នំធ្វើជាទីលាន ៗ កាលជីកដីនោះ គេប្រទះឃើញព្រះពុទ្ធរូបតូច ១ ជាច្រើនអង្គកប់នៅក្នុងដី មានទំហំតាំងពីប៉ុនកដៃ ប៉ុនមេដៃ រហូតដល់ប៉ុនកូនដៃ ហើយភាគច្រើនបានកសាងអំពីស្ពាន់ ប៉ុន្តែមានអង្គខ្លះដែលតូច ៗ ប៉ុនកូនដៃ កសាងអំពីកែវក្រូចឆ្មារទន់ផុយ ៗ ដូចជាដីឥដ្ឋ ប៉ុន្តែពុំលាយទេ ហើយច្រើនតែបែបប្រក់នាគ មានអង្គខ្លះពណ៌សប្រផេះ និងមានអង្គខ្លះពណ៌ខ្មៅ ។ បើតាមការយល់របស់អ្នកនិពន្ធថា ប្រហែលជាចាស់ ៗ ជំនាន់មុន បានកសាងព្រះពុទ្ធរូបនេះហើយសេកមន្តអាគម សម្រាប់ជួយការពារខ្លួនក្នុងគ្រាមានចម្បាំង ដោយយកមកចងក ឬក្រវាត់ចង្កេះ ឬបៀម ឬបង្កប់ក្នុងដងអាវុធ លុះផុតពេលចម្បាំង ក៏ប្រមូលយកមកកប់ទុកនៅទីនេះ ។ ព្រះពុទ្ធរូបដែលគាស់បានមកនោះ ត្រូវបានគេយកទៅតម្កល់នៅ លើបល្ល័ង្កព្រះ ក្នុងព្រះវិហារចំនួន ១២៦ អង្គ នៅសល់អំពីនោះមានទុកតាមកុដិលោកខ្លះ និងអង្គខ្លះទៀតត្រូវអ្នកស្រុកគេរើសយកទៅទុកជាទីសក្ការៈ ហើយបើតាមការយល់របស់លោកគ្រូព្រះនាម ហេង-ឡុន ជាចៅអធិការថា ប្រហែលជានៅមានកប់ក្នុងដីទៀត ព្រោះយូរ ៗ មានគេប្រទះឃើញឯនេះ ១ អង្គ ឯនោះ ១ អង្គ ដែលទើបនឹងលេចចេញពីក្នុងដីដោយសារមានភ្លៀងហូរច្រោះ ។

## ៩- អំពីកោះមូល

ដោយការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ ម៉ែន-ទន់ កាលពីថ្ងៃ ២១-២-៦៨ ។

កោះមូលស្ថិតនៅក្នុងសង្កាត់កោះកាពិ - ស្រុកកោះកុង - ខេត្តកោះកុង ។ កោះនេះជាកូនក្នតូចមួយ បើវាស់កាត់ទទឹងមានទំហំប្រហែល ២០០ម. ហើយនៅដាច់អំពីដីគោក ។ ប៉ែកខាងកើតឃ្លាតអំពីជ្រោយគយ (ឡាំដាំ) ប្រហែលជាង ២០០ម. ប៉ែកខាងត្បូងឃ្លាតអំពីក្បាលកោះកុងប្រហែល ៦០០ម. ហើយនៅប៉ែកខាងលិច និងខាងជើង ជាលំហសមុទ្រដ៏ធំធេង ។

បានជាហៅកោះមូល ព្រោះគេចង់និយាយថា កោះនេះរាងមូល ប៉ុន្តែតាមពិតកោះនេះពុំមែនរាងមូលដូចផែនស្ករនោះទេ គឺរាងទ្រវែងកោងបន្តិចដូចផ្លែស្វាយ ។

កាលពីសម័យមុន កោះនេះជាទីតាំងដំបន់រដ្ឋបាល ក្រោយមកទៀត ក្នុងសម័យអាណាព្យាបាលបារាំង ជាទីតាំងសាលាស្រុក និងក្រុមគយ ។ ដូច្នេះហើយ បានជានៅលើកោះមូល ឃើញមានគេហស្ថានចាស់ៗ សង់អំពីឥដ្ឋ និងបេតុងអារមេ ដូចជាសាលាស្រុក អាងទឹកនិងឃ្លាំងដាក់អំបិល ។ គេហស្ថានទាំងនេះ មានសភាពទ្រុឌទ្រោមទៅហើយ ក្រៅអំពីនេះមានគេហស្ថានថ្មមួយនៅល្អ គឺមន្ទីរគយ ដែល

សព្វថ្ងៃនេះមានបុគ្គលិកក្រុមគយនៅធ្វើការជាអចិន្ត្រៃយ៍ ។ នៅជុំវិញគេហដ្ឋានខាងលើនេះឃើញមានដំណាំដូងខ្ពស់ៗ និងរុក្ខជាតិឯទៀតៗ ដុះតាមចន្លោះផ្ទាំងសិលា ដែលគួរប្រដូចទៅនឹងព្រៃក្នុងទាំងឡាយដែរ ។

នៅតាមចង្កេះភ្នំ មានដំណែលផ្លូវព័ទ្ធជុំវិញ ហើយនៅខាងកើតមានផ្លូវថ្នល់មួយលើកដោយបំណែកថ្មភ្ជាប់នឹងជ្រោយគយ មានទទឹងប្រហែល ៤ម. ។ កាលពីមុន ផ្លូវដែលព័ទ្ធជុំវិញភ្នំ និងថ្នល់ឆ្លងទៅជ្រោយគយនោះ គេអាចបើកបររថយន្តបាន ប៉ុន្តែតាំងពីស្រុកកើតអសន្តិសុខដោយយៀកមិញពកត្បាត ហើយថែមត្រូវរុះរើសាលាស្រុកមកតាំងនៅត្រើយខាងកោះកាពិវលារណា ផ្លូវដែលព័ទ្ធជុំវិញភ្នំនោះត្រូវបាក់ក្រហេងក្រហូង និងមានដើមឈើដុះទ្រុបទ្រុល ហើយក្លាយទៅជាផ្លូវដើរយ៉ាងតូចសម្រាប់បុគ្គលិកនៅទីនោះដើរចេញ-ចូល ។

កោះមូលជាដំបន់គយសំខាន់បំផុតនៅខេត្តកោះកុង ។ ឈ្មួញបរទេស មានសិង្ហបុរីនិងសៀម ជាដើម ដែលមកទិញត្រី ត្រូវតែចូលមកចតនាវានៅ កោះមូលនេះ ហើយនៅពេលចូលមកដល់ក្តី មុននឹងចេញដំណើរទៅវិញក្តី ត្រូវបានទទួលការពិនិត្យអំពីអ្នករាជការក្រុមគយ ។

នៅលើកោះមូល ពុំមានប្រជាពលរដ្ឋរស់នៅជាឯកជនទេ មានតែបុគ្គលិករាជការស៊ីវិល និងទាហាន គឺបុគ្គលិកក្រុមគយមាន ៤នាក់ ទាហានខាងក្រុមនាវាចរ ១ នាក់ និងក្រុមគ្រួសារនៃបុគ្គលិកទាំងនេះ ។

# ១០– ប្រវត្តិយាយម៉ៅ

អ្នកផ្តល់ពត៌មានគឺលោក ទៀវ-ចាន់ អាយុ ៤៥ ឆ្នាំ ជាស្មៀនសាលាសង្កាត់កោះកាពិ ។ លោក ទៀវ ចាន់ បានដឹងរឿងនេះដោយសារលោកតា ង៉ែត នៅកោះកាពិ ដែលគាត់បានទទួលអនិច្ចកម្មយូរឆ្នាំហើយ ។

យាយម៉ៅ ជានាមនៃវត្ថុសក្តិសិទ្ធិមួយ ដែលប្រជាពលរដ្ឋនៅតាមមាត់សមុទ្រនិងកោះនានានៃខេត្តកោះកុង បានគោរពបូជាស្ទើរគ្រប់គ្នា ។ ឯប្រវត្តិនៃវត្ថុសក្តិសិទ្ធិនោះមានដូចតទៅ :

ក្នុងកាលដែលកន្លងយូរហើយ ពុំដឹងជាសតវត្សទីប៉ុន្មាន និងពុំដឹងជាក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយអង្គណា មានមន្ត្រីសក្តិធំម្នាក់នាមពុំប្រាកដ បានកាន់កាប់ការពារការជានាយដំបន់នៅតាមឆ្នេរសមុទ្រចាប់តាំងពីភូមិបាត់ទៅទល់នឹងព្រំដែនសៀម ។

មន្ត្រីនេះបានតាំងដំបន់ធ្វើការនៅកោះមូល ព្រោះកោះនេះនៅជិតទល់ដែនសៀម ហើយមានលំហសមុទ្រដ៏ធំ អាចមើលឃើញទូក-សំពៅចេញចូលបានដោយងាយក្នុងកិច្ចការពារព្រំដែន ។

លោកនាយដំបន់នេះមានភរិយា ឈ្មោះ ម៉ៅ ។ លោកស្រី ម៉ៅ ជានារីមានសន្តានចិត្តប្រាកដនិយម និយាយម៉ាត់ពេកម៉ាត់ហ្នឹង ហើយរឹងរូះផង ។ ប្រជាពលរដ្ឋទាំងប្រុសស្រី ចាស់-ក្មេង តែងខ្លបខ្លាច

អំណាចលោកស្រីជាងលោកប្រុសទៅទៀត ។ ក្រៅអំពីនេះ លោកស្រីមានបុគ្គលិកលក្ខណៈមួយទៀត គឺកំណាញ់គ្រឿងកាមគុណ ។ ស្វាមីរបស់លោកស្រី ។ បានប្តេជ្ញាចិត្តដាច់ខាត ថាមិនឲ្យមានស្រីដទៃណាមកលាយឡំមួយជាពីរឡើយ ។

ចំណែកលោកស្រីវិញ មានអធ្យាស្រ័យផ្ទុយស្រឡះអំពីគំនិតលោកស្រី គឺលោកមានប្រជាប្រិយភាព មានការរាប់អានរាស្ត្រប្រជា មិនប្រកាន់ឋានៈអ្នកមាន ឬអ្នកក្រឡើយ ហើយក្រៅអំពីនេះលោកក៏ពុំប្រកាន់ថា ក្នុងជាតិនេះអាត្មាអញត្រូវមានប្រពន្ធតែមួយនោះទេ ដូច្នេះហើយបានជាលោកហ៊ានក្បត់ចិត្តលោកស្រី មៅ ដោយបានទៅរួមរ័ក្សនឹងស្រីមួយរូបទៀត ឈ្មោះនាង ប៉ែន ។

នាង ប៉ែន មានរូបសម្បត្តិឆើតឆាយជាងលោកស្រី មៅ ហើយវ័យក៏នៅក្មេងខ្ចី ធ្វើឲ្យលោកងាយជំពប់ចិត្តលែងខ្លាចលោកស្រីជាភរិយា ហើយថែមទាំងពុំសូវបាននៅបនិត្យនឹងលោកស្រីទៀត ។

ដោយកម្លាំងកាមតណ្ហាក់ដុតកេលលោកស្រី ធ្វើឲ្យលោកស្រីក្តៅក្រហាយចិត្តដូចគេយកអង្កើកភ្លើងទៅបង្កប់ក្នុងដើមទ្រូង ។ លោកស្រីបានដាក់កំហិតថា បើលោកប្រុសមិនលះបង់នាង ប៉ែនចោល ទេ លោកស្រីនឹងធ្វើអត្តឃាតកម្មដោយវិធីណាមួយពុំខាន ។ ពាក្យប៉ុណ្ណេះគួរតែលោកប្រុសស្តាប់បាន ហើយប្រញាប់ប្រញាល់ថយក្រោយជាបន្ទាន់ ព្រោះ

ធ្លាប់ដឹងចិត្តលោកស្រីស្រាប់ ប៉ុន្តែដោយស្នេហារាំងបាំងកម្លាំងតាមរាបិទ ធ្វើឲ្យសំដីលោកស្រីរសាត់តាមខ្យល់ ពុំចូលត្រចៀកលោកប្រុសសោះឡើយ មួយលើកជាដែល, ពីរលើកព្រងើយ, បីលើកលើសដើម ។

ឱ ! កម្លាំងស្នេហា ពេគកាមគុណ តើរាំបន្ទំចិត្តលោកស្រីឲ្យលោតដល់កម្រិតណា ! ពាក្យប្ដេជ្ញារបស់លោកស្រីមានប្រសិទ្ធភាពឬទេ ! ។

មែន មនុស្សបម្រើទឹកធ្លូលគ្រប់គ្នា ថាតើលោកស្រីសម្រាន្តអីកយូរម្ល៉េះ ! ម៉ោង ៦-៧ ហើយនៅមិនទាន់ក្រោក ទើបតាត់គ្នាឲ្យទៅលបមើល ។ ពេលនោះការងឿងឆ្ងល់កាន់តែខ្លាំងឡើង ព្រោះពុំឃើញរូបលោកស្រីនៅសម្រាន្តសោះឡើយ ។ សភាពជ្រួលច្របល់ក៏កើតមានឡើង ទាំងលោកនាយដំបន់ ទាំងអ្នកជាការក្រោមបង្គាប់ ព្រមទាំងអ្នកបម្រើប្រុស-ស្រី រត់ខ្វល់ដើង អ្នកខ្លះរកមើលសព្វកៀនកោះក្នុងផ្ទះ ខ្លះមើលតាមដើមឈើក្រែងលោកស្រីចងក ខ្លះដើរមើលតាមមាត់ទឹក ប៉ុន្តែនៅតែពុំឃើញទៀត ទើបតាត់គ្នាឲ្យទៅរកនៅទីឆ្ងាយៗ ក្រែងលោកស្រីនិរទេសខ្លួន ខ្លះទៅជ្រោយគយ (ឡាំងដាំ) ខ្លះទៅកោះកាពិ ខ្លះទៅពាមក្រសោប និងខ្លះទៀតទៅកោះកុង . . . ។

ពុំទ្លា នៅព្រឹកនៃថ្ងៃបន្ទាប់ គេឃើញសពលោកស្រីអណ្ដែតទឹកស្ទឹងពាមជាយកោះអូរ ម៉ែកខាងទិសពាយព្យ ហើយនៅពេលរូបកាយ

សពពុំមានស្លាមដាំដំអ្វី ទើបនាំគ្នាសន្និដ្ឋានថាលោកស្រីប្រាកដជាលោតទឹកសម្លាប់ខ្លួន ។

ក្រោយដែលស្រង់សពយកមកលើគោកហើយ លោកនាយដំបន់និងសហការី បានចាត់ចែងធ្វើកេងគម្រល់សព និងរៀបធ្វើបុណ្យតាមប្រពៃណីយ៉ាងអ៊ុកធឹក ។ បន្ទាប់មក លោកនាយដំបន់ក៏លើកនាងប៉ែនឲ្យឡើងជាភរិយាពេញទី ហើយត្រូវបានគេហៅថាលោកស្រី ១ ជាប់រហូតទៅ ។

រំលងអំពីមរណកាលនៃលោកស្រី មៅ បាន ៣-៤ ខែ អ្នកស្រុកនៅក្នុងដំបន់នេះបេះតែមានជម្ងឺ បន្តិចអ្នកនេះឈឺ បន្តិចអ្នកនោះឈឺ ប្រុសក៏មាន ស្រីក៏មាន ចាស់ក៏មាន ក្មេងក៏មាន ហើយពុំមានគ្រូហ្មណាមើលជា ទោះបីបន់ស្រន់អារក្ស-អ្នកតា ឬសែនព្រេនថ្វាយអ្វីៗពុំជាដែរ ខ្លះក៏បាត់បង់ជីវិត ខ្លះក៏នៅទុរនទុកស្ទើរស្លាប់ស្ទើររស់ ។

ហេតុតែសំណាងមាន អាយុមិនទាន់អស់មិនស្លាប់ ស្រាប់តែមានស្រីម្នាក់យំគក់ទ្រូង គក់ស្មា ហើយស្រែកសួរអ្នកកំពុងជម្ងឺថា ស្គាល់យើងទេ ! យើងជានរណា ! យើងស្លាប់ដោយសារអ្វី! អ្នកទាំងអស់គ្នាស្រឡាំងកាំង ក្នុងភាពសន្និដ្ឋានថាច្បាស់ជាខ្មោចចូល ហើយក៏បន្ទឺឡើងថា យើងខ្ញុំពុំស្គាល់ទេ សូមមេត្តាប្រាប់យើងខ្ញុំផង លោកជាអ្នកណា ! លោកស្លាប់ដោយសារអ្វី ! រូបនោះឆ្លើយថា : យើងជាលោក

ស្រី មៅ យើងស្តាប់ដោយឈឺចិត្តទីងប្តីមានសហាយ បើចង់ជាត្រូវរករបស់មកថ្វាយយើង ។

គ្រួសារអ្នកជម្ងឺត្រេកអរណាស់ នាំគ្នាសួរអំពីរបស់ដែលត្រូវថ្វាយ តើរបស់អ្វីទៅ ? មាន់ស្ងោរឬ ? ទេ ក្បាលជ្រូកឬ ? ទេ អាការសាហាវឬ ? ទេ កន្ទុនបាក់កឬ ? ទេ កំរើឬ ? ទេ ស្រោមឬ ? ទេ អ្នកទាំងអស់គ្នាដេញដោលសួរអំពីរបស់ដែលខ្មោចបិសាចតែងត្រូវការ ប៉ុន្តែរូបនោះចេះតែឆ្លើយបដិសេធដាច់អហង្ការ យូរណាស់ទើបឆ្លើយទាំងអិមអៀមថា : រកគ្រឿងកាម ១ គូ មកថ្វាយយើង ទើបយើងឲ្យជា ។ អ្នកទាំងអស់គ្នានៅតែស្តាប់ពុំទាន់យល់ច្បាស់ ក៏នាំគ្នាសួរបញ្ជាក់ទើបរូបនោះឆ្លើយទាំងកំហឹងថា រកលិង្គឲ្យយើង ១ គូព្រោះយើងខ្វះគ្រឿងនេះយូរហើយ ថាតែប៉ុណ្ណោះក៏ចេញពីរូបបាត់ទៅ ហើយទាំងរូប ទាំងស្មុំ អត់ព្រាំពុំបានក៏នាំគ្នាសើចគិលឡើង ។

អ្នកទាំងអស់គ្នាឈប់សង្ស័យ ហើយក៏ចាត់ចែងយកឈើមកធ្វើជាលិង្គ ១ គូរដាក់ថ្វាយ ឯអ្នកជម្ងឺក៏បានជាសះស្បើយតែរៀងខ្លួន ៗ មុនដំបូងគេពុំទាន់កំណត់កន្លែងដែលត្រូវដាក់ថ្វាយទេ គឺគេយកលិង្គតង្វាយទៅដាក់នៅក្រោមដើមឈើធំ ឬនៅលើដុំថ្ម ហើយអុជធូបនិយាយទៅ លុះយូរ ៗ ទៅ ទើបគេនាំគ្នាសង់ជាអាស្រម ។ ទី ១ គេសង់នៅកោះមួលខាងទិសពាយព្យ ត្រង់កន្លែងដែលឃើញពស់អណ្តែតជាដំបូង បន្ទាត់

មកនៅកោះកាពិ រួចនៅតាមមាត់សមុទ្រ និងកោះនានា ។

ចំណែកអ្នកនិយមជឿវិញ មិនគ្រាន់តែអ្នកមានជម្ងឺប៉ុណ្ណោះទេ ទោះបីអ្នកធ្វើដំណើរដោយទូក សំពៅ តាមសមុទ្រដែលភ័យខ្លាចអំពីព្យុះខ្យល់ និងគ្រោះកាចផ្សេង ៗ ទៀតក៏តែងសំបូងសង្រួងបន់ស្រន់លោកស្រី មៅ សុំសេចក្ដីសុខគ្រប់គ្នា ។

ចាប់តាំងពីពេលនោះមក ប្រជាពលរដ្ឋនៅតាមមាត់សមុទ្រ និងតាមកោះនានាតាំងពីភូមិកមរហូតដល់ព្រំប្រទល់ដែនសៀម តែងគោរពបូជាលោកស្រី មៅ គ្រប់គ្នា ព្រោះកាលនៅរស់នៅឡើយ លោកស្រីមានអានុភាពលើប្រជាពលរដ្ឋនៅដំបន់នេះ លុះអនិច្ចកម្មទៅហើយ គឺវិញ្ញាណក្ខន្ធលោកស្រីនៅមានឥទ្ធិពលខ្លាំងក្លាលើដំបន់នេះទៀត ។ ព្រាយបិសាចអារក្សអ្នកតា ឯទៀត ៗ ក៏ខ្លបខ្លាចអំណាចលោកស្រីទាំងអស់ ដូច្នេះហើយបានជាអ្នកស្រុកនៅដំបន់នេះ បើមានជម្ងឺ ឬបន់ស្រន់ពីរឿងអ្វី គេពុំដែលបន់វត្ថុសក្តិសិទ្ធណាក្រៅពីលោកស្រីមៅ ឡើយ ហើយចំណោរយូរៗទៅ ពាក្យថាលោកស្រី មៅ ក៏ក្លាយមកជា យាយមៅ រហូតដល់សព្វថ្ងៃ ។

រីឯសំណែនដែលគេសែនថ្វាយវិញ នៅគ្រប់អាស្រមទាំងអស់ឃើញមានសុទ្ធតែរូបលិង្គរជាតំនរៈដែលគេធ្វើអំពីស៊ីម៉ងត៍ក៏មាន អំពីឈើក៏មាន ប៉ុន្តែភាគច្រើនគឺឈើ ដែលមានខ្លះត្រូវបានលាបពណ៌ជាលំអផង លុះ

មានច្រើនពេកទៅ ចណ្ដាលឲ្យកណ្ដៀរស៊ីលិង្គឈើទាំងនោះដូច្នេះហើយបានជានៅឆ្នាំ ១៩៦៦ បរិស័ទ បាននាំគ្នាធ្វើពិធីមួយ សុំរើយកតង្វាយលិង្គឈើចាស់ ៗ នៅដុតចោលម្ដង ហើយសាងរូបលិង្គថ្មីថ្វាយជំនួសវិញ ។

ក្រៅអំពីរូបលិង្គដូចបានពោលខាងលើនេះ ឃើញមានតង្វាយដទៃទៀតគឺឡង់និងគេងឡានខ្លះដែរ ទំនងជាអ្នកនិយមចិនគេដាក់ថ្វាយ ជាពិសេសតាមរបៀបអ្នកតាចិន ។

តាមពត៌មានមួយផ្នែកទៀតថា លោកស្រី ប៉ែន ជាភរិយាចុងនៃលោកនាយដំបន់ក៏ស្លាប់ទៅកើតជាព្រាយបិសាចដែរ ដូច្នេះហើយបានជានៅកោះមូលមានអាស្រម ២ គឺអាស្រម ១ នៅជ្រុងខាងទិសពាយព្យនៃកោះ ជាអាស្រមរបស់យាយ ម៉ៅ និងអាស្រម ១ ទៀតនៅជ្រុងខាងទិសទក្សិណនៃកោះ ជាអាស្រមរបស់យាយ ប៉ែន ប៉ុន្តែយាយ ប៉ែននេះពុំសូវមានគេស្គាល់ និងពុំមានអ្នកណាបន់ស្រន់អ្វីទេ ។

## ភាសាដែលគួរបញ្ជាក់ក្នុងរឿងនេះ

– អាការសាហាវ គឺ ស្រា ភាសាសម្រាប់និយាយចំពោះខ្មោចបិសាច

– កន្ទន់បាក់ក ,, ចេក -ដ-

– កិរី ,, ក្លង -ដ-

– ស្រោម ,, អាវ -ដ-

- ឡង់ គឺ កូនចត្រតូច ៗ គ្រឿងសំណៅខាងអ្នកតាចិន
- គេងឡាង " គោមធ្វើអំពីក្រដាសក្រហម
- ស្នំ " អ្នកនិយាយភាសាផ្ទាល់និងខ្មោច

## ១១- ឈូងខ្លែង

> អ្នកផ្ដល់ពត៌មានគឺលោក តាន់-ឡឹក នាយដំបន់អធិការកិច្ចបឋមសិក្សា ស្រុកកោះកុង និងតាមការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃ ២០-២-៦៨ ។

ឈូងខ្លែង ស្ថិតនៅត្រង់ក្បាលកោះកុងខាងជើង និងខាងទិសនិរតី នៃ កោះមូលមានចម្ងាយប្រហែល ៣ គម ពីកោះមូល នៅក្នុងសង្កាត់ កោះកុង ស្រុកកោះកុង ខេត្តកោះកុង ។ បានជាគេហៅថា ឈូងខ្លែង មកពីឈូងនេះផតចូលទៅដីគោក មានកងដូចខ្លែង "អ្នកខ្លះហៅ គៅកើ" មកពីភាសាសៀមថា គៅ ខ្មែរថាឈូង សៀមថាកើ ខ្មែរថា ខ្លែង ។

ឈូងនេះមានទំហំផតចូលទៅប្រហែល ៥០០ ម. និងទទឹងមាត់ ប្រហែល ៦០០ ម ។ នៅពីមុខមានលំហសមុទ្រ ហើយនៅពីខាងក្រោយមានសុទ្ធតែព្រៃ និងភ្នំ ប៉ុន្តែពុំមានបណ្ដាជនសង់ផ្ទះនៅ ឬប្រកបរបរស្រែ ចំការនៅទីនោះទេ ។ នៅមាត់ឈូងខាងលិច ឃើញមាន ម៉ុងបញ្ចុះសព ១ (ផ្នូរខ្មោច) ដែលអ្នកស្រុកនៅកោះកាពិបាន យកទៅ

កប់តាមរបៀបចិន ។

នៅក្នុងផ្ទៃឈូង មានឡចំហុយត្រីបាធូ ២ កន្លែង ដែលជារបស់ឯកជន ។ ឡទាំង២ នោះគេសង់រោងយ៉ាងវែងនៅកណ្ដាលទឹក សសរសុទ្ធតែកូនឈើ ឯជំបូលប្រក់ស្លឹក ហើយនៅក្នុងរោងនោះមានឡជាច្រើនតម្រៀបគ្នាជាជួរ ឡនីមួយ ៗ មានទំហំទទឹងមាត់ប្រហែល ៨០ ស.ម. និងកំពស់ប្រហែល ១ម. ដោយមានក្ដាប់ខ្ទះសម្រាប់ចំហុយនៅមាត់ឡនោះផង បើនឹងហៅថា ជើងក្រានគុកជួរច្រះវិញក៏បាន ។ ក្រៅអំពីឡ ឬជើងក្រានគុកនេះយើងឃើញមានសម្ភារៈឯទៀត ៗ និងពួកកម្មករជាច្រើននាក់នៅធ្វើការផង ។

ឡដែលធំសម្បើមជាងគេ គឺឡយីហោ ប៉ោ-លី ។ ថៅកែឡនេះទៅពីស្រុកកោះធំ ខេត្តកណ្ដាល ឯឡ ១ ទៀតជារបស់ថៅកែ ពិន ប៉ុន្ដែយើងពុំបានចូលទៅក្នុងរោងនោះទេ ។

នៅពេលដែលអ្នកនិពន្ធយើងទៅមើលឡនោះ អ្នកស្រីម្ចាស់ឡយីហោ ប៉ោ-លី បានពន្យល់អំពីរបៀបចំហុយត្រី និងអំពីបច្ចេកទេសផ្សេងៗខាងអាជីវកម្មចំហុយត្រី ។

# ១២- ភូមិ និងវត្តកោះស្រឡៅ

អ្នកផ្ដល់ពត៌មានគឺលោក ដាំ-ពា អាយុ ៥១ ឆ្នាំ មេភូមិនៅកោះស្រឡៅ និងលោក លី-គុង សេង នាយកសាលារៀនកោះស្រឡៅ និងដោយការពិនិត្យផ្ទាល់ផល់ទីកន្លែងនៃអ្នកនិពន្ធ កាលពីថ្ងៃ ២០-២-៦៨ ។

ភូមិនិងវត្តកោះស្រឡៅ ពុំមានប្រវត្តិវែងឆ្ងាយពេកទេ ហើយនៅពេលដែលអ្នកនិពន្ធយើងធ្វើដំណើរទៅនោះ ចំលើពេលដែលលោកគ្រូចៅអធិការពុំគង់នៅ ជាហេតុឲ្យយកពត៌មានពុំបានសព្វគ្រប់ ។ ដូច្នេះយើងសូមបញ្ចូលភូមិ និងវត្តកោះស្រឡៅឲ្យមកនៅតែរឿងមួយវិញ ។

បានជាមានឈ្មោះថា កោះស្រឡៅ មកពីហេតុខុស ៗ គ្នាដូចតទៅ:

១- ខ្លះថា កាលពីយូរអង្វែងមកហើយ មានបុរសម្នាក់ឈ្មោះ ចៅ-ពៅ មកតាំងទីលំនៅ នៅលើកោះនេះមុនគេ ហើយអ្នកឯទៀត ៗ ក៏សន្មតហៅថា កោះចៅពៅ តាមភាសាសៀមថា ចៅឡៅ លុះយូរ ៗ ទៅក៏ក្លាយជាកោះស្រឡៅ ។

២- ខ្លះថា កោះនេះជាកន្លែងបិទស្រា ភាសាសៀម ហៅស្រាថា ឡាវ លុះយូរ ៗ ទៅក្លាយជាកោះស្រឡៅ ។

៣- ខ្លះកាលពីដើមមានលាវម្នាក់ មក តាំងទីកន្លែងនៅកោះ ភាសាសៀមហៅលាវថាឡាវ គឺកោះតាឡាវ លុះយូរ ៗ ទៅក្លាយជា កោះស្រឡៅ នេះឯង ។

កោះស្រឡៅ    ស្ថិតនៅក្នុងសង្កាត់កោះកាពិ - ស្រុកនិងខេត្តកោះកុង ។ មានបណ្តោយប្រហែល ១.៨០០ម. និងទទឹងប្រហែល ១.៥០០ម. ហើយនៅខាងទិសឦសាននៃកោះកាពិ ចម្ងាយប្រហែល ៧-៨គ.ម. ។ នៅទិសខាងត្បូង-ខាងកើត-ខាងជើងនៃកោះ មានដៃសមុទ្រតូច ៗ និងនៅខាងលិចមានព្រៃលិចទឹក ដែលដុះសុទ្ធតែដើមកោងកាង ។

ភូមិកោះស្រឡៅជាភូមិតូចមួយ នៅកណ្តាលព្រៃលិចទឹកនិងដៃសមុទ្រ មានប្រជាពលរដ្ឋរស់នៅ ៥០ គ្រួសារ ។ គេហដ្ឋានភាគច្រើនរបស់គេសង់នៅតាមមាត់សមុទ្រ ពាក់កណ្តាលផ្ទះខាងមុខនៅក្នុងទឹក ពាក់កណ្តាលផ្ទះខាងក្រោយនៅដីគោក ។ គេសង់យ៉ាងនេះប្រយោជន៍ងាយចតទូក ប៉ុន្តែមានផ្ទះខ្លះ សង់នៅតាមចង្កេះភ្នំ និងនៅជិតឆ្នេរដែរ ។

មុខរបរសំខាន់បំផុតនៃប្រជាពលរដ្ឋ គឺនេសាទត្រី បង្កែល ក្តាម ដោយមាន មង សន្ទូច ជាឧបករណ៍ ។ ក្រៅអំពីនេះ មានប្រកបរបរខាងកសិកម្មខ្លះដែរ ដូចជា ដាំស្វាយម៉ាវ ទូរេន ដូង ម្នាស់ ជំពូ ត្របែក ។ល។ ប៉ុន្តែមិនជាច្រើនពេកទេ គេដាំសម្រាប់តែទទួលទានក្នុងគ្រួសារ ។ ការលក់ដូរមានតែផ្ទះ ២-៣ ដាក់អីវ៉ាន់លក់បន្តិចបន្តួច និងលក់នំបញ្ចុកចំណី ប៉ុន្តែពុំមានផ្ទះលក់កាហ្វេ-គុយទាវ ទេ ។

នៅកោះស្រឡៅមានវត្តមួយ កសាងជាយូរឆ្នាំមកហើយ ហៅតាម

ផ្លូវការជាវត្តពារវែក ។ ជាដំបូងសាងនៅដីទំនាបត្រង់ខាងកើតភ្នំ ជិតដែសមុទ្រ ប៉ុន្តែត្រូវរុះរើទៅសាងនៅលើចង្កេះភ្នំវិញចំនួន ២៩ ឆ្នាំមកហើយ ។ វត្តនេះមានព្រះវិហារសាងអំពីឥដ្ឋប្រក់ស័ង្កសី មានកុដិ ២ សាលាបុណ្យ ១ កុដិបាយ ១ ដែលសុទ្ធតែសាងអំពីឈើប្រក់ស័ង្ក-សី ។ ព្រះសង្ឃក្នុងវត្តមានតែ ១ អង្គគឺលោកគ្រូចៅអធិការព្រះនាម រតន៍-ជី ព្រះជន្មបានជាង ៦០ វស្សា ហើយ ។

នៅខាងត្បូងវត្ត មានសាលាបឋមសិក្សាបំពេញវិជ្ជា ១ បង្កើតឡើងជាង ១០ ឆ្នាំហើយ ។ មុនដំបូងសង់អំពីឈើ ប្រក់ស្លឹក ប៉ុន្តែឥឡូវនេះសង់អំពីឈើប្រក់ស័ង្កសី ។ សាលារៀននេះ មានបន្ទប់រៀន ៣ ប៉ុន្តែមានសិស្សរៀនដល់ទៅ ៧ ថ្នាក់ គឺអង្គុយរៀនរួមថ្នាក់ ព្រោះសិស្សមានចំនួនតិចពេក ។

នៅត្រង់កន្លែងវត្តចាស់ មានគិលានដ្ឋានតូច ១ ទំហំប្រហែល ៤ ម៉ែត្រ ៤ ជ្រុងសង់អំពីឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ ខ្ពស់អំពីដី ។ គិលានដ្ឋាននេះកើតពីឆ្នាំ ១៩៦៧ មានគិលានុបដ្ឋាក ១ នាក់ ប្រចាំការជាអចិន្ត្រៃយ៍ ។

ប្រជាពលរដ្ឋមានជំនឿខាងព្រះពុទ្ធសាសនា ប៉ុន្តែបើមានជម្ងឺងាកទៅរកការបន់ស្រន់ខាងខ្មោច ព្រាយ បិសាច ខ្ទុះ ដែរ ។ កាលពុំទាន់មានគ្រូពេទ្យ បើមានជម្ងឺអ្នកស្រុកនាំគ្នាប្រើសំបកឈើជាមធ្យោ

បាយព្យាបាលពេគ និងមានមន្ទីរផ្សា ស្តោះផ្ទុំ ឬសែនព្រេនផងដែរ ប៉ុន្តែមកដល់សម័យសង្គមរាស្ត្រនិយម ដែលមានមន្ទីរពេទ្យ ឬគិលានដ្ឋាន ប្រជាពលរដ្ឋបានទំនិយមចូលទៅព្យាបាលនៅមន្ទីរពេទ្យក្រុងខេមរភូមិន្ទ ឬចូលទៅសុំថ្នាំលេប-ចាក់ នៅគិលានដ្ឋានកោះកាពិ ឬនៅកោះស្រឡៅនេះឯង ។

ភាសានិយាយ គឺមនុស្សអាយុ ៦០ - ៧០ ឆ្នាំ ច្រើនចេះភាសាសៀមជាងខ្មែរអាយុ ៣០-៤០-៥០ ឆ្នាំ ចេះខ្មែរនិងសៀមប្រហែលគ្នា បើពីអាយុ ៣០ ចុះមក ២០ ឆ្នាំចេះខ្មែរច្រើនជាងសៀម ប៉ុន្តែចំពោះក្មេងៗ ដែលមានអាយុពី ២០ ឆ្នាំចុះមក សុទ្ធតែចេះភាសាខ្មែរ ហើយច្បាស់លាស់ផង ចំណែកភាសាចិនវិញ ទាំងចាស់ទាំងក្មេង គេពុំចេះសោះទេ ។

ប្រជាពលរដ្ឋនៅកោះស្រឡៅ មានភ័ព្វសំណាងមួយ គឺធម្មជាតិបានផ្តល់ឲ្យ ដោយមានទឹកសាបសម្រាប់ប្រើប្រាស់បរិបូណ៌ ហើយទឹកសាបនៅកោះនេះ បានចិញ្ចឹមដល់ប្រជាពលរដ្ឋនៅកោះកាពិ និងអ្នកនៅតាមក្រសោប ទៀតផង ។

# ១៣-កោងកាងសមុទ្រ

តាមការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ ម៉ែន-ទន់ ខេត្តកោះកុង កាលពីខែកុម្ភៈ ១៩៦៨ ។

កោងកាងសមុទ្រ ជារុក្ខជាតិមួយយ៉ាងមានលក្ខណៈពិសេស គួរឲ្យចាប់អារម្មណ៍ និងគួរឲ្យកោតស្ញែងអំពីធម្មជាតិ និងអំពីគុណសម្បត្តិនៃដើមឈើនេះ ។

ឈើកោងកាងដុះនៅតែតាមមាត់សមុទ្រ-មាត់ព្រែក ដែលមានទឹកប្រៃ មានកំពស់ប្រហែលពី ៥ម.ទៅ ៨ម. និងមានទំហំដើមប្រហែលពី ០ម០៧ ទៅ ០ម១៥,។ បើដុះឃ្លាត ៗ ពីគ្នា ឯណោះ ១ ដើម ឯណោះ ១ ដើម ដើមកោងកាងមានទម្រង់ស្លឹក និងសំណុំមែក មិនខុសអំពីដើមឯទៀតឡើយ ប៉ុន្តែកម្រដុះឃ្លាតពីគ្នាណាស់ គឺដុះប្រជ្រៀតគ្នា ហើយមានមែកសកកគ្នាទៅវិញទៅមក ។ រីឯឫសវាវិញ ពុំមែនបែកចេញតែពីត្រង់គល់ដូចដើមគ្រប់ប៉ុណ្ណោះទេ គឺបែកចេញពីពាក់កណ្ដាលដើមក៏មាន បែកចេញពីមែកក៏មាន ។ ឫសនោះបែកត ៗ ទៅទៀតសំដៅទៅចាប់នឹងដី ហើយចាក់ស្រែះប្រទាក់ប្រទងគ្នាគួរឲ្យចង់ពិតពិលរមិលមើល ។

រុក្ខជាតិកោងកាងពុំមានជ្រុះស្លឹកព្រមគ្នាទៅតាមរដូវ ដូចរុក្ខជាតិឯទៀតទេ វាជ្រុះនិងលាស់ឡើងវិញបន្ត ៗ គ្នាពុំមានពេលចន្លោះ ម្ល៉ោះ

ហើយនៅវដូវណាក៏ដូចជាខែណាដែរ រុក្ខជាតិកោងកាងនៅ តមានស្ទឹកស្រស់ចំប្រប់ មានទិដ្ឋភាពគួរជាទីមនោរម្យយ៉ាងក្រៃលែង ។ បើយើងធ្វើដំណើរដោយនាវាទៅកណ្ដាលសមុទ្រ ហើយបោលនេត្រាមើលទៅមាត់ច្រាំង យើងនឹងឃើញព្រៃខៀវស្រងាត់ មានចុងត្រឹមដូចគេច្រិបនិងកន្ត្រៃ លាតសន្ធឹងយ៉ាងវែងជាប់និងផ្ទៃទឹក នោះហើយគឺជាដើមកោងកាង ។ បើនៅពេលរសៀលវិញយើងឃើញស្ទឹកកោងកាងត្រដាងខ្លួនទទួលរស្មីព្រះអាទិត្យ បញ្ចេញពណ៌ស្រអែត ស្ទើរលឿងស្ទើរបៃតងទាក់ទាញខ្សែចក្ខុអ្នកទេសចរណ៍ឲ្យមើលហើយមើលទៀតពុំចង់ឃ្លាតឆ្ងាយ និងធ្វើឲ្យទឹកស្រណោះ ស្រងេះស្រងោចឥតព្រំដែន ។

ដើមកោងកាងមានធម្មជាតិពិសេសមួយ ដែលសង្ការបាខគាត់តែងឲ្យ គឺឈើនេះបាប់កំណើតត ។ ពីមេទៅកូន ខុសអំពីឈើទាំងពួង ។ តើឈើកោងកាងកើតត ។ គ្នារបៀបណា ? ។

រុក្ខជាតិកោងកាងដុះនៅតែតាមមាត់សមុទ្រ ដែលមានទឹកជោរនាចត្រាំគល់ឈើនេះមានផ្ទៃដូចជាឈើដទៃដែរ មានទំហំប្រហែល ១ សង្ទីម៉ែត្រ ឬធំជាងនេះបន្តិច មានបណ្ដោយពី ០ម៣០ ទៅ ០ម៤០ និងមានរាងមូលដូចផ្លែននោង ឬផ្លែម្រុំ ឬក៏ដូចផ្លែប៉ីង ។ ផ្លែនោះរាងស្រួចចុងហើយសំយុងចុះសំដៅដី នៅចុងខាងលើដែលជាប់នៅគុងសណ្ដង់ទងមានបុចផ:ពន្ធកហើយស្រេច ពេលណាទុំ , ផ្លែនោះរបូតធ្លាក់ចុះទៅដី

ហើយដោតជាប់ត្រង់គ្នាឡើងលើដូចគេដាំ ។ ចុងម្ខាងដែលដោតជាប់ទៅក្នុងដីនោះ មិនយូរប៉ុន្មានក៏មានចេញឫសហាប់ជាប់ទៅនឹងដី រីឯចុងខាងលើដែលមានប៉ិចជាពន្លកហើយស្រួចនោះ ក៏បែកជាត្រួយបន្ទឹក និងមែកតទៅ ។

ដើមកោងកាងទីមួយ ១ មានផ្លែច្រើនណាស់ ហើយជ្រុះមកដុះប្រួងប្រាងនៅក្រោមដើម ។ លុះដុះបានធំបន្តិចហើយ ក៏ទៅជាចាំងសម្រាប់ទប់ដីខ្សាច់ គឺនៅពេលទឹកដោរហើយដែលមានរលកបោកបញ្ជូនដីខ្សាច់មកផង ដីខ្សាច់នោះក៏គៀងជាប់នឹងគល់កោងកាង ។ ការដែលដើមកោងកាងចេះតែដុះតគ្នាឆ្ងាយទៅ ១ ដីខ្សាច់ចេះតែគៀងលូតវែងទៅរកទឹកសមុទ្រដែរ លុះយូរ ១ ក៏កើតជាដីគោក ហើយការជម្រុះស្លឹកនៃដើមកោងកាងក៏នាំឲ្យមានជីជាតិ និងបំពេញសាច់ដីឲ្យកាន់តែខ្ពស់ថែមទៀត ។ ដូច្នេះ យើងគួរឲ្យឈ្មោះដើមកោងកាងថា : ជាវត្ថុសម្រាប់បង្កើតដី ឬ ជាជាអ្នកឈ្នានពានសមុទ្រ ។ ប៉ុន្តែដើមកោងកាងគ្រាន់តែមានទាទីខាងបង្កើតដីប៉ុណ្ណោះ លុះដីដុះបានខ្ពស់ហើយ ខ្លួនឯងក៏ត្រូវវិនាប់ទៅវិញ ហើយទុកកន្លែងឲ្យដើមស្មាច់គេដុះមុន ឯចំណែកដើមកោងកាងត្រូវបន្តសកម្មភាពទៅមុខទៀត ។ ដូច្នេះហើយបានជាគេឃើញទីណាមានដើមកោងកាង នៅខាងក្រោយនោះឃើញមានដីគោកហើយមានដើមស្មាច់ និងរុក្ខជាតិដទៃទៀត ដុះល្អើមគ្មានរំលោះសោះ ។

ក្រៅអំពីការបង្កើតដីដូចបានពោលខាងលើនេះ ដើមគោងកាងមានគុណប្រយោជន៍ផ្សេងទៀត គឺដើមវាគេយកទៅធុតធ្វើជាធ្យូងសម្រាប់ប្រើការយ៉ាងល្អឯក ឯសំបកវាគេយកទៅធ្វើជាថ្នាំសម្រាប់សម្លាប់ស្បែក ។

## ផ្នែកកំណត់-ប្រវត្តិការណ៍

# ពិធីបូជាសពព្រះសុមេធាវង្ស ប្រាជ្ញ-ប៊ុល

ព្រះសុមេធាវង្ស ប្រាជ្ញ-ប៊ុល រាជាគណថ្នាក់ត្រីគង់នៅវត្តឧណ្ណាលោម ដែលបានបានសុគតពីថ្ងៃទី ១៩ សីហា ១៩៦៩ នោះពុទ្ធបរិស័ទជាសិក្សានុសិស្ស បានរៀបចំធ្វើពិធីដង្ហែចេញពីកុដិរបស់សពព័ទ្ធជុំវិញវត្ត រួបចូលទៅកាន់ឈាបនដ្ឋានវត្តឧណ្ណាលោម ដើម្បីប្រារព្ធបូជាព្រះសព ។ កាលពីថ្ងៃអាទិត្យទី ២៤ ខែសីហា ១៩៦៩ វេលាម៉ោង ១៣ ។

នៅពេលរំកិលព្រះសពដាក់លើជើងថ្ករហើយ ព្រះសង្ឃបង្សុកូលចំពោះព្រះវិញ្ញាណក្ខន្ធនៅកណ្ដាលចំណោមពុទ្ធបរិស័ទទាំងអស់ដែលមានព្រះសង្ឃមាន សម្ដេចព្រះសង្ឃរាជ ព្រះរាជាគណៈឋានានុក្រម ព្រមទាំងព្រះសង្ឃសហធម្មិក ឯផ្នែកគ្រហស្ថមានសហជីវិន ឌុ-ធួច រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ មន្ត្រីរាជការក្រសួងធម្មការ និងបណ្ឌិតសិស្សគណជាច្រើនកុះករ ។

ដើម្បីជូនអ្នកអានជ្រាបអំពីព្រះសពឲ្យបានច្បាស់លាស់ យើងសូមចុះជូននូវសន្ទរកថា របស់ព្រះតេជព្រះគុណ ព្រះពុទ្ធវង្ស សេង-នាង ដែលថ្លែងក្នុងឱកាសនោះ ដូចតទៅ ៖

# សុន្ទរកថា

## ព្រះពុទ្ធវង្ស សេខ- ឆាង ថ្លែងក្នុងឱកាសបូជាសព ព្រះសុមេធវង្ស ប្រាជ្ញ-ប៉ុល នៅថ្ងៃ ២៤ សីហា ១៩៦៩ នៅឈាបនដ្ឋាន វត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

---

សូមព្រះតេជះតម្កល់លើត្បូង

*សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ*

*សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជជាអម្ចាស់*

*សូមទ្រង់ព្រះមេត្តាប្រោសជ្រាប ។*

*សូមពិតថេរដីកា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ, សូមចម្រើនពរ លោកអ្នកឧកញ៉ារដ្ឋលេខាធិការក្រសួងធម្មការ និងពុទ្ធបរិស័ទទាំងឡាយ*

*សូមទានជ្រាប - សូមជ្រាប ។*

*កូនទាមសិស្សានុសិស្ស និងញាតិមិត្រនៃសពព្រះសុមេធវង្ស ប្រាជ្ញ-ប៉ុល និងកូនទាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព ដែលជាអ្នកជួយចាត់ការបុណ្យសពនេះ, សូមព្រះរាជទាន ព្រះបរមរាជវរោកាស ដើម្បីថ្លែងទទួលនូវអំណរព្រះមហាករុណាធិគុណដ៏លើសលប់ ដោយកតញ្ញូកតាធម៌យ៉ាងស្មោះជាទីបំផុត ចំពោះសម្ដេចជាទីគោរពនៃពុទ្ធសាសនិកជនទូទៅ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ស្ដេចយាងមក*

ជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបុណ្យឈាបនកិច្ចសពព្រះសុមេធ-វង្ស ទ្រាជ្ជ-ប៊ុល នាពេលនេះ ។

ចំពោះព្រះរាជវត្តមានដ៏ឧត្តមនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមកត់សម្គាល់ទុកក្នុងហទយតែដ៏ជ្រាលជ្រៅជាទីបំផុត ព្រោះថាក្នុងបច្ចុប្បន្នកាលនេះ សូម្បីសម្តេចជាអម្ចាស់ទ្រង់មានព្រះសុខភាពនិងព្រះកាយពលពុំបរិបូណ៌យ៉ាងណាក៏ដោយ ព្រះអង្គក៏ទ្រង់ធ្មៀតយាងមកក្នុងពិធីនេះ ដើម្បីបានជាទីបន្សាត់បង់ នូវសេចក្តីខ្សឹកខ្សួលអួលអាក់របស់ទូលព្រះបង្គំទាំងឡាយ ដែលជាសិស្សគណនិងញាតិមិត្តនៃសពព្រះសុមេធវង្ស ។

មួយទៀត ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស ដើម្បីថ្លែងនូវអំណរគុណចំពោះព្រះករុណាគ្រប់ព្រះអង្គ និងចំពោះលោកអ្នកឧកញ៉ារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ ព្រមទាំងអស់លោក ជាពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដែលបាននិមន្ត-អញ្ជើញមកជួយឧបត្ថម្ភក្នុងពិធីឈាបនកិច្ចនេះ ឲ្យបានចំរើនរុងរឿងឡើង ។

សូមទ្រង់ព្រះមេត្តាប្រោស !

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមព្រះរាជទាន ព្រះបរមរាជានុញ្ញាត និងអនុញ្ញាត ថ្លែងនូវជីវប្រវត្តិសង្ខេបនៃព្រះសុមេធវង្ស ទ្រាជ្ជ-ប៊ុល ថ្វាយ ប្រគេន ជូនដូចតទៅនេះ :

ព្រះសុមេធាវង្ស ទ្រាង-ប៊ុល កើតក្នុងភូមិព្រៃម្នាស់ សង្កាត់ព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នៅថ្ងៃសៅរ៍ ខែមាឃ ឆ្នាំច ទោស័ក ព.ស. ២៤៥៣ គ.ស ១៩០៩, មាតានាម សៅ-យ៉ាន់ បិតានាម លក្ខណ៍-ទ្រាង ។

ព្រះសុមេធាវង្ស ទ្រាង-ប៊ុល កាលនៅជាកុមារ អាយុ ១៤ ឆ្នាំ បានចូលទៅសិក្សាអក្សរសាស្ត្រខ្មែរ និងធម៌អាថ៌ផ្សេងៗ ក្នុងសំណាក់លោកគ្រូធម្មកេសរ គង់-មៅ ចៅអធិការវត្តប្រាសាទ សង្កាត់ប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង អស់រយៈកាល ៣ ឆ្នាំទើបអាចមើលបានសរសេរកើត ។

លុះដល់ឆ្នាំខាលអដ្ឋស័ក ព.ស. ២៤៦៩ គ.ស. ១៩២៦ កុមារ ទ្រាង-ប៊ុល មានអាយុ ១៧ឆ្នាំ បានបួសជាសាមណេរក្នុងវត្តប្រាសាទ ដោយមានលោកគ្រូធម្មកេសរ គង់-មៅ ជាព្រះឧបជ្ឈាយ៍ ។

នៅឆ្នាំមមីនក្សត្រ ទោស័ក ព.ស.២៤៧៤ គ.ស.១៩៣០ សាមណេរ ទ្រាង-ប៊ុល មានអាយុគម្រប់ ២១ឆ្នាំ បានទទួលឧបសម្បទាជាភិក្ខុ ក្នុងព័ទ្ធសីមាវត្តប្រាសាទ ដោយបាននិមន្តលោកគ្រូធម្មកេសរ គង់-មៅ ជាព្រះឧបជ្ឈាយ៍, លោកគ្រូឥន្ទបញ្ញាវិន័យ រាជ-សាំង និងលោកគ្រូឥន្ទបញ្ញា អ៊ុក-ទៀវ ជាឧបសម្បទាចារ្យ បាននាមបញ្ញតិថា សុវណ្ណបញ្ញា ។

លុះដល់អាយុ ២៤ ឆ្នាំវស្សាទី ៤ ភិក្ខុ ប្រាជ្ញ-ប៉ុល បានទៅសិក្សាព្រះបរិយត្តិធម៌នៅវត្តព្រះនាង សង្កាត់កំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។

អាយុ ២៥ឆ្នាំ វស្សាទី ៥ ភិក្ខុ ប្រាជ្ញ-ប៉ុល បានទៅសិក្សាព្រះបរិយត្តិធម៌នៅវត្តពាមមង្គល សង្កាត់កោកោង ស្រុកមុខកំពូល ខេត្តកណ្តាល ។

អាយុ ២៨ ឆ្នាំវស្សាទី ៨ ភិក្ខុ ប្រាជ្ញ - ប៉ុល បានមកធ្វើជាមេកុដិលេខ ៣ ក្នុងក្រុមសម្តេចព្រះពោធិវង្ស វត្តឧណ្ណាលោមនេះជាប់រហូតមក ។

អាយុ ២៩ ឆ្នាំវស្សាទី ៩ ភិក្ខុ ប្រាជ្ញ - ប៉ុល បានចូលសិក្សាព្រះបរិយត្តិធម៌ក្នុងសាលាបាលីរង់វត្តឧណ្ណាលោម បានសញ្ញាប័ត្រសាលាបាលីរង់មាននាមថា មហាបរិយត្តិបឋមវិជ្ជា ។

អាយុ ៣៣ ឆ្នាំវស្សាទី ១៣ ភិក្ខុមហា ប្រាជ្ញ - ប៉ុល បានទទួលសមណសក្តិជាព្រះគ្រូវិសុទ្ធិមុនី ។

ពីអាយុ ៤១ ដល់ ៤៣ ឆ្នាំវស្សាទី ២១ ដល់ ២៣ ព្រះគ្រូវិសុទ្ធិមុនី ប្រាជ្ញ - ប៉ុល បានចូលអប់រំធម្មវិន័យថ្នាក់ត្រី - ទោ ឯក បានវិញ្ញាបនប័ត្រទាំង ៣ ថ្នាក់ មាននាមថាធម្មកោសលត្រី - ទោ - ឯក ហើយបានបង្រៀនធម្មវិន័យដល់ភិក្ខុសាមណេរក្នុងវត្តឧណ្ណាលោមតមកដល់មកថ្ងៃទី ២១ មករា ឆ្នាំ ១៩៥៤ ព្រះគ្រូវិសុទ្ធមុនី ប្រាជ្ញ - ប៉ុល បាន

ទទួលសមណស័ក្តិជាព្រះទេពមុនី ពជាគណៈថ្នាក់ទី ៤ ក្នុងអាយុ ៤៤ ឆ្នាំ វស្សាទី ២៣ និងជាអតីតសមាជិកនៃវេវសភាផង ។

ដល់មកថ្ងៃទី ២៧ ឧសភា ១៩៦៣ ព្រះទេពមុនី ច្រាជ្ញ-ប៉ុល បានឡើងសមណស័ក្តិជា ព្រះសុមេធាវង្សពជាគណៈថ្នាក់ទី ៣ ក្នុងអាយុ ៥៣ ឆ្នាំវស្សា ៣២ ។

ថ្ងៃទី ១២ មេសា ១៩៦៤ ព្រះសុមេធាវង្ស ច្រាជ្ញ-ប៉ុល បាន ទទួលគ្រឿងឥស្សរិយយសមេដាយសុវត្ថា ទីអស្សបុទ្ធិ ។

ក្រៅពីនេះព្រះសុមេធាវង្ស ច្រាជ្ញ-ប៉ុល បានចេះចាំកិក្ខុបាតិមោក្ខ បាលីអាចសូត្រមាត់ទទេបាន, បានជាវគម្ពីរធម៌អាចិវេស្រង ១ មានគម្ពីរព្រះ ត្រៃបិដកបាលី-សម្រាយជាដើម បានស្ថាបនាកុដិ ២ ខ្នង ដោយឥដ្ឋស៊ីម៉ងត៍ គ្រឿងឈើប្រក់ក្បឿងក្នុងវត្តឧណ្ណាលោម , បានជួសជុលសម្អាតព្រះ ចេតិយ ១ អង្គក្នុងវត្តប្រាសាទ, បានសាងព្រះចេតិយ ២ អង្គទៀត ក្នុង ភូមិព្រៃម្នាស់ សង្កាត់ព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង, បានជួយ ស្ថាបនាវិហារវត្តប្រាសាទនិងវិហារវត្តសានគរ ស្រុកស្ទោង ខេត្តកំពង់ធំ ដែលកំពុងតែស្ថាបនាសព្វថ្ងៃពុំទាន់ហើយនៅឡើយ ។

ជាអកុសលទទួលរោគទឹកមូត្រផ្អែម លេបលួចចូលមកក្នុងសរីរាង្គ កាយរបស់លោកបន្តិចម្តងៗ ហើយកាន់តែចម្រើនឡើងៗ ។ សិស្សគណ និងញាតិមិត្រមានលោកវេជ្ជបណ្ឌិតវ័ន្ន គុត ជាដើម បាននាំលោកទៅ

ព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា ។ ទោះបីគ្រូពេទ្យខំប្រឹងប្រែងដោយសេចក្តីព្យាយាមយ៉ាងណាក៏ដោយ នៅតែពុំអាចទប់ទល់នឹងរោគនោះបានឡើយ ។ ដោយអស់សង្ឃឹមក្នុងការព្យាបាលតទៅទៀត, គ្រូពេទ្យ ក៏ឲ្យលោកនិមន្តត្រឡប់មកកុដិរបស់លោកវិញ ។

ដល់មកថ្ងៃអង្គារទី ៦ កើត ខែស្រាពណ៍ ឆ្នាំរកាឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ១៩ សីហា ១៩៦៩ វេលាម៉ោង ២៣ និង ៤០ នាទី,ស្រាប់តែមច្ចុរាជដ៏កាចសាហាវចូលមកផ្តាច់ផ្តិលជីវិត នៃព្រះសុមេធាវង្ស ប្រាជ្ញ-ប៉ុល នាកណ្តាលចំណោមសិស្សានុសិស្ស ញាតិមិត្រ នៅទីកុដិរបស់លោកក្នុងអាយុ ៦០ ឆ្នាំ វស្សាទី ៣៩ ។

សូមគ្រប់ព្រះមេត្តាប្រោស !

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងនូវវិយោគសេចក្តីស្តាយស្រណោះអាឡោះអាល័យចំពោះសពព្រះសុមេធាវង្ស ប្រាជ្ញ-ប៉ុល ដូចតទៅនេះ ៖

## ព្រះសុមេធាវង្ស ប្រាជ្ញ-ប៉ុល !

ថ្ងៃនេះ សិស្សានុសិស្ស ញាតិមិត្រនិងពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ បានជូនដំណើរលោកគ្រូ មកដល់តែត្រឹមទីនេះទេ បន្ទិចទៀតរូបកាយរបស់លោកគ្រូនឹងបាត់បង់ទៅហើយ នៅសល់តែគុណបំណាច់និងសេចក្តីល្អដែលលោកគ្រូសាងទុកជាកេរ្តិ៍តំណាងប៉ុណ្ណោះ ។

# លោកគ្រូព្រះសុមេធវង្ស !

សូមលោកគ្រូកុំតូចចិត្តក្នុងការបាត់បង់រូបកាយនេះ ព្រោះរូបកាយនេះ មានការកើតឡើង និងបែកធ្លាយទៅវិញជាទំនៀមដូចថ្ងៃបណ្ដើរកូន ឬដូចជាដុំពពុះទឹកដែលប៉ោងឡើងហើយបែកធ្លាយទៅវិញដូច្នោះដែរ ។

ហេតុនេះ ការបាត់បង់រូបកាយមិនមែនមានចំពោះតែលោកគ្រូមួយរូបប៉ុណ្ណោះទេ គឺប្រាកដជាមានដល់រូបយើងខ្ញុំទាំងអស់គ្នាផងដែរ គ្រាន់តែខុសពេលគ្នាត្រង់មុននិងក្រោយប៉ុណ្ណោះ ។

លោកគ្រូព្រះសុមេធវង្ស ! ទោះបីដូច្នោះក៏ដោយ យើងខ្ញុំទាំងអស់គ្នា ក៏នៅតែមានសេចក្តីស្តាយចំពោះការបាត់បង់នេះ ព្រោះការបាត់បង់រូបលោកគ្រូនេះ ចាត់ទុកជាការបាត់បង់មហាថេរមួយរូប ដែលមានចិត្តស្មោះត្រង់ចំពោះជាតិ សាសនា និងព្រះរាជបល្លង្គ ស៊ូទ្រាំនៅក្នុងភេទបព្វ-ជិតជាប់ដល់អស់ជីវិត ។ នេះជាគំរូមួយដ៏ល្អ គួរបព្វជិតជំនាន់ក្រោយយកជាតម្រាប់តាម ។

យើងខ្ញុំទាំងអស់គ្នាជាសិស្សគណនិងជាញាតិមិត្ត គ្មានវត្ថុប្រសើរផ្ញើប្រគេនចំពោះលោកគ្រូទេ មានតែបុណ្យកុសលដែលយើងខ្ញុំបានធ្វើនាពេលនេះ ទុកជាគ្រឿងសក្ការៈបូជាចំពោះលោកគ្រូ សូមលោកគ្រូបានប្រកបដោយសេចក្តីសុខ ចម្រើនក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ជាអវសាន ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយអភិ-បាលរក្សាអង្គសម្តេចព្រះសង្ឃរាជជាម្ចាស់ សូមព្រះអង្គប្រកបដោយព្រះបរមសុខសួស្តី មានព្រះជន្មាទីឃាយុយឺនយូរតរៀងទៅ !

មួយចំណែកទៀត សូមគុណបុណ្យព្រះរតនត្រ័យជួយថែរក្សា ព្រះករុណាគ្រប់ព្រះអង្គ និងលោកអ្នកឧកញ៉ាវង្សលេខាធិការក្រសួងធម្មការ ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ដែលបាននិមន្តអញ្ជើញមកជួយឧបត្ថម្ភពិធីបុណ្យសពនាពេលនេះ សូមបានប្រកបដោយសេចក្តីសុខចម្រើនគ្រប់ទិវារាត្រីកុំឃ្លៀងឃ្លាតឡើយ ! ។

សេចក្តីគោរពគួរសមទ្រង់ព្រះករុណាប្រោស ៚

# ពិធីប្រគេនព្រះរាជអំណោយសម្តេចឪ
# ចំពោះសម្តេចព្រះពោធិវង្ស

---

ថ្ងៃអង្គារ ទី ២៦ សីហា ១៩៦៩ វេលាម៉ោង ៩ ព្រឹក នៅក្នុងសាលបណ្ណាល័យនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ មានធ្វើពិធីមួយ ដោយមាន ឯ.ឧ. ឡុង - គីម ទេសាភិបាលធនាគារជាតិ ជាព្រះរាជបម្រើនាំព្រះរាជអំណោយសម្តេចឪជាប្រាក់មួយលានរៀល មកប្រគេនសម្តេចព្រះពោធិវង្ស ដើម្បីឧបត្ថម្ភក្នុងការស្ថាបនា អគារពុទ្ធសាសនបណ្ឌិត្យ ។

នៅវេលាម៉ោង ៩ គត់ ជួបជុំព្រះសង្ឃនិងគ្រហស្ថ ដែលយើងសង្កេតឃើញផ្នែកព្រះសង្ឃមានសម្តេចព្រះពោធិវង្ស សកលវិទ្យាធិការនៃពុទ្ធិកសកលវិទ្យាល័យ និងជាអគ្គាធិការ នៃពុទ្ធិកសិក្សា ក្នុងព្រះរាជាណាចក្រ មួយអន្លើដោយព្រះសង្ឃជាសាស្ត្រាចារ្យនៅពុទ្ធិកសាកលវិទ្យាល័យ ពុទ្ធិកវិទ្យាល័យ និងសមាជិកក្រុមជំនុំព្រះត្រៃបិដក; ផ្នែកខាងគ្រហស្ថមាន ឯ.ឧ. ឡុង - គីម ទេសាភិបាលធនាគារជាតិ សហជីវិន ឌី-ឡុង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុក ក្រសួងធម្មការ,

សហ. អ៊ុំ-ឈួ-ស៊ុយហួ នាយកការិយាល័យក្រសួងធម្មការ,

សហ. ណាង់ - ហ៊ាបអាន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ,

សហ. ខែ-ម៉េងហាប់ អគ្គលេខាធិការនៃពុទ្ធិកសកលវិទ្យាល័យ

ព្រះស៊ីហនុរាជ, សហ. ជាប ស៊ីវណ្ណ ទីប្រឹក្សាបច្ចេកទេស នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សា និងអស់លោកសាស្ត្រាចារ្យពុទ្ធិកសាកលវិទ្យាល័យ, ពុទ្ធិកវិទ្យាល័យ និងមន្ត្រីរាជការនៅក្រសួងធម្មការ និងក្រុមនានានៅក្រោមឱវាទ ។

ក្រោយដែលបានក្រាបបង្គំ សម្ដេចព្រះពោធិវង្ស និងព្រះសង្ឃគ្រប់ព្រះអង្គហើយ ឯ.ឧ. ទួច-គីម បានថ្លែងសង្កថាយ៉ាងខ្លីមួយ បញ្ជាក់អំពីព្រះរាជអំណោយមួយលានរៀល ដែលសម្ដេចឪជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសប្រទានក្នុងវេលានេះ ។ គឺថា ដើមឡើយ ឯ.ឧ. អ៊ឹង-ហ៊ុនសាជ កាលលោកនៅកាន់ដំណែងជាឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងធម្មការនោះ លោកបានថ្វាយបុតហ្វាយមួយ ចំពោះសម្ដេចឪជាអម្ចាស់ ដើម្បីសុំខ្ចីប្រាក់អំពីហិបប្រាក់ស្ថាបនាជាតិចំនួនមួយលានរៀល យកមកចាត់ចែងការសិន ទម្រាំបានទទួលពីថវិកាជាតិសម្រាប់ការស្ថាបនាអគារពុទ្ធសាសនបណ្ឌិត្យ ដែលសព្វថ្ងៃនេះជិតបានរួចទៅហើយ ។ ក្រោយដែលទ្រង់ជ្រាបដំណឹងនេះ សម្ដេចឪជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទានមួយលានរៀលនេះ ដើម្បីប្រគេនសម្ដេចព្រះពោធិវង្ស ជាចំណែកក្នុងកិច្ចការស្ថាបនាអគារនេះ ដោយមិនបាច់សងវិញឡើយ ។

បន្ទាប់មក សម្ដេចព្រះពោធិវង្ស ព្រះអង្គមានពុទ្ធដីកា ថ្លែងអំណរ

ព្រះមហាករុណាធិគុណនៃសម្តេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ប្រោសប្រទានការឧបត្ថម្ភដ៏មុតមាំនៅវេលានេះ បន្ថែមលើព្រះរាជូបត្ថម្ភដ៏ច្រើនអនេក ដែលព្រះអង្គទ្រង់តែងប្រោសប្រទានចំពោះព្រះពុទ្ធសាសនា និងចំពោះជាតិ ៗ បន្តមក សម្តេចមានពុទ្ធដីកាបន្ថែមអំពីប្រវត្តិខ្លះនៃមន្ទីរពុទ្ធសាសនបណ្ឌិត្យ ដែលដើមឡើយនៅដោយឡែកអំពីក្រសួងធម្មការ លុះមកដល់ពេលខ្មែរយើងបានឯករាជ្យម្តង កាលពីសម័យជប៉ុន សម្តេចឧបយុវរាជកាលព្រះអង្គគង់នៅក្នុងរាជសម្បត្តិនោះព្រះអង្គសព្វព្រះរាជហឫទ័យឲ្យក្រសួងធម្មការមកនៅអែបជាមួយ ហើយគ្រប់គ្រងលើពុទ្ធសាសនបណ្ឌិត្យរហូតមក ៗ ទីបំផុតព្រះអង្គថ្វាយព្រះពរចំពោះសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏និងអំណោយគុណចំពោះឯកឧត្តមជាព្រះរាជអំណាង ដែលបានអញ្ជើញមកក្នុងវេលានេះ ៗ

តមកទៀត សហជីវិន ឌី-ឡូច ក៏បានថ្លែងសន្ទកថាមួយដែរ ដើម្បីបញ្ជាក់អំពីសេចក្តីត្រេកអរដ៏ឥតឧបមា របស់បុគ្គលិកក្រសួងធម្មការនិងវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ចំពោះព្រះរាជអំណោយដ៏ថ្លៃថ្លាវិសេសនេះ ព្រមទាំងសេចក្តីកោតសរសើរចំពោះសម្តេចព្រះពោធិវង្ស ដែលព្រះអង្គបានធ្វើព្រះភារកិច្ចជាច្រើនចំពោះពុទ្ធិកសិក្សាក្នុងព្រះរាជាណាចក្រ មិនតែប៉ុណ្ណោះព្រះអង្គបានប្រឹងប្រែងពេញកម្លាំងព្រះកាយដើម្បីស្ថាបនាអគារពុទ្ធសាសន

បណ្ឌិត្យ នៅក្នុងវេលានេះជាអាទិ៍ ។ ទីបំផុត សហជីវិន រដ្ឋលេខាធិការ បានថ្លែងអំណរគុណចំពោះព្រះសង្ឃទាំងអស់ ព្រមទាំងឯកឧត្ដម ទូចគីម ដែលជាព្រះរាជតំណាង ដែលបាននិមន្តនិងអញ្ជើញមកធ្វើជាអធិបតីឲ្យបានឧឡារិកក្នុងពិធីនេះ ។ មួយទៀត សហជីវិន ថ្លែងអំណរគុណផងដែរ ចំពោះបុគ្គលិកទាំងអស់នៅក្រសួងធម្មការ ដែលបានធ្វើការយ៉ាងសុខដមបម្រើកិច្ចការអាណាចក្រ និងពុទ្ធចក្រ ឲ្យបានចម្រើនហូរហែមក ។

ពិធីនេះ បានចប់សព្វគ្រប់នៅម៉ោង ១០ ដោយមានការលៀងភេសជ្ជៈ ជាកិច្ចបង្ហើយផង ។

លី-គាមតេង

បន្ទាប់ពីបានទទួលព្រះរាជអំណោយនេះហើយ សម្ដេចព្រះពោធិវ័ង្ស ព្រះអង្គបានថ្វាយចុតហ្មាយមួយច្បាប់ចំពោះសម្ដេចព្រះប្រមុខរដ្ឋ ដែលយើងសូមចុះផ្សាយ នៅទំព័របន្ទាប់នេះ ។

# សូមថ្វាយព្រះពរចំពោះសម្តេចព្រះប្រមុខរដ្ឋ
# ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ព្រះមេត្តាប្រោស

អាត្មាភាព, តាងនាមសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក លោករដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ, ព្រះភិក្ខុសង្ឃសង្គីតិកាចារ្យខាងក្រុមជំនុំព្រះត្រៃបិដក ព្រមទាំងបុគ្គលិកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ និងក្នុងនាមនៃអាត្មាភាពផ្ទាល់ អាត្មាភាពសូមព្រះពរឱកាសថ្វាយនូវព្រះមហាកតញ្ញូតាធម៌ចំពោះសម្តេចជាម្ចាស់ ដែលបានប្រោសព្រះរាជទានព្រះរាជអំណោយចំនួនមួយលានរៀល (១.០០០.០០០) ដើម្បីចាត់ចែងការ កសាងអគារ នៃវិជ្ជាឋាន ពុទ្ធសាសនបណ្ឌិត្យ និងក្រសួងធម្មការ ដែលកំពុងតែប្រព្រឹត្តទៅបានហើយស្រេចជិតបីភាគបួននៃការងារ ។ ពិធីប្រគល់នូវព្រះរាជអំណោយដ៏ថ្លៃថ្លានេះ បានធ្វើនៅពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ នៅក្នុងថ្ងៃទី២៦ សីហា១៩៦៩ នេះ វេលាម៉ោង ៩ ព្រឹក ក្រោមអធិបតីភាពនៃឯកឧត្តម ទូច គីម ទេសាភិបាលនៃធនាគារជាតិកម្ពុជា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ហើយដោយមានលោករដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងសហការី និងមន្ត្រីសង្ឃពុទ្ធិកសិក្សាបករួមជាមួយផង ។

សម្តេចជាម្ចាស់

ព្រះកាយវិការប្រកបដោយសប្បុរសធម៌ ប្រៀបបាននឹងមហាសាគរនេះ បានញ៉ាំងអាត្មាភាពឲ្យកាន់តែមានវិរិយភាព និងកម្លាំងពលំក្នុងការស្ថាបនាគ្រឹះស្ថាននៃពុទ្ធសាសនបណ្ឌិត្យនិងក្រសួងធម្មការ ព្រមទាំងសម្ពិទ្ធិខាងសង្គមកិច្ច ដង្ហែតាមព្រះរាជមាគ៌ាកសាងវឌ្ឍនភាពនៃប្រទេស ។ ព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ព្រះករុណាវិសេសក្នុងគ្រានេះទៀត គឺជាសក្តិភាពយ៉ាងឧត្តម ថែមទៅលើព្រះរាជអំណោយកប់មិនអស់ហើយមិនចេះដាច់ ដែលសម្តេចជាអម្ចាស់ទ្រង់បានប្រោសព្រះរាជទានចំពោះកូនចៅ គ្រប់និគមជនបទ,ចំពោះអង្គការកសាងជាតិគ្រប់វិស័យ, គឺដូចជាការឧបត្ថម្ភព្រះពុទ្ធសាសនា ដែលមានក្រសួងធម្មការ និងវិជ្ជាបានពុទ្ធ-សាសនបណ្ឌិត្យជានិមិត្តរូប ។

ក្នុងការទទួលព្រះរាជអំណោយថ្ងៃនេះ អាត្មាភាពនឹកទៅដល់ ព្រះមហាគុណូបការៈ របស់សម្តេចជាម្ចាស់ កាលទ្រង់គង់នៅជាព្រះមហាក្សត្រក្នុងសិរីរាជសម្បត្តិនៅឡើយ ហើយស្តេចយាងផ្ទាល់ព្រះអង្គមកកាន់វិជ្ជាបានពុទ្ធសាសនបណ្ឌិត្យនាគ្រិស្តសករាជ ១៩៤៥ ដើម្បីទ្រង់រៀបបំក្រសួងធម្មការឲ្យរើតទៅធ្វើការរួមជាមួយគ្នាក្នុងគ្រឹះស្ថានតែមួយ ។ វិជ្ជាបានពុទ្ធសាសនបណ្ឌិត្យនោះគឺជាមជ្ឈមណ្ឌលដ៏វិសេស តំណាងនូវវប្ប-ធម៌និងអារ្យធម៌ជាតិ ជាព្រះកេរ្តិ៍ណែលនៃព្រះករុណាព្រះបាទសម្តេចព្រះ

ស៊ីសុវត្ថិ-មុនីវង្ស បរមខត្តិយគោដិ , ព្រះករុណាព្រះបាទ សម្តេចព្រះ ស៊ីហនុវរ្ម័ន ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ព្រះ មហាកាញ្ញុនគោដិ ហើយក្នុងបច្ចុប្បន្នកាល នេះ គឺជារស្មីនៃពុទ្ធសាសនា ចិញ្ចែងលើផ្ទៃភពអន្តរជាតិ ក្នុងសម័យ សង្គមរាស្ត្រនិយម ព្រះ នរោត្តម-សីហនុ ព្រះអគ្គប្រមុខរដ្ឋនៃកម្ពុជា ឯករាជ្យ អព្យាក្រិត្យ អនុស្សាវរីយ៍ទាំងអស់នេះហើយ បានដាស់ញាក់នូវ ព្រះរាជហឫទ័យនៃសម្តេចជាម្ចាស់ដែលទ្រង់ជាប់ជំពាក់ជានិច្ច ចំពោះកិច្ច ទ្រទ្រង់ពុទ្ធសាសនា ដែលជាព្រះភារកិច្ចយ៉ាងសំខាន់ឯករបស់ព្រះរាជ បល្ល័ង្ក និងរបស់សង្គមរាស្ត្រនិយម ។ អាត្មាភាពព្រមទាំងពុទ្ធបរិស័ទ ទាំងអស់ មានជំនឿយ៉ាងខ្ជាប់ខ្ជួនចំពោះព្រះរាជបុត្តមក៍នៃសម្តេចជាអម្ចាស់ ក្នុងវិស័យពុទ្ធសាសនា ដោយសង្ឃឹមថា នឹងចេះតែរុងរោចន៍ជានិច្ចលើ ឆាកអន្តរជាតិដើម្បីសេចក្តីសុខ សន្តិភាព ចំពោះកម្ពុជរដ្ឋនិងសកលលោក ផង ។

ជាទីអវសាន អាត្មាភាព សូមប្រមូលនូវបុញ្ញរាសីដែលកើតឡើង អំពីព្រះរាជកុសលដ៏ថ្លៃថ្លានេះ ថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានីជា អម្ចាស់ជីវិត ចំពោះសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់, សូមទ្រង់បានប្រកបតែ ព្រះបរមសុខសួស្តី ជោគជ័យមង្គល ឈ្នះអស់មារសត្រូវជិតឆ្ងាយ សូម ព្រះករុណាទាំងពីរព្រះអង្គ មានព្រះបរមសុខភាពបរិបូណ៌ មានព្រះជន្មា

ទីឃាយុជាងរយព្រះវស្សា ដើម្បីជាម្លប់ដល់ពុទ្ធបរិស័ទ និងប្រជាពលរដ្ឋ ជាកូនចៅ អស់កាលជានិច្ចនិរន្តរ៍តទៅ ៖

គួរពុំគួរសូមសម្ដេចជាម្ចាស់ទ្រង់ព្រះករុណាប្រោស

សូមថ្វាយនៅភ្នំពេញ ថ្ងៃទី ២៥ សីហា $\frac{២៥១៣}{១៩៦៩}$

អាត្មាភាព :

សម្ដេចព្រះពោធិវង្ស ហួត - តាត